**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈ ការដាំបន្លែ

(**ករណីសិក្សា ៖ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល**)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **អិន សុគា**

**ឡាញ់ ស្រីនាថ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ង៉ាន់ ស៊ុនដេត**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ អិន សុគា និង ឡាញ់ ស្រីនាថ ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកទេសសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី១៦ ក្រុម $E_4DC_1$ ឆ្នាំសិក្សា ២០១៦-២០១៧ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណ

- លោកឪពុក ចៀម វិត និង អ្នកម្តាយ សែម សុភី
- លោកឪពុក ខៀវ ស្រ៊ី និង អ្នកម្តាយ យុន ស៊ីម

ដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូនឲ្យបានធំដឹងក្តី ដោយមិនខ្លាចនឿយហត់ ព្រមទាំងអប់រំកូនឲ្យដើរតាមគន្លងធម៌ ។ លោកទាំងពីរតែងតែផ្តល់ដំបូន្មានល្អៗដល់កូន និងបានផ្គត់ផ្គង់ឲ្យកូនបានសិក្សារៀនសូត្រមានចំណេះដឹង ព្រមទាំងលើកទឹកចិត្តកូនគ្រប់ពេលវេលា ដើម្បីឲ្យកូនខិតខំតស៊ូទទួលបានជោគជ័យក្នុងការសិក្សាក្លាយជាពលរដ្ឋល្អម្នាក់ក្នុងសង្គម។

## សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ

- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក-លោកស្រី ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធាន អនុប្រធានការិយាល័យ លោក-លោកស្រី សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកគ្រប់លំដាប់ថ្នាក់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត បង្ហាត់ បង្រៀន យើងខ្ញុំតាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់បញ្ចប់ និងបង្កភាពងាយស្រួលដល់ការរៀនសូត្រ និងផ្តល់ចំណេះដឹងដល់យើងខ្ញុំឲ្យក្លាយជាពលរដ្ឋដែលអាចជួយអភិវឌ្ឍសង្គមបាន។
- លោកសាស្ត្រាចារ្យ បណ្ឌិត ង៉ាន់ ស៊ុនដេត ដែលបានណែនាំយើងខ្ញុំ ដោយបានចំណាយពេលវាលាដ៏មានតម្លៃក្នុងការដឹកនាំ បង្ហាត់បង្ហាញ ពន្យល់ណែនាំ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដល់យើងខ្ញុំ ក្នុងការសរសេរសារណារហូតទទួលបាននូវភាពជោគជ័យ។
- លោកអ៊ុំមេឃុំ នួន សឿន និង លោកអ៊ុំស្មៀនឃុំ ស្រេង កួយ នៅឃុំស្វាយប្រទាល ព្រមទាំងមន្ត្រីពាក់ព័ន្ធទាំងអស់នៅមន្ទីរកសិកម្មខេត្តកណ្តាល ដែលបានផ្តល់ឯកសារ និងទិន្នន័យក្នុងឃុំ និងបានសហការណ៍យ៉ាងល្អជាមួយយើងខ្ញុំទាំងពីរនាក់ ដើម្បីគាំទ្រដល់ដំណើការនៃការចងក្រងសារណានេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរលោកអ្នកមានគុណទាំងបួន ឯកឧត្តម លោកសាស្ត្រាចារ្យ និងអស់លោកអ្នកដែលបានរៀបរាប់ខាងលើនេះ ទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល និងការសិក្សាផ្នែកទ្រឹស្តីអស់រយៈពេលជិត៤ឆ្នាំ និងការចុះសិក្សាស្រាវជ្រាវ នៅឃុំស្វាយប្រទាល ក្នុងស្រុកស្អាង ខេត្តកណ្តាល ដែលយើងខ្ញុំបានសិក្សាដែលទាក់ទងនឹងកសិកម្មដំណាំបន្លែក្រោមប្រធានបទ ″ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈការដាំបន្លែ″ ។

គោលគំនិតចម្បងនៃប្រធានបទនេះគឺ ស្វែងយល់អំពីឥទ្ធិពលនៃដំណាំបន្លែទៅលើសេដ្ឋកិច្ចគ្រួសាររបស់កសិករ ស្ថានភាពដាំដុះបន្លែក្នុងឃុំស្វាយប្រទាល ដែលមានដូចជា ការសិក្សាអំពីលក្ខណៈបច្ចេកទេសក្នុងការដាំដុះបន្លែ ការសិក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយនានាដែលកើតមានជុំវិញការដាំដុះបន្លែ។ រួមជាមួយនឹងការវិភាគពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែ ការសិក្សាពីសារៈសំខាន់នៃដំណាំបន្លែ និងអនុសាសន៍ចាំបាច់ ដើម្បីជំរុញផលិតភាពដំណាំបន្លែរបស់កសិករដែលរស់នៅពឹងផ្អែកលើការដាំបន្លែនេះ។

ដើម្បីឲ្យសម្រេចបានសារណានេះ កាន់តែមានខ្លឹមសារ និងអត្ថន័យល្អ យើងខ្ញុំក៏បានធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ទៅលើទស្សនៈនិងទ្រឹស្តីពាក់ព័ន្ធមួយចំនួន នៅស្ថាប័នផ្សេងៗដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម មន្ទីរកសិកម្មខេត្តកណ្តាល និងគេហទំព័រមួយចំនួន ក៏ដូចជាឯកសារផ្សេងៗទៀត។ ការសិក្សានេះ បានលើកឡើងពីបទពិសោធន៍ជាក់ស្តែង ក្នុងការដាំដុះ និងប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងការប្រកបរបរដាំបន្លែរបស់ប្រជាកសិករក្នុងឃុំស្វាយប្រទាលនេះ។

នេះជាការរួមចំណែកដ៏តូចមួយ ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានចុះសិក្សាស្រាវជ្រាវដល់មូលដ្ឋានឃុំស្វាយប្រទាល និងស្ថាប័នពាក់ព័ន្ធ។ យើងខ្ញុំសង្ឃឹមថាសៀវភៅសារណាបទនេះ នឹងអាចជួយជាគំនិតមួយ ក្នុងការលើកស្ទួយផលិតកម្មកសិកម្ម ពិសេសដំណាំបន្លែ ក្លាយជាផ្នែកមួយដែលផ្តល់ប្រយោជន៍ ដល់ការសិក្សារបស់លោកអ្នក ឬឲ្យមានការរីកចម្រើនសម្រាប់ប្រទេសកម្ពុជា ។

អាស្រ័យដោយការសិក្សាស្រាវជ្រាវនិងចំណេះដឹងរបស់យើងខ្ញុំ នៅមានកម្រិត ទើបទាំងផ្នែកខ្លឹមសារ និងអក្ខរាវិរុទ្ធ ពុំទាន់មានលក្ខណៈល្អឥតខ្ចោះនៅឡើយ។ យើងខ្ញុំរីករាយរង់ចាំទទួលការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកអ្នកអាន ទាំងអស់ដើម្បីឲ្យសៀវភៅនេះកាន់តែមានន័យពេញលេញ។

# មាតិកា

បញ្ជីអក្សរកាត់ .......... v

បញ្ជីតារាង .......... vi

បញ្ជីក្រាប .......... vi

## សេចក្តីផ្តើម

១. លំនាំបញ្ហា .......... ១

២. ចំណោទបញ្ហា .......... ១

៣. គោលបំណងនៃការស្រាវជ្រាវ .......... ១

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .......... ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ .......... ២

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ .......... ២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ៣

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១. ទ្រឹស្តីកសិកម្ម .......... ៥

១.១.១. និយមន័យកសិកម្ម .......... ៥

១.១.២. ប្រវត្តិកសិកម្ម .......... ៦

១.១.៣. កសិកម្មកម្ពុជា .......... ៦

១.១.៤. បច្ចេកទេសហាយដ្រូផូនិចជាផ្នែកមួយនៃទំនើបកម្មកសិកម្មកម្ពុជា .......... ៧

១.២. ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច .......... ៨

១.២.១. និយមន័យនៃការអភិវឌ្ឍ .......... ៨

១.២.២. គោលបំណងនៃការអភិវឌ្ឍ .......... ៩

១.៣. និយមន័យបន្លែ .......... ៩

១.៤. សារៈសំខាន់នៃការដាំដុះបន្លែ .......... ១០

១.៤.១. សារៈសំខាន់ផ្នែកម្ហូបអាហារ .......... ១០

១.៤.២. សារៈសំខាន់ផ្នែកសេដ្ឋកិច្ច .......... ១១

១.៥.កត្តាសំខាន់ៗទាក់ទងនឹងការដាំដុះបន្លែ .......... ១២

១.៥.១. កត្តាធាតុអាកាស ............................................................................................. ១២
១.៥.១.១. សីតុណ្ហភាព............................................................................................. ១២
១.៥.១.២. កត្តាទឹកភ្លៀង ............................................................................................ ១២
១.៥.១.៣. សំណើមក្នុងបរិយាកាស............................................................................... ១៣
១.៥.១.៤. រយៈពេលយប់ និងថ្ងៃ ............................................................................... ១៣
១.៥.២. កត្តាទឹក ............................................................................................................ ១៤
១.៥.៣. កត្តាដី ............................................................................................................... ១៤
១.៥.៤. កត្តាជី ............................................................................................................... ១៥
១.៦. ស្ថានភាពទីផ្សារបន្លែនៅកម្ពុជា ................................................................................. ១៥
១.៦.១. និយមន័យទីផ្សារ................................................................................................. ១៦
១.៦.២. តម្រូវការ និងច្បាប់តម្រូវការ.................................................................................. ១៦
១.៦.៣. ផ្គត់ផ្គង់ និងច្បាប់ផ្គត់ផ្គង់ ....................................................................................... ១៧
១.៧. ប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងផលិតកម្មកសិកម្ម.................................................................... ១៧
១.៧.១. តម្រូវការទុនផលិតកម្ម និងការចំណាយ...................................................................... ១៧
១.៧.២. ចំណូលពីការលក់ដំណាំបន្លែ.................................................................................... ១៨
១.៧.៣. ប្រាក់ចំណេញពីការដាំដុះបន្លែ.................................................................................. ១៨
១.៧.៤. ប្រសិទ្ធភាពសេដ្ឋកិច្ចមួយឯកតាទុនផលិតកម្ម ............................................................... ១៩
១.៧.៥. ប្រសិទ្ធភាពកម្លាំងពលកម្ម ...................................................................................... ១៩
១.៧.៦. ប្រសិទ្ធភាពដីធ្លី .................................................................................................. ១៩
១.៨. ការវិភាគចំណុចស្រង់ដើម ......................................................................................... ១៩

## ជំពូកទី២

## ស្ថានភាពទូទៅនៃដំណាំបន្លែនៅឃុំស្វាយប្រទាល

២.១. ស្ថានភាពទូទៅនៃតំបន់សិក្សាស្រាវជ្រាវ......................................................................... ២១
២.១.១. ស្ថានភាពទូទៅនៃស្រុកស្អាង ..................................................................................... ២១
២.១.១.១. ទីតាំងភូមិសាស្ត្រស្រុកស្អាង.................................................................................. ២១
២.១.១.២.ស្ថានភាពសេដ្ឋកិច្ច................................................................................................ ២១
២.១.១.៣. ប្រភពទឹក........................................................................................................ ២២
២.១.១.៤. ស្ថិតិប្រជាពលរដ្ឋក្នុងស្រុកស្អាង .............................................................................. ២២

២.១.២. ទីតាំងភូមិសាស្ត្រឃុំស្វាយប្រទាល ............................................................... ២៣
២.១.៣. ស្ថានភាពទូទៅនៃឃុំស្វាយប្រទាល ............................................................... ២៣
២.១.៤. ស្ថានភាពសេដ្ឋកិច្ច ............................................................... ២៥
២.១.៤.១. ស្ថានភាពមុខរបរប្រជាជនក្នុងឃុំស្វាយប្រទាល ............................................................... ២៥
២.១.៤.២. ស្ថានភាពលំនៅដ្ឋាន ............................................................... ២៦
២.១.៤.៣. ផ្នែកគមនាគមន៍ ............................................................... ២៦
២.១.៤.៤. ស្ថានភាពវិស័យកសិកម្ម ............................................................... ២៦
២.២. ស្ថានភាពផលិតកម្មដំណាំបន្លែ ............................................................... ២៧
២.២.១. លក្ខណៈបច្ចេកទេសដាំដុះ ............................................................... ២៧
២.២.១.១. ការរៀបចំដី ............................................................... ២៧
២.២.១.២. ការជ្រើសរើសពូជ ............................................................... ២៧
២.២.១.៣. ការដាំដុះ ............................................................... ២៨
២.២.១.៤. ការថែទាំ ............................................................... ២៨
២.២.២. រដូវដាំដុះបន្លែ ............................................................... ២៩
២.២.៣. ប្រភពទឹកស្រោចស្រព ............................................................... ៣០
២.២.៤. ការប្រមូលផល ............................................................... ៣០
២.២.៥. ប្រភពដើមទុន ............................................................... ៣០
២.២.៦. ស្ថានភាពទីផ្សារបន្លែ ............................................................... ៣១
២.២.៦.១.ទីផ្សារបន្លែ ............................................................... ៣១
២.២.៦.២. បណ្ដាញបែងចែកផលិតផលដំណាំបន្លែ ............................................................... ៣២
២.២.៦.៣. បញ្ហាទីផ្សារបន្លែរបស់កសិករក្នុងឃុំស្វាយប្រទាល ............................................................... ៣៣
២.២.៦.៤. ដំណោះស្រាយបញ្ហាទីផ្សារសម្រាប់កសិករ ............................................................... ៣៣

## ជំពូកទី ៣

## ការវិភាគទិន្នន័យ និងលទ្ធផលស្រាវជ្រាវ

៣.១. ទិន្នន័យប្រជាសាស្ត្រ ............................................................... ៣៤
៣.១.១. ទិន្នន័យមេគ្រួសារ ............................................................... ៣៤
៣.១.១.១. ភេទ ............................................................... ៣៤
៣.១.១.២. ក្រុមអាយុ ............................................................... ៣៥

៣.១.២. ចំនួនសមាជិកគ្រួសារ ..... ៣៦
៣.១.៣. កម្លាំងពលកម្មក្នុងគ្រួសារ ..... ៣៧
៣.២. ផ្ទៃដីសម្រាប់ដាំដុះដំណាំបន្លែ ..... ៣៨
៣.៣. ប្រភេទបន្លែ ..... ៣៨
៣.៤. ការវិភាគប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែ ..... ៣៩
៣.៤.១. ចំណាយសរុបជាមធ្យមទៅលើការដាំដុះដំណាំបន្លែ ..... ៣៩
៣.៤.២. ចំណូលជាមធ្យមទៅលើការដាំដុះដំណាំបន្លែ ..... ៤០
៣.៤.៣. ប្រាក់ចំណេញ ឬខាតជាមធ្យមពីការដាំដុះដំណាំបន្លែ ..... ៤០
៣.៤.៤.ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការដាំដុះដំណាំបន្លែ ..... ៤១
៣.៤.៤.១. ប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម ..... ៤១
៣.៤.៤.២. ប្រសិទ្ធិភាពកម្លាំងពលកម្ម ..... ៤២
៣.៤.៤.៣. ប្រសិទ្ធភាពដីធ្លី ..... ៤៣
៣.៤.៥. ការវិភាគចំណុចស្រង់ដើម ..... ៤៣
៣.៥. ការវិភាគ SWOT នៃដំណាំបន្លែ ..... ៤៤

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..... ៤៦
២. អនុសាសន៍ ..... ៤៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| ពាក្យអក្សរកាត់ | | ការពន្យល់ |
|---|---|---|
| % | : | ភាគរយ |
| ម² | : | ម៉ែត្រការេ |
| ហ.ត | : | ហិកតា |
| គ.ក | : | គីឡូក្រាម |
| P | : | Price |
| Q | : | Quantity |
| TC | : | Total Cost |
| TR | : | Total Revenue |
| SWOT | : | Strength Weakness Opportunity Treats |

# បញ្ជីតារាង

តារាងទី២.១ ស្ថិតិប្រជាជនក្នុងស្រុកស្អាងឆ្នាំ២០០៨ ........................................................................ ២២
តារាងទី២.២. ចំនួនភូមិ និងផ្ទៃដីគិជាហ.ត........................................................................................៣៤
តារាងទី២.៣. ស្ថិតិប្រជាពលរដ្ឋក្នុងឃុំ ប្រចាំឆ្នាំ២០១៧...................................................................២៥
តារាងទី៣.១៖ ការបង្ហាញពីភេទរបស់កសិករដែលជាមេគ្រួសារ ........................................................... ៣៤
តារាងទី៣.២ ៖ ការបង្ហាញពីក្រុមអាយុរបស់កសិករដែលជាមេគ្រួសារ ................................................... ៣៥
តារាងទី៣.៣ ៖ ការបង្ហាញអំពីសមាជិកគ្រួសារកសិករ.......................................................................៣៧
តារាងទី៣.៤. ការបង្ហាញអំពីកម្លាំងពលកម្មក្នុងគ្រួសាររបស់កសិករ...................................................... ៣៨
តារាងទី៣.៥. ទំហំផ្ទៃដីដាំបន្លែជាមធ្យម.......................................................................................... ៣៨
តារាងទី៣.៦. ការចំណាយសរុបជាមធ្យមរបស់កសិករទៅលើការដាំដុះបន្លែ .......................................... ៣៩
តារាងទី៣.៧. ចំណូលសរុបជាមធ្យមរបស់ប្រជាកសិករដែលទទួលបានពីការដាំដុះបន្លែ
ក្នុងមួយវដ្តផលិតកម្ម.................................................................................................... ៤០

# បញ្ជីក្រាប

ក្រាបទី៣.១ ការបង្ហាញអំពីប្រភេទដំណាំរបស់កសិករ.......................................................................... ៣៩

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅក្នុងប្រទេសកម្ពុជា កំណើនប្រជាជនយ៉ាងឆាប់រហ័ស ជម្រុញឲ្យកម្ពុជាត្រូវខិតខំយ៉ាងខ្លាំងដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងស្របនឹងកំណើននេះ។

កសិករកម្ពុជាបានខិតខំរកគ្រប់មធ្យោបាយ និងត្រូវជំនះឧបសគ្គជាច្រើន ក្នុងទិសដៅបង្កើនផលិតផលម្ហូបអាហារ ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងស្រុក ក៏ដូចជាសម្រាប់នាំចេញផងដែរ។

ម្ហូបអាហារទាក់ទងនឹងដំណាំជាច្រើនប្រភេទដូចជា៖ ស្រូវ ដំឡូង ពោត បន្លែគ្រប់ប្រភេទ ។ល។ បន្លែស្ថិតនៅក្នុងចំណោមម្ហូបអាហារយ៉ាងសំខាន់ដែលប្រជាជន ធ្វើការដាំដុះនៅតំបន់មួយចំនួននៃប្រទេស ដោយតំបន់ខ្លះប្រជុំទៅដោយផ្ទៃដីដាំដុះបន្លែ ខណៈដែលតំបន់ខ្លះទៀតមានការដាំដុះបន្លែបន្តិចបន្តួចតែប៉ុណ្ណោះ។ បច្ចេកទេសកសិកម្មទំនើបៗ រួមផ្សំនឹងបច្ចេកទេសកសិកម្មតាមបែបប្រពៃណី ត្រូវបានប្រើប្រាស់ដោយកសិករដាំដុះបន្លែនៅកម្ពុជា ក្នុងគោលបំណងបម្រើឲ្យសេចក្តីត្រូវការរបស់ប្រជាជន។ ពីមុនបន្លែ ច្រើនដាំដុះសម្រាប់តែផ្គត់ផ្គង់សេចក្តីត្រូវការក្នុងគ្រួសារ ឬលក់ដូរបន្តិចបន្តួច ប៉ុន្តែបច្ចុប្បន្ននេះ សភាពការណ៍សេដ្ឋកិច្ចមានការប្រែប្រួល ចំនួនប្រជាជនមានការកើនឡើង តម្រូវការបន្លែសម្រាប់ផ្សំជាអាហារក៏មានកម្រិតកាន់តែខ្ពស់ ការដាំបន្លែក៏មានការរីកវឌ្ឍច្រើន គឺមានការដាំដុះលើផ្ទៃដីធំធេងសម្រាប់លក់ដូរនៅតាមទីផ្សារធំៗ។

## ២. ចំណោទបញ្ហា

ដំណាំបន្លែ ត្រូវបានក្លាយជាផ្នែកមួយដ៏សំខាន់សម្រាប់បំពេញតម្រូវការម្ហូបអាហាររបស់ប្រជាជនកម្ពុជា ព្រមទាំងជាផ្នែកមួយដែលជួយជំរុញឲ្យសេដ្ឋកិច្ចមានការរីកចម្រើន។ ក្នុងនោះ ដំណាំបន្លែនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ត្រូវបានលើកមកសិក្សា តើការដាំដុះបន្លែអាចជួយលើកកម្ពស់ជីវភាពគ្រួសារកសិករដល់កម្រិតណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការកំណត់នូវគោលបំណងឲ្យបានច្បាស់លាស់ គឺមានសារៈសំខាន់ណាស់ក្នុងការសិក្សា ដើម្បីឲ្យដំណើរការនៃការសិក្សាសម្រេចបានជោគជ័យ។ គោលបំណងនេះរួមមាន៖

- ស្វែងយល់អំពីស្ថានភាពដាំដុះបន្លែក្នុងឃុំស្វាយប្រទាល
- សិក្សាពីលក្ខណៈបច្ចេកទេសក្នុងការដាំដុះបន្លែ
- សិក្សាពីសារៈសំខាន់នៃដំណាំបន្លែ

- សិក្សាពីបញ្ហាប្រឈម និងដំណោះស្រាយនានាដែលកើតមានជុំវិញការដាំដុះបន្លែ
- វិភាគពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែ
- អនុសាសន៍ចាំបាច់ ដើម្បីជំរុញផលិតភាពដំណាំបន្លែ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សានេះ ផ្តោតសំខាន់ទៅលើបន្លែសំខាន់ៗចំនួន៤ប្រភេទរួមមាន៖ ស្ពៃតឿ ស្ពៃចង្កឹះ ស្ពៃខ្មៅ និងស្ពៃក្រញ៉ាញ់ ដែលជាដំណាំយុទ្ធសាស្ត្ររបស់ប្រជាជនក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល។ ការសិក្សានេះ ចាប់ផ្តើមចុះធ្វើការស្រាវជ្រាវចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧ ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

- ទទួលបានចំណេះដឹង និងបទពិសោធន៍ក្នុងការសិក្សាស្រាវជ្រាវ ចងក្រងជាឯកសារ
- ទទួលបានបទពិសោធន៍ក្នុងការទំនាក់ទំនងក្នុងសង្គម
- អាចស្វែងយល់ពីការប្រកបរបរដាំបន្លែ និងជីវភាពរស់នៅរបស់ប្រជាជនដែលប្រកបរបរនេះ
- ជាឯកសារជំនួយក្នុងការសិក្សាស្វែងយល់ និងសម្រាប់ការសិក្សាស្រាវជ្រាវបន្ត។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយដែលទទួលបានប្រសិទ្ធភាព និងលទ្ធផលល្អ លុះណាតែការជ្រើសរើសសំណាកបានល្អនៅក្នុងតំបន់សិក្សាស្រាវជ្រាវ និងមានលក្ខណៈច្បាស់លាស់ សម្រាប់បំពេញតម្រូវការប្រធានបទ។ ដោយហេតុថា ប្រជាជននៅឃុំស្វាយប្រទាលស្ទើតែ ៧០ ភាគរយប្រកបរបរដាំបន្លែ សម្រាប់ជាចំណូលក្នុងគ្រួសារ ទើបបានជាតំបន់នេះត្រូវបានជ្រើសរើសយកមកសិក្សាស្រាវជ្រាវ។

វិធីសាស្ត្រជ្រើសរើសសំណាក ដែលនឹងត្រូវបានយកមកគណនាសម្រាប់ការសិក្សាស្រាវជ្រាវនេះ គឺអនុវត្តតាមរូបមន្ត Yamane (១៩៦៧)

$$n = \frac{N}{1+N\,(e)2}$$

N: ចំនួនគ្រួសារសរុបក្នុងឃុំ

n: ចំនួនសំណាកសរុបក្នុងឃុំដែលត្រូវសម្ភាសន៍

១: ចំនួនថេរ

e: កម្រិតលម្អៀង សន្មតយក ២២%

(N = ៣,៥៤៩ គ្រួសារ, e = ២២%)

$$n = \frac{៣,៥៤៩}{១ + ៣,៥៤៩\ (០.២២)^{២}} = ២០\ គ្រួសារ$$

ដូចនេះ សំណាកសរុបដែលត្រូវសម្ភាសន៍មានចំនួន ២០ គ្រួសារ។

ប្រភពទិន្នន័យដែលត្រូការចាំបាច់ ដែលឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺរួមមានទិន្នន័យដែលមានស្រាប់ និងទិន្នន័យអង្កេត ដែលទទួលបានពីការចុះអង្កេត និងសម្ភាសន៍ជាមួយប្រជាកសិករនៅមូលដ្ឋាន ដោយប្រើប្រាស់កម្រងសំណួរ។

ទិន្នន័យដែលមានស្រាប់ ជាប្រភេទទិន្នន័យដែលទទួលបានមកពីឯកសារ របាយការណ៍ ឬព្រឹត្តិបត្រទាំងឡាយណា ដែលជាប់ពាក់ព័ន្ធជាមួយនឹងការស្រាវជ្រាវនេះ។ ទិន្នន័យនេះទទួលបានពីប្រភពដូចជា៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរកសិកម្មខេត្តកណ្តាល
- របាយការណ៍ស្តីពីស្ថានភាព ភូមិ និងឃុំដែលចុះសិក្សាស្រាវជ្រាវ។

ចំណែកឯទិន្នន័យចំបង គឺជាទិន្នន័យដែលសំខាន់សម្រាប់ការសិក្សាស្រាវជ្រាវ ហើយដែលទទួលបានពីការចុះអង្កេត និងសម្ភាសន៍ផ្ទាល់ជាមួយប្រជាកសិករមូលដ្ឋាន ដោយប្រើប្រាស់កម្រងសំណួរដែលមានជាទម្រង់បិទ និងទម្រង់បើកដែលបានធ្វើការសាកល្បង និងរៀបចំកែតម្រូវរួចជាស្រេច។

រាល់ទិន្នន័យដែលប្រមូលបានតាមរយៈការសម្ភាសន៍ និងទទួលបានពីស្ថាប័នពាក់ព័ន្ធ ត្រូវបានយកមកវិភាគតាមវិធីសាស្ត្រស្ថិតិពិពណ៌នា និងគណនារូបមន្តមួយចំនួន ដោយប្រើឧបករណ៍វិភាគ Excel និង SPSS program ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការចងក្រង និងរៀបចំសារណាបទនេះ ធ្វើឡើងដោយចែកជាបីជំពូកដូចខាងក្រោម៖

- **ជំពូកទី១ រំលឹកទ្រឹស្តី** : សិក្សាទៅលើទ្រឹស្តីកសិកម្មទូទៅ ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច ទ្រឹស្តីនិងកត្តាសំខាន់ៗដែលពាក់ព័ន្ធនឹងដំណាំបន្លែនៅកម្ពុជា និងទ្រឹស្តីពាក់ព័ន្ធនឹងការវិភាគប្រសិទ្ធភាពសេដ្ឋកិច្ច។

- **ជំពូកទី២ ស្ថានភាពដំណាំបន្លែក្នុងឃុំស្វាយប្រទាល** : សិក្សាស្ថានភាពទូទៅនៃតំបន់សិក្សាស្រាវជ្រាវ ព្រមទាំងទៅលើស្ថានភាពផលិតកម្មដំណាំបន្លែ និងការដាំដុះបន្លែរបស់ប្រជាជននៅក្នុងតំបន់នោះ។

- **ជំពូកទី៣ ការវិភាគទិន្នន័យ និងលទ្ធផលស្រាវជ្រាវ** : សិក្សាទៅលើទិន្នន័យប្រជា សាស្ត្រ ការវិភាគពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែក្នុងការលើកស្ទួយជីវភាពគ្រួសារក្នុងតំបន់នោះ និងស្វែងយល់ពីចំណូល ចំណាយ ជាមធ្យមពីការដាំដុះបន្លែក្នុងមួយវដ្តផលិតកម្ម ព្រមទាំងធ្វើការវិភាគ SWOT នៃដំណាំបន្លែផងដែរ។

- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍** : ធ្វើការសន្និដានរួមទៅលើការសិក្សាស្រាវជ្រាវ និងផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីកែលម្អ និងអភិវឌ្ឍដំណាំបន្លែក្នុងឃុំស្វាយប្រទាល ឲ្យកាន់តែមានភាពល្អប្រសើរ។

# ជំពូកទី១
# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ទ្រឹស្តីកសិកម្ម

### ១.១.១. និយមន័យកសិកម្ម

កសិកម្ម គឺជាពាក្យមួយដែលត្រូវបានបុគ្គលផ្សេងៗគ្នា ឬអ្នកប្រាជ្ញផ្សេងៗជាច្រើនរូបផ្តល់និយមន័យស្រដៀងៗគ្នា ទោះបីជាការសិក្សាស្រាវជ្រាវទាំងនោះ ត្រូវបានធ្វើឡើងនៅតាមតំបន់ផ្សេងៗគ្នាជាច្រើនកន្លែងក៏ដោយ។ ចំពោះនិយមន័យដែលគេនិយមយកមកធ្វើការបកស្រាយមានដូចជា៖

- កសិកម្ម គឺជាអំពើរបស់មនុស្សទៅលើមជ្ឈដ្ឋានធម្មជាតិ ដើម្បីទទួលបានមកវិញនូវផលិតផលដែលគេអាចប្រើប្រាស់បានដូចជា ម្ហូបអាហារ សម្លៀកបំពាក់ លំនៅឋាន ថ្នាំសច្ចូវ និងរបស់របរប្រើប្រាស់ជាច្រើនទៀត។ កសិកម្មមានរបៀបរៀបចំផលិតផលទៅតាមបច្ចេកទេសដែលគេប្រើប្រាស់ និងទៅតាមផលិតផលដែលគេផលិត ដែលក្នុងនោះមានកសិដ្ឋានចំរុះ ការបង្កបង្កើនផលប្រចាំឆ្នាំ ការចិញ្ចឹមសត្វ និងការដាំដំណាំដែលអាចឲ្យផលយូរឆ្នាំ[1]។
- កសិកម្ម គឺជាសិល្បៈ និងជាវិទ្យាសាស្ត្រនៃការដាំដុះ និងការចិញ្ចឹមសត្វដើម្បីធ្វើជាអាហារ និងដើម្បីបំពេញតម្រូវការផ្សេងៗរបស់មនុស្ស ឬដើម្បីជាប្រយោជន៍ផ្នែកសេដ្ឋកិច្ចផ្សេងៗ។ អត្ថន័យនេះចង់បង្ហាញថា មនុស្សបានប្រើប្រាស់ឯកទេស និងជំនាញរបស់ខ្លួនហើយធ្វើសកម្មភាពផ្សេងៗទៅលើធម្មជាតិដើម្បីបម្រើឲ្យផលប្រយោជន៍ និងដើម្បីបំពេញនូវតម្រូវការយ៉ាងច្រើនឥតគណនារបស់ខ្លួនទាំងនៅក្នុងពេលបច្ចុប្បន្ន និងពេលអនាគត[2]។

ជារួមមក ការផ្តល់និយមន័យកសិកម្មខាងលើ សុទ្ធតែបង្ហាញអំពីសកម្មភាពរបស់មនុស្សទៅលើមជ្ឈដ្ឋានធម្មជាតិដោយមានទាំងការដាំដុះ និងមានការចិញ្ចឹមសត្វដើម្បីទទួលបានមកវិញនូវអត្ថប្រយោជន៍ផ្នែកស្បៀងអាហារ និងផ្នែកសេដ្ឋកិច្ច។

[1] ឈុន ពហុ, "សេដ្ឋកិច្ចកសិកម្ម", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ)

[2] វចនានុក្រម oxford, និយមន័យកសិកម្ម (២ កញ្ញា ២០១០)

### **១.១.២. ប្រវត្តិកសិកម្ម**

ប្រវត្តិកសិកម្មត្រូវបានគេយល់ឃើញផ្សេងៗគ្នា ខាងក្រោមនេះគឺជាការបកស្រាយមួយបែបស្តីពីប្រវត្តិកសិកម្ម។

កាលដើមឡើយមនុស្សរស់នៅប្រមូលផ្តុំគ្នាបែបជាកុលសម្ព័ន្ធ និងតែងតែចេញទៅរកបេះផ្លែឈើ បន្លែបង្កា និងបរបាញ់សត្វនៅក្នុងព្រៃដើម្បីធ្វើជាម្ហូបអាហារជារៀងរាល់ថ្ងៃ។ ហើយពួកគេតែងតែផ្លាស់ប្តូរទីលំនៅពីតំបន់មួយ ទៅតំបន់មួយទៀតជាបន្តបន្ទាប់ នៅពេលដែលពួកគេយល់ថាតំបន់ដែលគេរស់នៅលែងមានម្ហូបអាហារសម្រាប់ពួកគេទៀតហើយ។ ដោយបំលាស់ប្តូរលំនៅបែបនេះជារឿយៗ បានធ្វើឲ្យពួកគេលំបាកក្នុងការស្វែងរកទីកន្លែងដែលសំបូរម្ហូបអាហារសម្រាប់ចិញ្ចឹមជីវិត ពួកកុលសម្ព័ន្ធទាំងនោះក៏មានគំនិតសន្សំសំចៃ ដោយរក្សាទុកបន្លែ ផ្លែឈើដែលនៅស្រស់ៗ ឬរក្សាសត្វដែលនៅរស់ដើម្បីធ្វើជាម្ហូបអាហារទៅថ្ងៃក្រោយទៀត។ សត្វដែលរក្សាទុកនោះ ពួកគេចេះតែដាក់ចំណីឲ្យស៊ីរហូតលូតលាស់ ធំធាត់ជាលំដាប់។ រីឯកាកសំណល់ សំបក និងគ្រាប់ផ្លែឈើបន្លែបង្កាដែលពួកគេចេះតែបោះចោលគរលើគ្នានោះ ក៏ក្លាយទៅជាដីជី និងដុះជាដើមរុក្ខជាតិថ្មីៗជាច្រើន ដូចគ្នាទៅនឹងអ្វីដែលពួកគេធ្លាប់បានបរិភោគ។ នៅពេលឃើញដូចនេះ ក្រុមកុលសម្ព័ន្ធទាំងនោះ ក៏ចាប់ផ្តើមចេះថែរក្សា និងដាំដំណាំ ព្រមទាំងចាប់សត្វក្នុងព្រៃមកផ្សាំងដើម្បីចិញ្ចឹមយកធ្វើជាម្ហូបអាហារ និងដើម្បីដោះដូរជាមួយរបស់របរផ្សេងៗទៀត។ លុះក្រោយមក សត្វដែលគេចិញ្ចឹមនោះចេះតែដើរពាសវាលពាសកាល ស៊ីនិងបំផ្លាញដំណាំដែលពួកគេបានដាំ ពួកគេក៏ចាប់ផ្តើមកកើតគំនិតថ្មីមួយទៀតគឺ ធ្វើរបងព័ទ្ធជុំវិញដំណាំដែលបានដាំ និងធ្វើទ្រុងសម្រាប់ដាក់សត្វចិញ្ចឹមទាំងនោះ។ ចាប់ពីពេលនោះមក គេក៏នាំគ្នាហៅទង្វើបែបនេះថាជា *"កសិកម្ម"* តៗគ្នារហូតមក។[3]

### **១.១.៣. កសិកម្មកម្ពុជា**[4]

វិស័យកសិកម្មគឺជាមូលដ្ឋានគ្រឹះក្នុងការបង្កើនប្រាក់ចំណូលនៅតំបន់ជនបទ ជាពិសេស ក្នុងចំណោមប្រជាជនក្រីក្រ។ វិស័យនេះរួមចំណែកប្រមាណជា ២៩% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) នៅឆ្នាំ២០០៥។ ដោយសារតែនៅកម្ពុជា ប្រជាជន ៨៥% រស់នៅតំបន់ជនបទ ហើយក្នុងនោះប្រមាណ ៦០% កំពុងប្រកបរក្នុងវិស័យកសិកម្ម ហើយម្យ៉ាងទៀត មេគ្រួសារនៃគ្រួសារក្រីក្រជា

---

3 ឈុន ពហុ, "សេដ្ឋកិច្ចកសិកម្ម", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ)

4 បណ្ឌិត ហង់ ជួន ណារ៉ុន, សេដ្ឋកិច្ចកម្ពុជា, ឆ្នាំ២០១៥, ទំព័រ១៧៧

កសិករមានរហូតដល់ ៧៥% ដូចនេះហើយ ការអភិវឌ្ឍវិស័យនេះមានសារសំខាន់ខ្លាំងណាស់ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចជនបទ។

ការអភិវឌ្ឍវិស័យកសិកម្ម គឺជាចំណុចស្នូលនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍ជនបទ ធានាឲ្យបាននូវសន្តិសុខស្បៀង និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ទោះបីជាផលិតកម្មសរុបពីវិស័យកសិកម្ម នេសាទ និងព្រៃឈើបានកើនឡើងក្នុងឆ្នាំ ១៩៩៨-២០០៣ ចំណែកនៃវិស័យនេះក្នុងផ.ស.ស បានធ្លាក់ចុះពី ៤៣.៧% ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹមតែ ២៩.៦% ក្នុងឆ្នាំ២០០៧ មូលហេតុចំបងបណ្តាលមកពីកំណើនដ៏ឆាប់រហ័សនៃវិស័យឧស្សាហកម្ម នៅក្នុងអំឡុងពេលនោះ។ កំណើនវិស័យកសិកម្មមានល្បឿនយឺតជាងកំណើនក្នុងវិស័យឧស្សហយកម្ម និងវិស័យសេវា។

ផលិតផលកសិកម្មរបស់កសិករកម្ពុជាដែលផលិតបានត្រូវប្រឈមនឹងបញ្ហាដូចជា ទីផ្សារក្នុងស្រុកតូចចង្អៀត គុណភាពមិនអាចនាំចេញបាន និងតម្រូវការផលិតផលកសិកម្មក្នុងតំបន់មិនទាន់មាន។ ជាងនេះទៅទៀត កសិផលក៏ប្រឈមទៅនឹងការប្រកួតប្រជែងដ៏ខ្លាំង ជាមួយនឹងប្រទេសនាំចូល ព្រមជាមួយនឹងគោលនយោបាយគាំពារនិយមរបស់ប្រទេសទាំងនោះ។

បន្ទាប់ពីមានកំណើនខ្ពស់ក្នុងឆ្នាំ១៩៩៤-១៩៩៨មក វិស័យដំណាំបានធ្លាក់ចុះយ៉ាងគំហុកពោលគឺកំណើនមធ្យមប្រចាំឆ្នាំតែ ០.៤% ប៉ុណ្ណោះ ពីឆ្នាំ១៩៩៩ដល់ឆ្នាំ២០០២ ដោយសារតែទឹកជំនន់ និងឱនភាពនៃរបាយទឹកភ្លៀង។

កម្ពុជាមានផ្ទៃដីដាំដុះ និងដំណាំអចិន្ត្រៃយ៍ទំហំ ៣.៨លានហិចតា ក្នុងនោះ ១.៥លានហិចតាជាតំបន់ដាំដំណាំអចិន្ត្រីយ៍ ព្រមទាំងមានផ្ទៃដី ១២លានហិចតាជាដីព្រៃ និងព្រៃឈើ។ តំបន់ដាំដុះកំពុងកើនឡើងជាប្រចាំ។

វិស័យកសិកម្មនៅកម្ពុជា ភាគច្រើនគ្របដណ្តប់ដោយកសិករខ្នាតតូច ការធ្វើកសិកម្មនៅលើផ្ទៃដីធំមិនទាន់មានច្រើននៅឡើយ។ កសិករភាគច្រើនលើសលប់ជាម្ចាស់ដីស្រែផ្ទាល់ ខណៈដែលគ្រួសារកសិករគ្មានដីធ្លីមានប្រមាណ ១៣% ទៅ១៥% នៃគ្រួសារកសិករសរុប។

### ១.១.៤. បច្ចេកទេសហាយដ្រូផូនិចជាផ្នែកមួយនៃទំនើបកម្មកសិកម្មកម្ពុជា

ក្រោយពីមានការកើនឡើងខាងកសិកម្ម(បដិវត្តបៃតង និងបដិវត្តជីវបច្ចេកវិទ្យា) អ្នកសិក្សាក្រោយៗបានស្រាវជ្រាវ និងកែច្នៃ ព្រមទាំងបច្ចកវិទ្យាថ្មី គំនិតថ្មី និងបច្ចេកទេសថ្មីៗដែលធ្វើឲ្យវិស័យកសិកម្មមានការរីកចម្រើន។ បច្ចេកទេសហាយដ្រូផូនិចនេះ ជាសមិទ្ធិផលមួយដែលបានរួមផ្សំគ្នារវាងបដិវត្តបៃតង និងបដិវត្តបច្ចេកវិទ្យា។ បច្ចេកទេសហាយដ្រូផូនិច (Hydroponic) ត្រូវបានគេ

យកមកអនុវត្តនៅប្រទេសកម្ពុជាឆ្នាំ២០១១ ហើយប្រជាជនកម្ពុជាបានឲ្យឈ្មោះមួយទៀតថា *"បច្ចេកទេសដាំដំណាំលើទឹក"* ហើយដំណាំដែលចេញពីបច្ចេកទេសនេះ ត្រូវបានអតិថិជនទទួលស្គាល់វាមានរសជាតិឆ្ងាញ់និងមានផលប្រយោជន៍ដល់សុខភាព។ ការដាំដំណាំបែបនេះ មានបច្ចេកទេសងាយៗ និងមានរចនាសម្ព័ន្ធត្រឹមត្រូវ ងាយស្រួលក្នុងការគ្រប់គ្រង និងផ្តល់ទិន្នផលលើសពីការដាំបែបធម្មតា។ នៅពេលបច្ចុប្បន្ន បច្ចេកទេសហាយដ្រូផូនិច ត្រូវបានប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមខេត្តមួយចំនួនបានយកមកអនុវត្ត និងបានលក់ទៅកាន់ទីផ្សារពិសេសដូចជាសណ្ឋាគារ ហាងអាហារបរទេស និងគ្រួសារដែលមានលទ្ធភាពទិញ។ ការដាំបន្លែបែបនេះមិនត្រូវការដី មិនប្រកាន់ទីតាំងច្រើនឡើយ ឲ្យតែមានពន្លឺចូលដល់ រីឯនៅតំបន់ទីក្រុងវិញ ក៏អាចដាំបន្លែបាន អាចដាំនៅលើដំបូលផ្ទះ ឬអាគារ តាមសួនច្បារជាដើម។

បច្ចេកទេសហាយដ្រូផូនិចនេះ គឺជាផ្នែកមួយនៃទំនើបកម្មកសិកម្មចំពោះបច្ចេកទេសដាំដុះបន្លែ ហើយបច្ចេកទេសនេះត្រូវបានបរទេសទទួលស្គាល់ពីគុណភាព និងសុវត្ថិភាពដោយសារតែវាមិនត្រូវបានប្រើប្រាស់សារធាតុគីមីដែលប៉ះពាល់ដល់សុខភាព ដូចជាថ្នាំសម្លាប់សត្វល្អិត ថ្នាំជំនួយ និងថ្នាំមួយចំនួនទៀត។ បច្ចេកទេសនេះអាចនិយាយបានថាជាបច្ចេកទេសថ្មីមួយដែលមានទំនើបកម្មបំផុតក្នុងប្រទេសកម្ពុជា ដោយសារបច្ចេកទេសនេះមានលក្ខណៈជាប្រព័ន្ធ ទាំងការដាំដុះ ឬការស្រោចស្រពដំណាំ និងមានប្រព័ន្ធទឹកការពារកំដៅទៀតផង។ ការអនុវត្តបច្ចេកទេសនេះមិនមែនជាទំនើបកម្មគ្រឿងយន្តនោះទេតែជាទំនើបកម្មខាងបច្ចេកវិទ្យា និងបច្ចេកទេសក្នុងការដាំដុះ ត្រូវបានប្រើប្រាស់អគ្គិសនីជាប្រចាំ។ [5]

## ១.២. ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច

### ១.២.១. និយមន័យនៃការអភិវឌ្ឍ

ពាក្យថា អភិវឌ្ឍន៍ (ឬការអភិវឌ្ឍ) ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ទាំងផ្នែកនយោបាយ ផ្នែកសង្គម ផ្នែកនីតិសាស្ត្រ ផ្នែករចនាសម្ព័ន្ធគ្រប់គ្រង ផ្នែកបច្ចេកវិទ្យា ផ្នែកបរិស្ថាន ផ្នែកសាសនា ផ្នែកសិល្បៈនិងវប្បធម៌ និងជាពិសេសនៅក្នុងផ្នែកសេដ្ឋកិច្ច។

ពាក្យ អភិវឌ្ឍន៍ មានការឲ្យនិយមន័យខុសៗគ្នាជាច្រើន ក្នុងចំណោមការឲ្យនិយមន័យទាំងនោះរួមមាន៖

តាមទស្សនរបស់លោក WALT W. ROSTOW បានបង្ហាញថា អភិវឌ្ឍន៍ គឺជាប់ទាក់ទងនឹង

[5] ដំណាំបន្លែលើទឹក, រៀបរៀងដោយកញ្ញា ឥម សុផារិទ្ធ កម្មវិធីទូរទស្សន៍ជាតិនៃកម្ពុជា ឆ្នាំ២០១៣

បំលាស់ប្តូរពីជីវិតរស់នៅបែបប្រពៃណី ទៅកាន់ជីវិតរស់នៅមួយបែបទំនើប មានរបៀបរៀបរយល្អ និងអាចទស្សន៍ទាយជាមុននូវលទ្ធផលដែលគេនឹងទទួលបាននៅពេលអនាគត។ លើសពីនេះទៅទៀត លោកក៏បានលើកឡើងផងដែរថា ការអភិវឌ្ឍ ទាក់ទងនឹងការផ្លាស់ប្តូរផលិតកម្មកសិកម្មបែបប្រពៃណី ទៅកាន់ផលិតកម្មដែលមានលក្ខណៈវិទ្យាសាស្ត្រ ដែលជាទូទៅត្រូវបានគេយកចិត្តទុកដាក់ខ្លាំងទៅលើផ្នែកឧស្សាហកម្ម។ [6]

អភិវឌ្ឍន៍ គឺជាចលនាវិវត្តពីស្ថានភាពមួយទៅស្ថានភាពមួយទៀតដែលប្រសើរជាងមុន។[7]

អភិវឌ្ឍ គឺជាដំណើរការនៃការធ្វើឲ្យប្រសើរឡើងនូវគុណតម្លៃនៃការរស់នៅ និងសមត្ថភាពរបស់មនុស្ស តាមរយៈការបង្កើននូវកម្រិតជីវភាពរស់នៅ ភាពជឿជាក់លើសមត្ថភាពនិងតម្លៃ និងសេរីភាពរបស់មនុស្ស។ [8]

### ១.២.២. គោលបំណងនៃការអភិវឌ្ឍ

អភិវឌ្ឍន៍ គឺជាដំណើរនៃការធ្វើឲ្យប្រសើរឡើងខាងគុណភាពនៃការរស់នៅរបស់មនុស្សទាំងអស់ដែលបង្ហាញតាមលក្ខខណ្ឌបីយ៉ាងគឺៈ

ក. ការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាជន ដូចជាកម្រិតប្រាក់ចំណូល និងការប្រើប្រាស់របស់ប្រជាជនកើនឡើងដោយឆ្លងតាមដំណើរនៃការទាក់ទងនៃសេដ្ឋកិច្ច។

ខ. ការបង្កើតលក្ខខណ្ឌ ដែលនាំឲ្យមានការគោរពខ្លួនឯងរបស់មនុស្សជាតិដោយឆ្លងតាមរយៈការស្ថាបនាស្ថាប័នសង្គម ស្ថាប័ននយោបាយ និងស្ថាប័នសេដ្ឋកិច្ច។

គ. ការកើនឡើងនៃសេរីភាពក្នុងការប្រើប្រាស់មានទំហំកាន់តែធំដូចជា ប្រជាជនមានសិទ្ធិក្នុងការជ្រើសរើស ការប្រើប្រាស់ទំនិញ និងសេវាជាដើម។

## ១.៣. និយមន័យបន្លែ

និយមន័យបន្លែ ត្រូវបានគេកំណត់ខុសៗគ្នា ដោយសារផ្នែកជាច្រើននៃបន្លែត្រូវបានប្រើប្រាស់ជាអាហារទូទាំងពិភពលោក។ ផ្នែកទាំងនោះរួមមានៈ មើម ឬស ដើម ស្លឹក ផ្កា និងគ្រាប់។

បន្លែ គឺជាផ្នែកមួយចំនួននៃរុក្ខជាតិដែលត្រូវបានប្រើប្រាស់ដោយមនុស្សគ្រប់គ្នាដើម្បីធ្វើជា

---

[6] បោង អង្គារ៉ា, ការគ្រប់គ្រងការអភិវឌ្ឍ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ)

[7] យ៉ែម សំបូរ, "សេដ្ឋកិច្ចអភិវឌ្ឍន៍", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ)

[8] បណ្ឌិត ឌុយ ចាន់ឌីណា, Economic Development, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ)

ម្ហូបអាហារដែលជាផ្នែកមួយនៃអាហារប្រចាំថ្ងៃ។ [9]

បន្លែ គឺជាផ្នែករុក្ខជាតិដែលគេបរិភោគផ្សំជាមួយអាហារមូលដ្ឋាន[10]។ ផលិតផលដំណាំមួយចំនួនត្រូវបានគេប្រើប្រាស់ឲ្យទៅជាបន្លែ ដែលមានដូចជា៖ ដំឡូងមី ដំឡូងជ្វា សណ្តែកបាយ ពោត ។ល។

## ១.៤. សារៈសំខាន់នៃការដាំដុះបន្លែ [11]

បន្លែជាដំណាំដែលមានទំនាក់ទំនងនឹងការរស់នៅរបស់មនុស្សយើង ទាំងផ្នែកម្ហូបអាហារក៏ដូចជាផ្នែកសេដ្ឋកិច្ច។ បន្លែមានពីរប្រភេទគឺ:

១. បន្លែដែលដុះដោយធម្មជាតិ: បន្លែប្រភេទនេះភាគច្រើនមានតម្លៃថោក ហើយក៏ភាគច្រើនដែរ ដែលសំបូរទៅដោយសារធាតុចិញ្ចឹម។

២. បន្លែដែលប្រជាកសិករយើងដាំដុះ ហើយដែលត្រូវបានថែទាំយ៉ាងប្រុងប្រយ័ត្ន។

### ១.៤.១. សារៈសំខាន់ផ្នែកម្ហូបអាហារ

បន្លែជាដំណាំ ដែលមានលក្ខណៈចាំបាច់សម្រាប់សុខភាពរបស់មនុស្ស ព្រមទាំងអាចចាត់ចូលជាអាហារលេខ ១ បើគិតអំពីរូបធាតុចិញ្ចឹម។ បន្លែសំបូរទៅដោយរូបធាតុចិញ្ចឹមរួមមាន៖ ប្រូតេអ៊ីន គ្លុយស៊ីត ជាតិប្រេងពិសេស រូបធាតុខនិជ ព្រមទាំងជីវជាតិអា បេ សេ ជាដើម។ល។

រូបធាតុចិញ្ចឹមទាំងនេះ អាចទ្រទ្រង់រូបរាងកាយមនុស្សយើងឲ្យរស់រានមានជីវិត មានកម្លាំងពលំបរិបូណ៌ ព្រមទាំងប្រាជ្ញាស្មារតីសម្រាប់អនុវត្តការងារផ្សេងៗបាន។ យើងមិនអាចរក្សាសុខភាពបានល្អដោយគ្រាន់តែបរិភោគបាយ ឬសាច់ដោយយគ្មានបន្លែបានឡើយ។ បន្លែមានច្រើនប្រភេទ ឯការប្រើប្រាស់ជូនកាលមានលក្ខណៈដូចគ្នា ជូនកាលក៏ផ្លាស់ប្តូរទៅតាមរបៀបផ្សេងៗគ្នាដែរ។ ក្នុងករណីខ្លះ គេបរិភោគបន្លែនៅពេលស្រស់ ឆៅ ឬជូនកាលចម្អិនទៅជាសំឡក៏បាន។ ការបរិភោគបន្លែមិនបានគ្រប់គ្រាន់អាចបណ្តាលឲ្យមានជំងឺខ្វះជីវជាតិ ដែលជាមូលហេតុធ្វើឲ្យជំងឺដទៃទៀតងាយរាតត្បាតរាងកាយ។

ជីវជាតិសំខាន់សំខាន់ និងសារៈប្រយោជន៍នៃជីវជាតិទាំងនោះរួមមាន៖

- ជីវជាតិ អា ៖ អាចធ្វើឲ្យភ្នែកភ្លឺល្អ មើលឃើញច្បាស់។ កង្វះជីវជាតិ អា បណ្តាលឲ្យភ្នែកឧស្សាហ៍កើតជំងឺ មានជំងឺខ្វាក់មាន់ជាដើម។ ចំពោះកុមារ ការខ្វះជីវជាតិ អា បើស្ថិតក្នុង

[9] Wikipedia.org

[10] បណ្ឌិត ប្រិន រ៉ូវែល និង តាត់ អេងឡាយ, ១៩៩២, ដំណាំបន្លែនៅកម្ពុជា

[11] បណ្ឌិត ប្រិន រ៉ូវែល និង តាត់ អេងឡាយ, ១៩៩២, ដំណាំបន្លែនៅកម្ពុជា

លក្ខណៈធ្ងន់ធ្ងរ អាចធ្វើឲ្យគេងងឹតភ្នែកតែម្តង។ ប្រភពដ៏ល្អបំផុតសម្រាប់ជីវជាតិ អា គឺស្លឹកបន្លែពណ៌បៃតង ផ្លែឈើដែលមានពណ៌លឿង ដំឡូងជ្វាពណ៌លឿង ។ល។

- ជីវជាតិ បេ ៖ ស្បែក ភ្នែក សរសៃប្រសាទ និងឈាមត្រូវការជីវជាតិ បេ។ ការខ្វះជីវជាតិនេះ អាចបណ្តាលឲ្យមានការខ្វះឈាម ខ្សោយកម្លាំង ស្បែកស្ងួតក្រៀម ហើមខ្លួន ព្រមទាំងពុំសូវមានប្រាជ្ញា ស្មារតីល្អផងដែរ។ ជីវជាតិ បេ មាននៅក្នុងស្លឹកបន្លែ។
- ជីវជាតិ សេ ៖ ជួយក្នុងការការពារជំងឺ ជួយឲ្យការមុត ឬរបួសផ្សេងៗឆាប់ជាសះស្បើយ និងជួយឲ្យអញ្ចាញធ្មេញល្អ។ ប្រភពដ៏ល្អសម្រាប់ជីវជាតិ សេ គឺបន្លែយកស្លឹក ផ្លែត្របែក ល្ហុង ក្រូចពោធិ៍សាត់ ក្រូចថ្លុង ក្រូចឆ្មារ ។ល។

ការបរិភោគបន្លែឲ្យបានគ្រប់គ្រាន់ និងឲ្យបានទៀងទាត់ អាចធ្វើឲ្យសុខភាពមានលក្ខណៈល្អប្រសើរ។ ក្រៅពីនេះ បន្លែអាចប្រើជាគ្រឿងសម្រាប់ជួយលើកកម្ពស់គុណភាព អាហារខ្លះទៀតផង។

### ១.៤.២. សារៈសំខាន់ផ្នែកសេដ្ឋកិច្ច

ក្រៅពីការដាំដុះសម្រាប់ផ្គត់ផ្គង់គ្រួសារ បន្លែដែលនៅសេសសល់អាចយកទៅលក់នៅតាមទីផ្សារតូចធំដែលអាចផ្តល់ប្រាក់កាសតិច ឬច្រើនទៅតាមបរិមាណក៏ដូចជាតម្លៃនៃផលិតផលបន្លែ។ នៅប្រទេសកម្ពុជា ប្រជាជនមួយចំនួនមានមុខរបរជាអ្នកដាំបន្លែតែម្តង ពិសេសកសិករដែលស្ថិតនៅជាយក្រុង ឬតាមតំបន់មាត់ទន្លេ។ ពួកគាត់មានបទពិសោធន៍ច្រើនខាងដាំបន្លែ។ ប្រសិនបើមធ្យោបាយផលិតមានគ្រប់គ្រាន់ផងនោះ ពួកគាត់អាចទទួលបានកម្រៃយ៉ាងច្រើន និងដែលអាចធ្វើឲ្យជីវភាពរស់នៅរបស់ពួកគាត់បានធូរធារទៀតផង។ និយាយរួម អ្នកដាំបន្លែអាចរកប្រាក់ចំណូលបានប្រសើរជាងអ្នកដាំដុះដំណាំផ្សេងៗទៀត។

ម្យ៉ាងទៀត ការដាំបន្លែតាមគ្រួសារ អាចកាត់បន្ថយប្រាក់កាសសម្រាប់ទិញបន្លែពីគេ និងអាចមានបន្លែស្រស់ៗថ្មីៗសម្រាប់បរិភោគទៀតផង។

នៅក្នុងប្រទេសជឿនលឿន ក្រៅពីដាំដុះជាលក្ខណៈគ្រួសារ គេបានដាំនៅលើផ្ទៃដីធំៗ រាប់សិបហិកតា ប្រើដោយគ្រឿងយន្តទំនើបៗ បច្ចេកទេសទំនើបៗ ដូចជាការបង្កាត់ពូជថ្មី ការដាំរបៀបសិប្បនិម្មិត ការអនុវត្តប្រពលវប្បកម្ម ការប្រើប្រាស់ផលិតផលកសិកម្មនៅក្នុងរោងចក្រឧស្សាហកម្ម ការដឹកជញ្ជូនតាមនាវា ឬតាមរថភ្លើងពីតំបន់មួយទៅតំបន់មួយ ឬពីប្រទេសមួយ ទៅប្រទេសមួយទៀតបានយ៉ាងឆាប់រហ័ស។

មធ្យោបាយខាងលើនេះ អាចរកបានប្រាក់ចំណូលយ៉ាងច្រើនសម្រាប់សេដ្ឋកិច្ចគ្រួសារ ឬសេដ្ឋកិច្ចជាតិ។

## ១.៥.កត្តាសំខាន់ៗទាក់ទងនឹងការដាំដុះបន្លែ [12]

កត្តាសំខាន់ៗដែលទាក់ទងនឹងការដាំដុះបន្លែគឺ ធាតុអាកាស ទឹក ដី និងជី។

### ១.៥.១. កត្តាធាតុអាកាស

ប្រភេទឬពូជបន្លែនីមួយៗ ត្រូវការលក្ខខណ្ឌបរិកាសជុំវិញប្លែកៗគ្នា។ ធាតុអាកាសជាកត្តាមួយយ៉ាងសំខាន់ក្នុងចំណោមកត្តាសំខាន់ៗដទៃទៀត ដែលកំណត់លទ្ធភាពក្នុងការដាំដុះបន្លែ។ ដោយហេតុនេះហើយ ទើបយើងត្រូវដឹងជាចាំបាច់នូវប្រភេទដំណាំ និងតម្រូវការរបស់វាជាមុនសិនមុននឹងធ្វើការផលិត។

#### ១.៥.១.១. សីតុណ្ហភាព

សីតុណ្ហភាពមានឥទ្ធិពលខ្លាំងទៅលើដំណុះគ្រាប់ និងការលូតលាស់របស់បន្លែ។ ធាតុអាកាសត្រជាក់ខ្លាំង ឬក្តៅខ្លាំងមិនអំណោយផលឲ្យគ្រាប់ដុះបានល្អឡើយ។ សីតុណ្ហភាពដែលសមស្របផ្លាស់ប្តូរទៅតាមប្រភេទបន្លែនិងពូជនីមួយៗ។ កត្តាសីតុណ្ហភាព អាចធ្វើឲ្យគ្រាប់ដុះលឿនឬយឺតខ្លាំងឬខ្សោយ ឬមិនដុះតែម្តង។

នៅប្រទេសកម្ពុជានាចុងរដូវប្រាំង សីតុណ្ហភាពក្តៅខ្លាំង ហើយស្ថិតនៅជាប់យូរព្រមទាំងធ្វើឲ្យដំណាំបន្លែដុះលូតលាស់យឺត ដើមមិនសូវធំដូចធម្មតា និងទាមទារការស្រោចទឹកច្រើន។

សីតុណ្ហភាពក្តៅខ្លាំងអាចធ្វើឲ្យដំណាំរាំងស្ងួះ ក្នុងការស្រូបយកជីជាតិសម្រាប់ចិញ្ចឹមដើម ទោះបីរូបធាតុទាំងនោះមាននៅក្នុងដីក៏ដោយ ព្រមទាំងធ្វើឲ្យស្លោកផ្លែឬស្លឹកទៀតផង។

សីតុណ្ហភាពមធ្យមប្រចាំឆ្នាំគឺ ២៧ អង្សាសេ ឯពេលវេលាសមស្របល្អក្នុងការដាំដុះបន្លែនៅប្រទេសកម្ពុជាគឺ ខែវិច្ឆិកា ធ្នូ និងមករា ពិសេសបន្លែយកមើម និងពពួកស្ពៃដែលទាមទារសីតុណ្ហភាពត្រជាក់ ពន្លឺគ្រាប់គ្រាន់ គ្មានពពក អាចធ្វើរស្មីសំយោគបានល្អ ព្រមទាំងមានការដុះលូតលាស់ សមស្របផង។

#### ១.៥.១.២. កត្តាទឹកភ្លៀង

ទឹកភ្លៀង ជាកត្តាយ៉ាងសំខាន់សម្រាប់ដំណាំបន្លែទូទៅ ពិសេសការរាយទឹកភ្លៀង និងចំនួនទឹកភ្លៀងដែលធ្លាក់ក្នុងមួយឆ្នាំ។ ប្រទេសកម្ពុជា ទឹកភ្លៀងធ្លាក់រាយមិនបានស្មើទូទៅទេ គឺយើងមាន ៦ខែជារដូវវស្សា និង ៦ខែជារដូវប្រាំងដែលខ្សត់ទឹកភ្លៀង។ នៅរដូវវស្សាជួនកាលក៏មានជួបប្រទះនឹងការរាំងស្ងួត ដែលបណ្តាលឲ្យខូចខាតផលដំណាំដែរ។ ការដាំដុះបន្លែមួយចំនួនពឹងផ្អែកទៅលើ

[12] បណ្ឌិត ប្រិន រ៉ូវែល និង តាត់ អេងឡាយ, ១៩៩២, ដំណាំបន្លែនៅកម្ពុជា

ទឹកភ្លៀង ប៉ុន្តែនៅរដូវភ្លៀងវាអាចធ្វើឲ្យមានការលំបាកខ្លះដែរដូចជា៖

- ស្មៅឆាប់ដុះ
- បន្លែឈ្លក់ទឹកពេលភ្លៀងខ្លាំង
- បាត់បង់ដីដោយហូរតាមទឹក
- ដីឆាប់ហាប់
- មានជំងឺផ្សិតច្រើន
- ការប្រើប្រាស់ថ្នាំ ជូនកាលគ្មានប្រសិទ្ធភាព។

ប៉ុន្តែនៅរដូវប្រាំង ការដាំដុះទាមទារធ្វើឲ្យបានពីដើមរដូវ និងទាមទារការស្រោចទឹកច្រើន ឬធ្វើការបញ្ចូលទឹកជំនួសទឹកភ្លៀង។ នៅចុងរដូវវស្សា ភ្លៀងច្រើនធ្លាក់ខ្លាំងហួស ឯចុងរដូវប្រាំងច្រើនខ្វះទឹក សីតុណ្ហភាពក៏ក្តៅខ្លាំង ការដាំដុះក៏ពុំសូវផ្តល់ផលសមស្របឡើយ។

ទឹកភ្លៀងខ្លាំង រួចរាំងស្ងួតយូរក្រោយពេលដាំគ្រាប់ អាចបណ្តាលឲ្យគ្រាប់មិនដុះព្រោះដីស្រទាប់លើហាប់ណែនខ្លាំង គ្រាប់លំបាកដុះចេញ រួចពន្លកក៏ងាប់នៅក្នុងដីនោះតែម្តង។ ទឹកភ្លៀងជាកត្តាមួយសំខាន់សម្រាប់ការដាំដុះបន្លែ និងជាកត្តាកំណត់ទិន្នផលទៀតផង។

#### ១.៥.១.៣. សំណើមក្នុងបរិយាកាស

សំណើមក្នុងបរិយាកាសក៏ដើរតួសំខាន់ណាស់ដែរ ក្នុងការដាំដុះដំណាំបន្លែ។ សំណើមក្នុងបរិយាកាសមានកម្រិតខ្ពស់កាលណាភ្លៀងធ្លាក់ខ្លាំង។ នៅរដូវប្រាំង សំណើមក្នុងបរិយាកាសមានកម្រិតទាប ឯកម្រិតនៃការស្រោចទឹកបន្លែក៏យោងទៅលើសំណើមក្នុងបរិយាកាសដែរ។ កាលណាខ្យល់ក្នុងបរិយាកាសសើម រុក្ខជាតិបន្ថយនូវបំភាយចំហាយទឹក ការត្រូវការទឹករបស់ដំណាំក៏ថយចុះ។ នៅប្រទេសកម្ពុជា ក្នុងខែវិច្ឆិកា ធ្នូ ឬមករា សីតុណ្ហភាពចុះ សំណើមក្នុងបរិយាកាសក៏ចុះទាបដែរ ឯវត្តមាននៃសត្វល្អិតចង្រៃ ឬជំងឺក៏ពុំសូវមានកើតដែរ។ នៅចុងរដូវវស្សាភ្លៀងធ្លាក់ខ្លាំងធ្វើឲ្យសត្វល្អិតមួយចំនួនធំងាប់ដែលជាហេតុធ្វើឲ្យការកកើតកូនចៅនៅដើមរដូវប្រាំងពុំសូវមានសភាពខ្លាំងក្លា។

#### ១.៥.១.៤. រយៈពេលយប់ និងថ្ងៃ

រយៈពេលយប់ និងថ្ងៃក៏មានឥទ្ធិពលទៅលើការដាំដុះបន្លែផងដែរ។ ចំពោះប្រភេទដំណាំបន្លែខ្លះ ត្រូវការយប់យូរជាងថ្ងៃ និងខ្លះទៀតត្រូវការថ្ងៃយូរជាងយប់ដើម្បីលូតលាស់ និងចេញផ្លែផ្កា។ ក៏ប៉ុន្តែ ប្រភេទដុះណាំខ្លះ មិនប្រកាន់រដូវទេ គឺអាចលលូតលាស់ និងផ្តល់ផ្លែផ្កាខែណាក៏បាន។

### ១.៥.២. កត្តាទឹក

នៅប្រទេសកម្ពុជាយើង ដាំណាំបន្លែភាគច្រើនដាំនៅតាមដងទន្លេ លើដីសំបូរជីជាតិ ឬនៅលើដីកោះ។ នៅក្នុងខែសីហា កញ្ញា តុលា ផ្ទៃដីភាគច្រើនត្រូវលិចទឹកទន្លេមេគង្គ ទន្លេបាសាក់ ទន្លេតូច

ទន្លេសាប ឬទឹកភ្លៀង។ នៅក្នុងរយៈពេលនេះ ផ្ទៃដីប្រហែល៦០-៧០% ត្រូវខកខានដាំដំណាំ។ ផ្ទៃដីខ្លះត្រូវលិចទឹកក្នុងរយៈពេលពី ២ ទៅ ៤ ខែ ទៅតាមកម្ពស់ដី និងកម្រិតទឹកឡើងខ្លាំងឬតិច និងផ្លាស់ប្តូរទៅតាមឆ្នាំនីមួយៗ។ ការទទួលដីល្បាប់ជីជាតិថ្មី ក៏ប្រែប្រួលទៅតាមនោះដែរ។ ជាទូទៅបន្លែមួយចំនួនធំច្រើនដាំនៅខែទឹកស្រក ចាប់ពីចុងខែតុលា ឬដើមខែវិច្ឆិកា ឬដាំបណ្តោញទឹកបើសិនជាដីនោះលិចទឹក ដើម្បីធានានូវទឹកស្រោចស្រពដំណាំក្នុងករណីគ្មានស្រះ អណ្តូង ឬក៏ត្រូវរីងស្ងួតអស់។ ដើម្បីចំណេញពេលវេលា កសិករមួយចំនួនបានអនុវត្តការសាបកូនបន្លែនៅលើដីខ្ពស់ ដោយលែលកយ៉ាងណាឲ្យកូនបន្លែធំល្មមស្ទូង នៅពេលដីត្រូវស្ទូងនោះស្រស់ទឹកល្អ។

ចំពោះដំណាំបន្លែមួយចំនួនដែលមិនសូវទាមទារការស្រោចទឹកជាប្រចាំ គេអាចដាំដោយមិនបាច់ស្រោចទឹក ប៉ុន្តែនៅលើប្រភេទដីដែលអាចរក្សាទឹកទុកបានយូរអាចឲ្យរុក្ខជាតិរស់បាន។

ចំពោះដំណាំបន្លែមួយចំនួនទៀត ដែលទាមទារការស្រោចទឹកច្រើនត្រូវដាំនៅក្បែរមាត់ទន្លេ បឹងបួ ត្រពាំង ឬអាងទឹកដើម្បីងាយស្រួលក្នុងការស្រោចស្រព។

ទឹកដែលដំណាំបន្លែត្រូវការអាចបានមកពីទឹកភ្លៀង សន្សើម ស្រោចដោយកម្លាំងមនុស្ស បូមចូលតាមប្រឡាយតូចធំ ឬស្រោចស្រពពីលើ ឬបានពីការស្រូបបឺតពីក្នុងដី។ តម្រូវការទឹកផ្លាស់ប្តូរទៅតាមមុខដំណាំ រដូវ តំបន់ និងទៅតាមដំណាក់កាលលូតលាស់របស់វា។ ការស្រោចស្រពច្រើនហួសអាចបណ្តាលឲ្យបន្លែឈ្លក់ទឹក ស្រពោន ឬងាប់ ឬអំណោយផលដល់ការកើតជំងឺផ្សេងៗ។ ឯការខ្វះខាតទឹកក៏ធ្វើឲ្យបន្លែលូតលាស់ពុំបានល្អដែរ។

### **១.៥.៣. ភក្តាដី**

ដីសំដៅយកផ្នែកខាងលើ ដែលឫសបន្លែចាក់ចូល និងស្រូបយកជីជាតិ។ លក្ខណៈទ្រង់ទ្រាយទំហំម៉ូលេគុល និងសមាសភាពគីមីរបស់ដីមានសារៈសំខាន់ណាស់ក្នុងការជ្រើសរើសមុខដំណាំ។ ដំណាំបន្លែទាមទារដីធូរជ្រៅមានជីជាតិច្រើន និងជាប្រភេទដីដែលមិនជូរពេក ឬអាល់ការឡាំងពេក គឺជាទូទៅ pH ពី ៦.៥ ទៅ ៧.៥។ យោងទៅលើ pH គេចែកប្រភេទដីដូចតទៅះ

- pH : ៤ ទៅ ៥ ដីជូរខ្លាំង
- pH : ៥ ទៅ ៦ ដីជូរបន្តិច
- pH : ៧ ដីណឺត (NEUTER)
- pH : ៧.៥ ទៅ ៨ ដីអាល់កាឡាំងបន្តិច
- pH : លើសពី ៨ ដីអាល់កាឡាំងខ្លាំង (មានជាតិកំបោរច្រើន)

ជាទូទៅដីនៅតាមមាត់ទន្លេ នៅប្រទេសកម្ពុជា pH = ៦.៥ ទៅ ៧.៥ ចំពោះបាតបឹង pH

ភាគច្រើនទាប គឺអាចធ្លាក់ដល់ pH = ៤ ទៅ ៥។ pH ពី ៥.៥ ទៅ ៦ អាចឲ្យត្រាវ ម្ទេស ស្ពៃក្ដោប ប៉េងប៉ោះ និងត្រសក់លូតលាស់បាន។

### ១.៥.៤. កត្តាជី

បន្លែជាប្រភេទដំណាំដែលមានឫសខ្លី មិនអាចស្រូបយកជីជាតិពីក្នុងដីបានជ្រៅឡើយ។ ដូច្នេះវាទាមទារការដាក់ជីច្រើនដើម្បីជំនួយដល់ការលូតលាស់។ ជីសម្រាប់ដំណាំបន្លែអាចបានមកពីធម្មជាតិ លាមកសត្វ ជីកំប៉ុស្ត និងជីគីមី។ ជីជាតិមួយចំនួនស្ថិតនៅក្នុងដីស្រាប់ និងមួយចំនួនទៀតត្រូវដាក់បន្ថែម។

បន្លែយកស្លឹក ទាមទារការដាក់ជីដែលមានជាតិអាសូតច្រើន ឯបន្លែយកផ្លែត្រូវការជាតិផូស្វាត និងបន្លែយកមើមទាមទារយកប៉ូតាស្យូមច្រើន ដើម្បីផ្ដល់ទិន្នផលខ្ពស់។ ការដាក់ជីអាសូតច្រើនហួសបណ្ដាលឲ្យបន្លែយកគ្រាប់ពន្យារពេលទុំ និងងាយកើតជំងឺ។

កម្រិតជីដែលត្រូវប្រើផ្លាស់ប្ដូរទៅតាមប្រភេទដី ប្រភេទបន្លែ និងដំណាក់កាលនៃការលូតលាស់របស់បន្លែ។ បន្ថែមលើនេះទៀត ដំណាំបន្លែក៏ត្រូវការជីមួយចំនួនទៀតដូចជា Ca, S , Mg, Fe, Cu, Zn, Cl, Mn, Mo, B ។ល។

ការខ្វះធាតុចិញ្ចឹមខាងលើណាមួយ បណ្ដាលឲ្យដំណាំបន្លែមានជំងឺម្យ៉ាង ដែលគេហៅថាជំងឺខ្វះជីជាតិ។ ការខ្វះខាតនេះធ្វើឲ្យដំណាំខ្វះសមត្ថភាពក្នុងការផ្ដល់ទិន្នផលបានខ្ពស់បំផុត។

## ១.៦. ស្ថានភាពទីផ្សារបន្លែនៅកម្ពុជា

ការផ្គត់ផ្គង់តម្រូវការនៃផលិតផលបន្លែ នៅប្រទេសកម្ពុជា គឺមានឥទ្ធិពលយ៉ាងខ្លាំងដោយរដូវកាលប្រមូលផល។ នៅក្នុងរដូវកាលដែលប្រមូលផលច្រើនជាងគេពីខែធ្នូ ទៅដល់ខែកុម្ភៈ ដែលមានការផ្គត់ផ្គង់ច្រើនជាងតម្រូវការទៅទៀតហើយក៏បានធ្វើឲ្យថ្លៃបន្លែធ្លាក់ចុះ។ ហើយផ្ទុយទៅវិញ ការផ្គត់ផ្គង់បន្លែមិនមានការគ្រប់គ្រាន់នៅ ខែមីនាដល់ខែមេសា ។ សម្រាប់ទីផ្សារដ៏សំខាន់នៃទីផ្សារបន្លែគឺការលក់ទៅឲ្យអ្នកលក់ដុំដែលបានទៅទិញដល់កន្លែងកសិករដាំដុះផ្ទាល់តែម្ដង។ ហើយតម្លៃបន្លែនៅលើទីផ្សារមានលក្ខណៈខុសប្លែកគ្នាផងដែរ។ ផលិតផលបន្លែត្រូវបានគេដឹកជញ្ជូនទៅលក់នៅក្នុងទីផ្សារបន្ទាប់មក អ្នកលក់ដុំក៏បានលក់បន្តទៅឲ្យអ្នកលក់រាយនៅក្នុងតំបន់ ឬផ្សារផ្សេងៗទៀត។ ដូចច្នេះ ផលិតផលបន្លែត្រូវបានឆ្លងកាត់មនុស្សពី ៣-៤នាក់ ដើម្បីទៅដល់អ្នកប្រើប្រាស់ចុងក្រោយ។ [13]

---

[13] Ungsa and Vanhorn, ១៩៩៥

### ១.៦.១. និយមន័យទីផ្សារ

ក្នុងន័យធម្មតាទីផ្សារ គឺជាទីកន្លែងដោះដូរផលិតផលរវាងអ្នកទិញ និងអ្នកលក់ក្នុងក្របខណ្ឌតំបន់ភូមិសាស្ត្រនៅក្នុងរយៈពេលមួយកំណត់ នៅទីនោះដែលសេចក្ដីត្រូវការរបស់អ្នកទិញទាំងឡាយ ជួបជាមួយនឹងការផ្គត់ផ្គង់របស់អ្នកលក់និងដោះដូរចំពោះថ្លៃសមស្របមួយ។

ទីផ្សារ ជាមូលដ្ឋានចាំបាច់សម្រាប់យន្តការទីផ្សារសេរី (Economic mechanism) ដែលមានការផ្លោះប្ដូរផលិតផល និងសេវាដែលវាបង្កើតដោយមានពលកម្មសង្គម (Public labor) ជាមូលដ្ឋាន។ ទីផ្សារ ជាប្រភពនៃការរីកចម្រើននៃសេដ្ឋកិច្ចសង្គម។ ទីផ្សារជាកន្លែងដែលរៀបចំឡើង សម្រាប់ឲ្យមានទំនាក់ទំនងរវាងអ្នកលក់ (ផលិតករ) ឬអ្នកផ្គត់ផ្គង់ (Supplier) និងអ្នកទិញ (អតិថិជនឬ អ្នកប្រើប្រាស់) ឬអ្នកមានតម្រូវការដើម្បីដោះដូរទំនិញ និងសេវាកម្ម តាមរយៈការដោះដូរនេះធ្វើឲ្យមានកិច្ចព្រមព្រៀងគ្នាក្នុងការបង្កើត ឬចងក្រងថ្លៃ និងកំណត់បរិមាណផលិតផលដែលចាំបាច់សម្រាប់សង្គមមនុស្ស។ [14]

### ១.៦.២. តម្រូវការ និងច្បាប់តម្រូវការ [15]

តម្រូវការ បង្ហាញអំពីបំណងចង់បានទ្រព្យនិងសេវា និងលទ្ធភាពនៃការទូទាត់ដើម្បីទទួលបានវា។ សេដ្ឋវិទូនិយាយថា អ្នកគ្មានតម្រូវការជាក់ស្ដែងទេ បើអ្នកចង់បានរបស់អ្វីម្យ៉ាង តែគ្មានលទ្ធភាពដើម្បីទិញវា។ ផ្ទុយទៅវិញ បើអ្នកចង់បានរបស់អ្វីម្យ៉ាង ហើយអ្នកមានលុយអាចទិញវាបាន នោះគេថាអ្នកមានតម្រូវការលើវា។

ថ្លៃ គឺជាកត្តាសំខាន់មួយ ដែលមានឥទ្ធិពលទៅលើតម្រូវការ។ នៅកម្រិតថ្លៃនីមួយៗ បរិមាណតម្រូវការ គឺជាបរិមាណអតិបរមាដែលអ្នកទិញចង់ទិញនៅថ្លៃនោះ។

ច្បាប់តម្រូវការ អះអាងថា បើកត្តាឥទ្ធិពលផ្សេងៗទៀតមិនប្រែប្រួលនៅជំណាក់កាលជាក់លាក់មួយ ហើយបើថ្លៃមុខទំនិញមួយកាន់តែថោក នោះបរិមាញតម្រូវការទំនិញនោះកាន់តែកើនឡើង។ ផ្ទុយទៅវិញ បើថ្លៃទំនិញកាន់តែកើន នោះបរិមាណតម្រូវការទំនិញកាន់តែតិច។

[14] ហ៊ីង ចូវ៉ាក់ស៊ី និងហ៊ាន សាហ៊ីប ២០០៣

[15] ម៉ម ចរិយាវុធ និង ងួន ហេង, សេដ្ឋកិច្ចនយោបាយ, បោះពុម្ពលើកទី៣, ឆ្នាំ២០១២, ទំព័រ៦៨

### ១.៦.៣. ផ្គត់ផ្គង់ និងច្បាប់ផ្គត់ផ្គង់ [16]

ផ្គត់ផ្គង់ បង្ហាញពីបំណង និងលទ្ធភាពរបស់អ្នកផលិត ក្នុងការផ្គត់ផ្គង់ទ្រព្យ និងសេវាលើទីផ្សារ។ អ្នកដែលផ្គត់ផ្គង់ទ្រព្យ ឬសេវាលើទីលផ្សារ គឺជាអ្នកផលិត (ផលិតករ)។

ថ្លៃ គឺជាកត្តាសំខាន់ដែលមានឥទ្ធិពលទៅលើការផ្គត់ផ្គង់។ ច្បាប់ផ្គត់ផ្គង់ បង្ហាញថាអ្នកផលិតមានបំណងលក់ទ្រព្យ និងសេវាកាន់តែច្រើននៅថ្លៃខ្ពស់ ហើយលក់កាន់តែតិចនៅថ្លៃទាប។

## ១.៧. ប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងផលិតកម្មកសិកម្ម

ប្រសិទ្ធភាពសេដ្ឋកិច្ច គឺជារង្វាស់ដ៏សំខាន់មួយដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយក្នុងផលិតកម្មកសិកម្ម។ គ្រប់កត្តាផលិតកម្មដែលយកទៅវិនិយោគក្នុងផលិតកម្មដូចជា ដីធ្លី កម្លាំងពលកម្ម ដើមទុន និងបច្ចេកវិទ្យា ត្រូវបានវាស់វែងដោយខ្នាតរង្វាស់ប្រសិទ្ធភាពសេដ្ឋិកិច្ចដោយឆ្លងកាត់អនុគមន៍ផលិតកម្ម[17] ដូចខាងក្រោម៖

$$Y = f(A, L, C, T)$$

ដែលក្នុងនោះ Y : ជាបរិមាណកសិផលដែលទទួលបានក្នុងមួយវដ្តផលិតកម្ម

A : ជាផ្ទៃដីផលិតកម្ម

L : ជាកម្លាំងពលកម្មប្រចាំកសិដ្ឋាន

C : ជាដើមទុន ឬជាមូលធនសម្រាប់វិនិយោគក្នុងផលិតកម្ម

T : ជាបច្ចេកវិទ្យាដែលយកមកប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម

តាមអនុគមន៍ផលិតកម្មខាងលើ យើងសង្កេតឃើញថា បរិមាណកសិផល កើនឡើងបានអាស្រ័យដោយកត្តផលិតកម្មទាំងបួនក្នុងអនុគមន៍ផលិតកម្ម ហើយបរិមាណកសិផលកើនឡើងជាលំដាប់ក៏អាស្រ័យប្រសិទ្ធភាពសេដ្ឋកិច្ចនៃកត្តាផលិតកម្មនីមួយៗផងដែរ។

### ១.៧.១. តម្រូវការទុនផលិតកម្ម និងការចំណាយ

ទុនផលិតកម្ម គឺជាដើមទុនទាំងឡាយណាដែលចាំបាច់ប្រើប្រាស់ក្នុងផលិតកម្ម។ ទុនដែលប្រើប្រាស់ក្នុងផលិតកម្មរួមមាន៖

- អចលនទុន
  - ជាតម្លៃរបស់អចលនទ្រព្យ

---

[16] ម៉ម ចរិយាវុធ និង ងួន ហេង, សេដ្ឋកិច្ចនយោបាយ, បោះពុម្ពលើកទី៣, ឆ្នាំ២០១២, ទំព័រ៨១

[17] Timothy J. Coelli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer, Page 12

- មានតម្លៃខ្ពស់
- រយៈពេលប្រើប្រាស់ច្រើនជាងមួយឆ្នាំ
- រក្សាបាននូវរូបភាព ឬទ្រង់ទ្រាយដើមក្រោយពេលប្រើប្រាស់
- បញ្ចូលតម្លៃរបស់វាបន្តិចម្តងៗទៅក្នុងផលិតផលថ្មីដែលទើបផលិតបាន
- តម្លៃត្រូវបានបញ្ចូលតាមរយៈរំលោះ

➢ ចលនទុន

- ជាតម្លៃរបស់ចលនទ្រព្យដែលវិនិយោគក្នុងផលិតកម្មកសិកម្ម
- មានតម្លៃទាប
- ជារបស់ឆាប់ខូច
- ប្រើប្រាស់បានរយៈពេលតិចជាងមួយឆ្នាំ
- បាត់រូបភាពដើមទាំងស្រុងក្រោយពេលផលិត
- បញ្ចូលតម្លៃរបស់ខ្លួនវាតែម្តងគត់នៅក្នុងផលិតកម្មថ្មីដែលទើបផលិតបាន។

### ១.៧.២. ចំណូលពីការលក់ដំណាំបន្លែ

ចំណូលក្នុងផលិតកម្មកសិកម្ម គឺជាចំណូលដែលទទួលបានពីការលក់បរិមាណកសិផលសរុបដែលផលិតបានក្នុងមួយវដ្តផលិតកម្ម[18] (Q) គុណជាមួយនឹងថ្លៃកសិផលគិតក្នុងមួយឯកតា (P) ពោលគឺ៖

| |
|---|
| ចំណូល (TR) = ថ្លៃលក់កសិផលក្នុងមួយឯកតា (P) x បរិមាណកសិផលសរុប (Q) |

### ១.៧.៣. ប្រាក់ចំណេញពីការដាំដុះបន្លែ

ប្រាក់ចំណេញក្នុងផលិតកម្មកសិកម្ម ទទួលបានពីចំណូលក្នុងផលិតកម្មកសិកម្ម ដកនឹងចំណាយសរុបក្នុងផលិតកម្មកសិកម្ម[19] ពោលគឺ៖

| |
|---|
| ប្រាក់ចំណេញសរុប = ចំណូលសរុប (TR) - ចំណាយសរុប (TC) |

[18] Hal R. Varian, 2010, Intermediate Microeconomics, 8th Edition, New York, W.W. Norton & Company, Page 277

[19] Timothy J. Coelli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer, Page 12

### ១.៧.៤. ប្រសិទ្ធភាពសេដ្ឋកិច្ចមួយឯកតាទុនផលិតកម្ម

ការវិភាគរកប្រសិទ្ធភាពមួយឯកតាទុនផលិតកម្មគឺ ចង់ដឹងថា តើនៅពេលម្ចាស់កសិដ្ឋាន ចំណាយដើមទុនមួយរៀលទៅ តើគាត់នឹងទទួលបានប៉ុន្មានរៀលត្រឡប់មកវិញក្នុងចំណូលរបស់គាត់ ហើយចំណេញបានប៉ុន្មានដែរ? រូបមន្ត[20]សម្រាប់គណនា ផលិតភាពសេដ្ឋកិច្ចមួយឯកតាទុនផលិតកម្មគឺ

$$\text{ប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម (E)} = \frac{\text{ចំណូលសរុបប្រចាំឆ្នាំ ឬ ក្នុងមួយវដ្តផលិតកម្ម}}{\text{ចំណាយសរុបប្រចាំឆ្នាំ ឬ ក្នុងមួយវដ្តផលិតកម្ម}}$$

### ១.៧.៥. ប្រសិទ្ធភាពកម្លាំងពលកម្ម

ការគណនារកប្រសិទ្ធភាពកម្លាំងពលកម្មនេះ យើងអាចរកឃើញថា តើក្នុងកម្លាំងពលកម្ម ១នាក់ អាចរកប្រាក់ចំណូលបានប៉ុន្មាន? ក្នុងការគណនារកប្រសិទ្ធភាពកម្លាំងពលកម្ម អាចប្រើប្រាស់រូបមន្ត[21]ដូចខាងក្រោម៖

$$\text{ប្រសិទ្ធភាពកម្លាំងពលកម្ម} = \frac{\text{ថ្លៃកសិផលក្នុងមួយឯកតា X បរិមាណកសិផល}}{\text{កម្លាំងពលកម្មសរុប}}$$

### ១.៧.៦. ប្រសិទ្ធភាពដីធ្លី

ប្រសិទ្ធភាពដីធ្លីអាចឲ្យយើងដឹងថា តើដីរបស់កសិដ្ឋាន ១ឯកតា អាចរកចំណូលឲ្យកសិករបានប៉ុន្មាន? យើងអាចគណនាប្រសិទ្ធភាពដីធ្លីតាមរូបមន្ត[22]ដូចខាងក្រោម៖

$$\text{ប្រសិទ្ធភាពដីធ្លី} = \frac{\text{ចំណូសរុបប្រចាំឆ្នាំ ឬ មួយខួបផលិតកម្ម}}{\text{ផ្ទៃដីសរុប}}$$

## ១.៨. ការវិភាគចំណុចស្រង់ដើម

ចំណុចស្រង់ដើម គឺជាចំណុចដែលចំណូលសរុប ស្មើនឹងចំណាយសរុប មិនខាតហើយក៏

[20] Timothy J. Coelli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer, Page 210

[21] David Besanko Ronald R. Braetigan, 2010, Microeconomic, 4th Edition, New York, John Wiley & Sons, Page 206

[22] Timothy J. Coelli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer, Page 255

មិនចំណេញ។ គោលដៅនៃការវិភាគចំណុចស្រង់ដើម គឺវិភាគលើខ្សែចំណាយអថេរ ពីព្រោះថា ចំណាយអថេរ គឺជាការចំណាយទៅលើចលនទ្រព្យ ពោលគឺការចំណាយទៅលើខ្សែចលនទុន ប្រសិនបើដំណើរការផលិតកម្មរបស់កសិដ្ឋានប្រែប្រួល នោះខ្សែចំណាយចលនទុនក៏ប្រែប្រួលដែរ។

ការគណនារកចំណុចស្រង់ដើម អនុវត្តទៅតាមរូបមន្តដូចខាងក្រោម៖

ដោយចំណុចស្រង់ដើមជាចំណុចដែល ចំណូលសរុប (TR) = ចំណាយសរុប (TC)

ដោយ TR = PQ

$\Rightarrow$ PQ = TC

$\Rightarrow P = \frac{TC}{Q}$

ដូចនេះ $$\boxed{P = \frac{TC}{Q}}$$

ដែល P : ជាថ្លៃលក់នៅចំណុចស្រង់ដើម

Q : ជាបរិមាណកសិផល

TC: ជាចំណាយសរុបក្នុង១វដ្តផលិតកម្ម

# ជំពូកទី២
# ស្ថានភាពទូទៅនៃដំណាំបន្លែនៅឃុំស្វាយប្រទាល

# ជំពូកទី២

# ស្ថានភាពទូទៅនៃដំណាំបន្លែនៅឃុំស្វាយប្រទាល

## ២.១. ស្ថានភាពទូទៅនៃតំបន់សិក្សាស្រាវជ្រាវ

### ២.១.១. ស្ថានភាពទូទៅនៃស្រុកស្អាង

#### ២.១.១.១. ទីតាំងភូមិសាស្ត្រស្រុកស្អាង

ស្រុកស្អាង គឺជាស្រុកមួយរបស់ខេត្តកណ្តាល ស្ថិតនៅតំបន់វាលទំនាប លាតសន្ធឹងតាមបណ្តោយដងទន្លេបាសាក់ ពុះស្រុកជាពីផ្នែក គឺផ្នែកខាងលិចទន្លេ និងខាងកើតទន្លេមានដីកោះ ៤កន្លែង រួមមានឃុំកោះអន្លង់ចិន ឃុំខ្សាច់ទន្លា កោះគរនៃឃុំស្វាយប្រទាល និងកោះថ្មីនៃឃុំខ្ពប ហើយមានព្រំប្រទល់៖

- ខាងកើតជាប់ស្រុកកៀនស្វាយ និងស្រុកលើកដែក
- ខាងលិចជាប់នឹងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងស្រុកព្រៃកប្បាស និងស្រុកបាទី ខេត្តតាកែវ
- ខាងជើងជាប់នឹងក្រុងតាខ្មៅ
- ខាងត្បូងជាប់នឹងស្រុកកោះធំ

ស្រុកស្អាងមាន ១៦ឃុំ ១១៩ភូមិ និងមានប្រជាជនរស់នៅប្រមាណ១៩៧,៩០១នាក់ (សាលាស្រុកស្អាង) ស្ថិតនៅក្នុងគ្រួសារភាគច្រើនសុទ្ធសឹងជាគ្រួសារកសិករប្រកបរបរកសិកម្ម ៩៥ ភាគរយ (ដាំដំណាំគ្រប់រដូវ និងចិញ្ចឹមសត្វ)។

#### ២.១.១.២.ស្ថានភាពសេដ្ឋកិច្ច

ដោយយោងទៅលើតំបន់ភូមិសាស្ត្ររបស់ស្រុកស្អាង ប្រព័ន្ធកេ្សត្របរិស្ថានត្រូវបានបែងចែកជា៣ គឺ៖

- តំបន់កេ្សត្របរិស្ថានទី១ តំបន់នេះស្ថិតនៅភាគខាងលិចនៃស្រុកស្អាង ផ្ទៃដីដាំដុះភាគច្រើនជាដំណាំស្រូវដែលមានអាងទឹកធំមួយឈ្មោះ បឹង៥៥០ ឬបឹងជើងលាង ដែលអាចស្រោចស្រពទឹកស្រូវប្រាំងបានប្រមាណ ៣,២០០ ហ.ត របស់ប្រជាកសិករចំនួនបីឃុំ គឺ ឃុំកោះខែល ព្រៃកអំបិល និងក្រាំងយ៉ូវ ហើយមានប្រព័ន្ធប្រឡាយគ្រប់គ្រាន់សម្រាប់ស្រោចស្រព ដែលធ្វើឲ្យមានទឹកស្រោចស្រពគ្រប់រដូវ គម្របដីមានភាពជំរាលល្មម មានដីទួលខ្លះៗជាមួយនឹងទំនាបបឹង អូរ ថ្លុកត្រពាំងហើយមានការហូរច្រោះល្មម។
- តំបន់កេ្សត្របរិស្ថានទី២ ការរស់នៅរបសប្រជាជនមានច្រើនកុះករ នៅអមសងខាងទន្លេ

បាសាក់ ហើយប្រើប្រាស់ទឹកទន្លេសម្រាប់ហូប និងប្រកបរបរកសសិកម្ម។ ជាតំបន់ដែលសម្បូរទៅដោយធនធានធម្មជាតិ ដូចជាដីល្បាប់អាចដាំដំណាំបានគ្រប់រដូវ សម្បូរត្រីក្នុងបឹង និងក្នុងទន្លេ។

- តំបន់ក្បៀត្របរិស្ថានទី៣ តំបន់នេះស្ថិតក្នុងភាគអាគ្នេយ៍ស្រុកស្អាង រយៈពេលលិចទឹក ៤ ខែ គោក៨ខែ លើផ្ទៃដីមួយចំនួន។ ប្រជាជននៅតំបន់នេះរស់នៅកុះករចំនួន៣កន្លែង ដែលមាន ៥ភូមិ និងមួយឃុំ គឺការសង់ផ្ទះមានកម្ពស់ពីដី ៦ទៅ ៧ម៉ែត្រ ហើយនៅជុំវិញភូមិ និងផ្ទះគេដាំឫស្សីព្រៃ និងដើមឈើដូចជា ខ្នុរ រាំង កុំឲ្យខ្យល់បោកបក់ខ្លាំង។

**២.១.១.៣. ប្រភពទឹក**

ទឹក ជាប្រភពនៃការទ្រទ្រង់ដល់ការលូតរបស់រុក្ខជាតិដ៏សំខាន់។ ជាក់ស្តែង ក្នុងស្រុកស្អាង ដែលជាស្រុកសម្បូរទៅដោយកសិករ ប្រកបរបរកសិកម្ម ប្រភពទឹកសម្រាប់ប្រើប្រាស់ និងស្រោចស្រពដំណាំ គឺជាកត្តាសំខាន់ដែលមិនអាចខ្វះបាន។ ប្រភពទឹកសំខាន់ៗសម្រាប់ស្រុកស្អាងមាន ដូចជាៈ

- ទន្លេបាសាក់ដែលហូរកាត់ស្រុកស្អាង ហាក់បីដូចជាពុះស្រុកស្អាងជាពីរ ហើយហូរនាំដីល្បាប់ពីទន្លេមេគង្គ ទៅតាមព្រែកតូចធំនៅអមសងខាងទន្លេ ចាក់ទៅដីទំនាបដែលអំណោយផលដល់កាដាំដុះដំណាំគ្រប់ប្រភេទ និងការធ្វើស្រូវឡើងទឹក។
- ស្ទឹងព្រែកត្នោតដែលហូរកាត់ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលបានតម្រង់មកស្រុកស្អាង ដែលអំណោយផលដល់ការដាំដុះស្រូវវស្សានៅគ្រប់បណ្តាឃុំប៉ែកខាងលិច។ ពេលទឹកឡើងខ្លាំង ស្រុកស្អាងជាចំណុចជួបនៃទន្លេបាសាក់ និងទឹកស្ទឹងព្រែកត្នោត ហើយបង្កឲ្យមានការលិចលង់ផលដំណាំរបស់កសិករខ្លាំងក្លាណាស់ដែរ។

**២.១.១.៤. ស្ថិតិប្រជាពលរដ្ឋក្នុងស្រុកស្អាង**

តារាងទី២.១ ស្ថិតិប្រជាជនក្នុងស្រុកស្អាងឆ្នាំ២០០៨

| ល.រ | ឈ្មោះ ឃុំ-សង្កាត់ | ចំនួនភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋ | | ចំនួនប្រជាពលរដ្ឋ អាយុ ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | សរុប | ស្រី |
| ១ | ស្វាយរលំ | ៥ | ៣,៥៥៣ | ១៦,៧២៧ | ៩,៧០៥ | ១០,៩៦៩ | ៧,២០៥ |
| ២ | កោះអន្លង់ចិន | ៤ | ១,០៩៤ | ៤,៨២៣ | ២,៥៤៥ | ២,៦៣០ | ១,៣៨៦ |
| ៣ | សិត្បូ | ៤ | ១,៥៧២ | ១០,៧៩១ | ៧,២៤១ | ៧,១១២ | ៤,៨១៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | រកាខ្ពស់ | ៥ | ២,១០០ | ១៣,៧៦៤ | ៦,៧៩១ | ៩,១៣៣ | ៤,៥១៦ |
| ៥ | ស្វាយប្រទាល | ៩ | ៣,០៣៩ | ១៥,២៥៣ | ៧,៨៩៤ | ៨,៦៩២ | ៤,៩០៨ |
| ៦ | ព្រែកគយ | ៧ | ២,៩២៧ | ១៦,១២៣ | ៨,២១៥ | ៨,៩៩១ | ៤,៦៧៥ |
| ៧ | ស្អាងភ្នំ | ៩ | ២,៧០៣ | ១៣,១០៤ | ៦,៦៧៧ | ៧,៩៦២ | ៣,៩៨៨ |
| ៨ | ក្រាំងយ៉ូវ | ១៥ | ៣,៥៥៣ | ១៧,៩៩៨ | ៨,៩៨៩ | ៩,២១៨ | ៤,៨០០ |
| ៩ | ទឹកវិល | ៨ | ២,០០៦ | ១០,០២០ | ៤,៧២៤ | ៧,០៦១ | ៣,៣១៩ |
| ១០ | កោះទន្លា | ៥ | ១,២៧៦ | ៦,០៨៥ | ៣,១៩៦ | ៣,៨៦០ | ២,១២៦ |
| ១១ | ត្រើយស្លា | ៩ | ៣,៩៧៣ | ១៧,៨៥១ | ៩,១៦១ | ១១,៧៧៣ | ៦,០៤៩ |
| ១២ | តាលន់ | ៩ | ២,៩៤៤ | ១២,៥២៧ | ៦,៣៣៣ | ៨,៣៦២ | ៤,១៣៩ |
| ១៣ | កោះខែល | ៦ | ១,៨២៩ | ៩,០៣៣ | ៤,៦៥២ | ៦,៧៥៨ | ២,៩១៦ |
| ១៤ | ព្រែកអំបិល | ៩ | ៤,៥៦៥ | ២៥,៦៨២ | ១២,៩០៣ | ១៦,១៣៩ | ៨,០៧៣ |
| ១៥ | ខ្ពប | ១០ | ២,៩៣៤ | ១១,៥៣៦ | ៦,០៣៤ | ៦,៩៩១ | ៣,៧០៦ |
| ១៦ | ប្រាសាទ | ៥ | ១,៣១៥ | ៦,៨៩១ | ៣,៦៩១ | ៣,៧៨៩ | ២,១៩០ |
| សរុប | | ១១៩ | ៣៩,៩៣៥ | ៣៨,០៩១ | ២០៧,៧០៨ | ១២៨,៨៩០ | ១២២,០៤៩ |

ប្រភព៖ សាលាស្រុកស្អាង

### ២.១.២. ទីតាំងភូមិសាស្ត្រឃុំស្វាយប្រទាល

ឃុំស្វាយប្រទាល គឺជាឃុំមួយដែលស្ថិតនៅស្រុកស្អាងខេត្តកណ្ដាល ប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា។ ឃុំនេះមានប្រទល់ជាប់នឹងឃុំ:

- ខាងជើងជាប់នឹងឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ
- ខាងកើតនិងខាងត្បូងជាប់នឹងឃុំត្រើយស្លា ស្រុកស្អាង
- ខាងលិចជាប់នឹងទន្លេបាសាក់ដែលជាប់បណ្ដោយឃុំ៣គឺ: ឃុំសិត្បូ ឃុំរការខ្ពស់ និងឃុំព្រែកគយ។

### ២.១.៣. ស្ថានភាពទូទៅនៃឃុំស្វាយប្រទាល

ស្វាយប្រទាល ជាឃុំមួយស្ថិតនៅតាមបណ្ដោយដងទន្លេបាសាក់ ហើយនៅភាគខាងជើង

ឆៀងខាងលិចនៃស្រុកកៀនស្វាយខេត្តកណ្តាល។ ឃុំស្វាយប្រទាលមានផ្ទៃដីសរុប ៣,៥៧០[23] ហ.ត ផ្ទៃដីលំនៅដ្ឋានមាន ៦៩៣[24] ហ.ត ផ្ទៃដីធ្វើស្រែមាន ៣១២ ហ.ត (ផ្ទៃដីធ្វើស្រែប្រាំង ១៧១ ហ.ត និងស្រែវស្សាមាន ១៤១ ហ.ត) ផ្ទៃដីធ្វើចម្ការមាន ៩០០ ហ.ត (ផ្ទៃដីធ្វើចម្ការរយៈពេលខ្លីមាន ៦១៤ហ.ត និងផ្ទៃដីធ្វើចម្ការរយៈពេលវែងមាន ២៨៦ ហ.ត) និងផ្ទៃដីផ្សេងៗ (ដីព្រៃ បឹងបួរ ។ល។) មាន ១,៦៦៥ ហ.ត។

តារាងទី២.២. ចំនួនភូមិ និងផ្ទៃដីគិតជាហ.ត

| ល.រ | ឈ្មោះភូមិ | ផ្ទៃដី |
|---|---|---|
| ១ | ព្រែកតាតិន | ៤១៤ |
| ២ | ឬស្សីជ្រោយ | ៤៣៥ |
| ៣ | ព្រែកតាជ័រ | ៥៣៩ |
| ៤ | ព្រែកតាសៅ | ៣៧១ |
| ៥ | ចុងកោះគរ | ៣៥៥ |
| ៦ | បារ៉ែនលើ | ៣០១ |
| ៧ | អូរំចេក | ២២៤ |
| ៨ | បារ៉ែនក្រោម | ៤៨៦ |
| ៩ | ពោធិតាប៉ាង | ៤៤៥ |
| សរុប | | ៣៥៧០ |

ប្រភព៖ សាលាឃុំស្វាយប្រទាល ឆ្នាំ២០១៧

***ស្ថិតិប្រជាជន**

នៅឃុំស្វាយប្រទាលមានភូមិចំនួន ៩[25] ភូមិ ហើយប្រជាពលរដ្ឋសរុបចំនួន ៣,៥៤៩[26] គ្រួសារ ប្រជាជនសរុប ១៦,០១០ នាក់ ក្នុងនោះមានស្រី ៨,៤៨៨ នាក់។ ប្រជាពលរដ្ឋអាយុ១៨ឆ្នាំ

[23] ពត៌មានសង្ខេបផ្ទៃដី ឃុំស្វាយប្រទាល ០១ មករា ២០១៧

[24] សៀវភៅទិន្នន័យស្ថិតិថ្នាក់ឃុំស្វាយប្រទាលឆ្នាំ២០១៦

[25] ស្ថិតិផ្ទៃដី ឃុំស្វាយប្រទាល ៣០ មករា ២០១៧

[26] ស្ថិតិប្រជាពលរដ្ឋប្រចាំឆមាសទី១ ឆ្នាំ២០១៧, ១២ មិថុនា ២០១៧

ឡើងសរុបមានចំនួន ៩,៥៥២ នាក់ ស្រីចំនួន ៥,១០២ នាក់ និងកម្លាំងពលកម្មសរុបដែលប្រកបរបរកសិកម្មដាំបន្លែ ស្វាយ និងដំណាំផ្សេងៗមានប្រមាណ ១១,២០៧ នាក់ ត្រូវនឹង ៧០%នៃប្រជាជនសរុបនៅក្នុងឃុំ ។

តារាងទី២.៣. ស្ថិតិប្រជាពលរដ្ឋក្នុងឃុំ ប្រចាំឆ្នាំ២០១៧

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋ | | ចំនួនប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី |
| ១ | ព្រៃកតាតិន | ៣៦០ | ១,៥៣៩ | ៨៣៩ | ៩៣៦ | ៤៣៦ |
| ២ | ឬស្សីជ្រោយ | ៤០៩ | ១,៩៨១ | ១,១៣៤ | ១,២៩៩ | ៧៣៥ |
| ៣ | ព្រៃកតាជ័រ | ៥៥៣ | ២,៦០៨ | ១,៣៤២ | ១,៣៩០ | ៦៩០ |
| ៤ | ព្រៃកតាសៅ | ៣៦៦ | ១,៥៧០ | ៨១៦ | ១,០៨០ | ៥៧៧ |
| ៥ | ចុងកោះគរ | ១៨២ | ៧៨៩ | ៤០៨ | ៥៤២ | ៣០០ |
| ៦ | បារ៉ែនលើ | ២២៥ | ៩៨២ | ៥៣១ | ៥១៥ | ៣៤៥ |
| ៧ | អូរំចេក | ២៣៤ | ១,០៣៥ | ៥៣២ | ៤៧៤ | ២៥១ |
| ៨ | បារ៉ែនក្រោម | ៦៨៥ | ៣,០៥០ | ១,៦១៧ | ២,០៤៦ | ១,១០៣ |
| ៩ | ពោធិតាប៉ាង | ៥៣៥ | ២,៤៥៦ | ១,២៦៩ | ១,២៧០ | ៦៦៥ |
| សរុប | | ៣,៥៤៩ | ១៦,០១០ | ៨,៤៨៨ | ៩,៥៥២ | ៥,១០២ |

ប្រភព៖ សាលាឃុំស្វាយប្រទាល ឆ្នាំ២០១៧

## ២.១.៤. ស្ថានភាពសេដ្ឋកិច្ច

### ២.១.៤.១. ស្ថានភាពមុខរបរប្រជាជនក្នុងឃុំស្វាយប្រទាល

តាមរយៈទិន្នន័យដែលប្រមូលបានពីថ្នាក់ឃុំ និងការសម្ភាសន៍ផ្ទាល់គឺ ប្រជាជននៅក្នុងឃុំភាគច្រើនជាកសិករដែលប្រកបរបរកសិកម្មបីសំខាន់គឺ ធ្វើស្រែ ធ្វើចម្ការ (ដាំដំណាំចេក ស្វាយ ដំណាំបន្លែ) ចិញ្ចឹមសត្វ និងនេសាទ កម្មករក្នុងវិស័យកសិកម្ម កម្មកររោងចក្រកាត់ដេរ ជាងជួសជុល ជាងកាត់ដេរ និងអាជីវករជាដើម។ ប្រជាពលរដ្ឋប្រមាណ ៧៥%ប្រកបរបរកសិកម្ម និង២៥%ប្រកបមុខរបរផ្សេងៗ។

**២.១.៤.២. ស្ថានភាពលំនៅដ្ឋាន**

លំនៅដ្ឋាន គឺជាជម្រកសម្រាប់មនុស្សស្នាក់អាស្រ័យនិងរស់នៅ ដែលអាចការពារមនុស្សពីភ្លៀង ខ្យល់ កម្ដៅថ្ងៃ និងសត្វសាហាវជាដើម។ ដូច្នេះ លំនៅដ្ឋានជាកន្លែងដ៏សំខាន់សម្រាប់មនុស្សគ្រប់គ្នា ហើយផ្ទះនីមួយៗគឺមានលក្ខណៈខុសគ្នាអាស្រ័យទៅតាមជីវភាពរស់នៅ និងចំណង់ចំណូលចិត្តរបស់គ្រួសារនីមួយៗ។ តាមការចុះដល់មូលដ្ឋានជាក់ស្ដែង ផ្ទះរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំស្វាយប្រទាល មានស្ថានភាពខុសគ្នាដូចជា តំបន់ដែលរស់ដៅតាមបណ្ដោយដងទន្លេ និងផ្លូវខេត្ត ភាគច្រើនជាផ្ទះថ្មជាប់ដីមានប្រក់ទីបការ៉ូ និងមានដាំដំណាំដូចជា ស្វាយ ខ្នុរ ជុំវិញផ្ទះ។ រីឯផ្ទះប្រជាជនដែលរស់នៅក្នុងភូមិដែលមិនជាប់ផ្លូវធំភាគច្រើន សង់ពីឈើផុតពីដីដែលប្រក់ក្បឿង និងស័ង្កសីមួយចំនួនតូច ហើយនៅជុំវិញផ្ទះមានដាំដើមស្វាយ ឬបន្លែផ្សេងៗ។

**២.១.៤.៣. ផ្នែកគមនាគមន៍**

ឃុំស្វាយប្រទាល ជាឃុំមួយដែលពុំមានផ្លូវជាតិឆ្លងកាត់ឃុំនោះឡើយ ប៉ុន្តែក្នុងឃុំនេះមានផ្លូវខេត្តរាជធានីឬក្រុងស្រុកខណ្ឌដែលឆ្លងកាត់ឃុំសង្កាត់ (ផ្លូវដែលស្ថិតក្រោមការគ្រប់គ្រងថ្នាក់ខេត្ត រាជធានីឬស្រុកខណ្ឌ)។ ផ្លូវនេះមានប្រវែង ៧,៧៨៥ ម៉ែត្រ ដែលភ្ជាប់ពីខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ រហូតដល់ព្រំដែនវៀតណាម ។ រីឯផ្លូវសរុបក្នុងឃុំស្វាយប្រទាលមានចំនួន ១០ខ្សែ ដែលមានប្រវែងសរុប ២៨,៣៣៣ ម៉ែត្រ រួមបញ្ចូលទាំងផ្លូវចាក់បេតុងប្រវែង ៣៥១ ម៉ែត្រ សម្រាប់ប្រជាពលរដ្ឋក្នុងឃុំធ្វើដំណើរ និងជួយសម្រួលដល់ការដឹកជញ្ជូនទំនិញ ក៏ដូចជាផលិតផលកសិកម្មមានបន្លែជាដើម។ តាមរយៈការចុះដល់មូលដ្ឋានឃុំស្វាយប្រទាលផ្ទាល់ ឃើញថាឃុំនេះនៅបណ្ដោយដងទន្លេមេគង្គ ហើយមិនមានស្ពានសម្រាប់ឆ្លងកាត់ឡើយ។ ក្រៅពីផ្លូវគោកដែលជាមធ្យោបាយធ្វើដំណើរ ក៏មានកំពង់ចម្លងមួយចំនួន (មានកំពង់ចម្លងអុងប៉ាងជាដើម) ដែលជាមធ្យោបាយសម្រាប់ប្រជាពលរដ្ឋក្នុងឃុំ និងឃុំផ្សេងៗទៀតដែលនៅជិតនោះ អាចចម្លង ឡាន ម៉ូតូ រ៉ឺម៉ក និងឈ្មួញដែលដឹកបន្លែយកមកលក់នៅទីផ្សារក្នុងរាជធានីភ្នំពេញជាដើម [27] ។

**២.១.៤.៤. ស្ថានភាពវិស័យកសិកម្ម**

តាមរយៈការចុះអង្កេតផ្ទាល់ ប្រជាជនរស់នៅក្នុងឃុំស្វាយប្រទាល ប្រកបរបរកសិកម្មដូចជាធ្វើស្រែ ធ្វើចម្ការ ចិញ្ចឹមសត្វ និងនេសាទជាលក្ខណៈគ្រួសារ។ បើតាមសំដីរបស់លោកអ៊ុំស្មៀនឃុំ និងទិន្នន័យថ្នាក់ឃុំ កសិកម្មខាងលើនេះជាផ្នែកមួយដ៏សំខាន់ដែលប្រជាកសិករនិយមធ្វើ។ កសិករ

[27] សៀវភៅទិន្នន័យឃុំ សង្កាត់៖ ឃុំស្វាយប្រទាល ឆ្នាំ២០១៦ (សម្រាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់)

ក្នុងឃុំភាគច្រើននិយមដាំណាំបន្លែជាងគេ។ ដំណាំបន្លែអំបូរស្ពៃ ជាប្រភេទដំណាំដែលមានអាយុកាលខ្លី ដែលកសិករអាចដាំដុះបានប្រមាណជាមធ្យម ៧ ដងក្នុងមួយឆ្នាំ(ព័ត៌មានសម្ភាសន៍)។ ការដាំបន្លែប្រភេទនេះឆាប់បានប្រមូលផល ងាយស្រួលដាំ និងចំណាយតិចជាង។ ក្រៅពីនេះ កសិករក្នុងឃុំ ខ្លះធ្វើស្រូវ ខ្លះមានដាំដំណាំផ្សេងទៀតដូចជា ស្វាយ ចេក ពោតជាដើម ខណៈដែលប្រជាពលរដ្ឋមួយចំនួនតូចពុំមានដីផ្ទាល់ខ្លួនសម្រាប់ធ្វើស្រែចម្ការឡើយ ហើយមុខរបរចិញ្ចឹមជីវិតរបស់ពួកគាត់គឺលក់កម្លាំងពលកម្មបម្រើឲ្យវិស័យកសិកម្ម។

## ២.២. ស្ថានភាពផលិតកម្មដំណាំបន្លែ

### ២.២.១. លក្ខណៈបច្ចេកទេសដាំដុះ

#### ២.២.១.១. ការរៀបចំដី

ដំណាំបន្លែ ទាមទារការរៀបចំដីយ៉ាងសំអិតសំអាងបំផុត។ ការរៀបចំដីសំដៅធ្វើឲ្យដីធូរ ស្អាតគ្មានស្មៅឬសត្វល្អិតចង្រៃ ស្រោះទឹកល្អ មានជីគ្រប់គ្រាន់ ដើម្បីធានាគុណភាពផលិតផល និងទិន្នផលសមស្រប។

ការរៀបចំដីរបស់កសិករត្រូវបានធ្វើឡើងតាមដំណាក់កាលដូចជា:

- ការភ្ជួររាស់: កសិករភាគច្រើនភ្ជួររាស់ដីដោយប្រើគោយន្ត ដោយពេលខ្លះភ្ជួរតែមួយសារក៏ធ្វើការដាំដុះ ហើយពេលខ្លះទៀតភ្ជួរពីរសារទើបធ្វើការដាំដុះអាស្រ័យដោយដីមានស្មៅតិចឬច្រើន។ ការភ្ជួររាស់ដីបានល្អបំផុតគឺនៅពេលដែលដីមិនសើមពេក ហើយក៏មិនស្ងួតពេក។
- ការសំអាតស្មៅ
- ការលើករង
- ការដាក់ជីគីមី ឬជីធម្មជាតិមុនពេលដាំ។

#### ២.២.១.២. ការជ្រើសរើសពូជ

ពូជជាកត្តាសំខាន់ក្នុងចំណោមកត្តាសំខាន់ដទៃទៀត។ កសិករដាំដុះបន្លែនៅឃុំស្វាយប្រទាលជ្រើសរើសពូជបន្លែសម្រាប់ធ្វើការដាំដុះដោយផ្អែកលើទម្លាប់។ ហើយពូជបន្លែដែលពួកគាត់ទម្លាប់និយមដាំដុះជាងគេមានដូចជា៖ ស្ពៃតឿ ស្ពៃចង្កឹះ ស្ពៃខ្មៅ ស្ពៃក្រញ៉ាញ់ សាលាដ ម្រះ ។ល។ នៅពេលដែលពួកគាត់ដាំបន្លែមួយប្រភេទនៅលើដីមួយកន្លែងពីរទៅបីដងជាប់ៗគ្នា ពួកគាត់នឹងផ្លាស់ទៅដាំបន្លែមួយប្រភេទផ្សេងទៀតទើបបន្លែលូតលាស់បានល្អ។ ចំណែកឯប្រភពដែលទទួលបានគ្រាប់ពូជទាំងនោះអាចជាការទិញមកពីផ្សារ ឬទុកពូជដោយខ្លួនឯង។

### ២.២.១.៣. ការដាំដុះ

បន្លែនៅឃុំស្វាយប្រទាល សុទ្ធសឹងដាំដុះដោយធ្វើការលើកជារងមុននឹងធ្វើការពង្រោះគ្រាប់ពូជទៅលើដី។ ការធ្វើការពង្រោះបែបនេះ អាចឲ្យបន្លែនៅកន្លែងខ្លះដុះច្រើនជ្រុល ហើយកន្លែងខ្លះទៀតពុំសូវមានដុះ ប៉ុន្តែបញ្ហានេះនឹងត្រូវបានដោះស្រាយនៅក្នុងដំណាក់កាលនៃការជម្រះស្មៅ។

បន្ទាប់ពីធ្វើការពង្រោះគ្រាប់ពូជរួច ពួកគាត់រាយចំបើងគ្របលើរងបន្លែដើម្បីកុំឲ្យដីឆាប់ហាប់ដោយសារការស្រោចទឹក រក្សាទឹក និងការពារកុំឲ្យស្មៅ ដុះច្រើន។

### ២.២.១.៤. ការថែទាំ

#### ក. ការជម្រះស្មៅ

ការជម្រះស្មៅ គឺធ្វើឡើងដើម្បីកុំឲ្យស្មៅរំខានដល់ការលូតលាស់ និងដណ្តើមជីពីដំណាំ ម្យ៉ាងទៀត ស្មៅក៏ជាជម្រករបស់សត្វល្អិតនិងជំងឺផងដែរ។ ក្នុងដំណាក់កាលនៃការថែទាំបន្លែ កសិករនៅឃុំស្វាយប្រទាលធ្វើការជម្រះស្មៅម្តងទៅពីរដងក្នុងមួយវដ្តផលិតកម្ម។ ពួកគាត់ជម្រះស្មៅតែម្តងប៉ុណ្ណោះករណីដែលចម្ការរបស់ពួកគាត់ពុំសូវមានស្មៅ ប៉ុន្តែក្នុងករណីដែលមានស្មៅច្រើន ពួកគាត់នឹងជម្រះស្មៅចំនួនពីរដងក្នុងមួយវដ្តផលិតកម្ម។

ចំណែកឯវិធីសាស្ត្រនៃការជម្រះស្មៅ គឺដោយដកនឹងដៃ។ ហើយការជម្រះស្មៅនេះ ពួកគាត់តែងជួលកម្លាំងពលកម្មបន្ថែម ដើម្បីជម្រះស្មៅឆាប់រួចរាល់ ទើបធ្វើឲ្យបន្លែលូតលាស់បានទាន់គ្នាល្អ។ ស្របពេលនឹងការជម្រះស្មៅ ពួកគាត់នឹងដកចោលនូវកូនបន្លែត្រង់កន្លែងដែលដុះក្រាស់ពេក និងស្ទូងបន្ថែមត្រង់កន្លែងដែលដុះស្តើងពេក។ ការធ្វើបែបនេះ ទើបអាចឲ្យបន្លែលូតលាស់បានល្អ។ គួរបញ្ជាក់ផងដែរថា កូនបន្លែដែលត្រូវបានដក ពេលខ្លះក៏មានឈ្មួញមកសុំទិញផងដែរក្នុងតម្លៃមួយដែលទាបជាងតម្លៃបន្លែដែលគ្រប់អាយុប្រមូលផល។

#### ខ. ការប្រើប្រាស់ជីធម្មជាតិ និងជីគីមី

តាមការសម្ភាសន៍ផ្ទាល់ ឃើញថា ប្រភេទជីដែលគ្រួសារកសិករចូលចិត្តប្រើប្រាស់នោះ គឺមានលក្ខណៈខុសប្លែកគ្នាទៅតាមប្រភេទបន្លែដែលពួកគាត់ជ្រើសរើសដាំ។ ដោយសារតែនៅក្នុងឃុំនេះភាគច្រើនកសិករដាំបន្លែអំបូរស្ពៃ ដូច្នេះនៅក្នុងការប្រើប្រាស់ជី គ្រួសារកសិករប្រើប្រាស់ទាំងជីគីមី និងជីធម្មជាតិ ដើម្បីរក្សាគុណភាពដី និងជួយជំនួយដល់ការលូតលាស់របស់បន្លែ។

- ប្រភេទជីលាមកសត្វ៖ កសិករច្រើនតែប្រើប្រាស់ជីលាមកសត្វនៅមុនពេលដាំ ដើម្បីធ្វើជាជីទ្រាប់បាតដី។ ជាទូទៅប្រើប្រាស់ជីលាមកសត្វនេះ មួយដងប៉ុណ្ណោះក្នុងមួយឆ្នាំ ហើយភាគច្រើនកសិករទិញជីនេះមានតម្លៃពី២៥០,០០០រៀល ទៅ៣០០,០០០រៀល ក្នុងមួយឡានតូច។

– ប្រភេទជីគីមី៖ ជីគីមីសំខាន់ៗដែលប្រជាកសិករចូលចិត្តប្រើប្រាស់ប្រាស់មានដូចជា ដេអាប៉េ អ៊ុយរេ សញ្ញាក្បាលក្របី ។ ជាទូទៅការដាក់ជីធ្វើឡើង ២ ទៅ ៣ដង ក្នុងមួយវគ្គជីវិតដំណាំបន្លែនីមួយៗ ក្នុងនោះជីទ្រាប់បាតពេលភ្ជួររាស់ និងលើករងរួចភាគច្រើនកសិករប្រើជី ដេអាប៉េ ទៅបាចលើរងនីមួយៗ។ ឯជីអ៊ុយរេសញ្ញាក្បាលក្របីវិញ កសិករប្រើពេលបន្លែពេលចេញដើម។

**គ. ការប្រើប្រាស់ថ្នាំពុលលើបន្លែ**

នៅក្នុងតំបន់ដែលបានសិក្សាផ្ទាល់ឃើញថា កសិករភាគច្រើន គឺប្រើប្រាស់ថ្នាំពុលស្ទើរតែទាំងស្រុង។ បើតាមកសិករដែលប្រើប្រាស់ថ្នាំពុលបានឲ្យដឹងថា ការប្រើប្រាស់ថ្នាំពុលលើដំណាំបន្លែ ប៉ះពាល់ខ្លាំងដល់សុខភាពរបស់ពួកគាត់ និងអ្នកប្រើប្រាស់ ប៉ុន្តែប្រសិនបើគាត់មិនប្រើថ្នាំពុលនោះទេ ធ្វើឲ្យពួកគាត់មិនទទួលបានទិន្នផលខ្ពស់នោះទេ គឺដោយសារមានការបំផ្លាញផលដំណាំពីសត្វល្អិតចង្រៃ។ ការប្រើប្រាស់ថ្នាំពុលនេះ គឺប្រើនៅពេលមានសត្វល្អិតបំផ្លាញដំណាំតែប៉ុណ្ណោះ។ កសិករបានបន្ថែមថា គាត់ច្រើនបាញ់ថ្នាំនៅពេលព្រឹក និងពេលល្ងាច ពីព្រោះនៅពេលព្រឹកមានអាកាសធាតុត្រជាក់ ធ្វើឲ្យថ្នាំមានប្រសិទ្ធភាព ចំណែកឯពេលល្ងាចវិញគឺអាកាសធាតុត្រជាក់ផងដែរ ហើយថែមទាំងនៅពេលយប់ក៏មានសត្វបំផ្លាញ។

**២.២.២. រដូវដាំដុះបន្លែ**

រដូវកាល គឺសំខាន់ណាស់សម្រាប់ការដាំដុះដំណាំនីមួយៗ។ កាលណាកសិករ កំណត់រដូវកាលនៃការដាំដុះបានត្រឹមត្រូវនោះវាក៏ជួយឲ្យដំណាំទទួលបានផលល្អ ប៉ុន្តែវាក៏អាស្រ័យទៅតាមប្រភេទដំណាំផងដែរ។ ជាក់ស្តែងបន្ទាប់ពីការសម្ភាសន៍កសិករ ទាក់ទងនឹងពេលវេលានៃការដាំដុះ គឺប្រជាកសិករធ្វើការដាំពេញមួយឆ្នាំតែម្តងគឺទាំងរដូវប្រាំង និងរដូវវស្សា ពីព្រោះពួកគាត់យកការដាំបន្លែជាមុខរបរប្រចាំគ្រួសារ និងជាពិសេសពួកគាត់មានប្រភពទឹកដែលអាចផ្គត់ផ្គង់ការស្រោចស្រពបានគ្រប់រដូវ។ ការដាំបន្លែអំបូរស្ពៃនេះមានរយៈពេលខ្លី ដែលមួយវដ្តផលិតកម្ម ចំពោះប្រភេទស្ពៃតឿ ស្ពៃចង្កឹះ និងស្ពៃខ្មៅ មានរយៈពេលដាំជាមធ្យមក្នុងរង្វង់ ៣០ថ្ងៃ តែក្នុងករណីបន្លែលូតលាស់បានល្អ កសិករអាចប្រមូលផល ៤ ទៅ ៥ថ្ងៃមុនអាយុកាល និងក្នុងករណីបន្លែលូតលាស់មិនសូវល្អ កសិករអាចពន្យារពេលប្រមូលផល ៤ ទៅ ៥ថ្ងៃលើសអាយុកាល។ រីឯស្ពៃក្រញ៉ាញ់មានរយៈពេលយូរជាងគេដែលអាចឈានដល់ ១ខែ កន្លះ។ នារដូវប្រាំង ការដាំបន្លែភាគច្រើនទទួលបានទិន្នផលខ្ពស់ជាងការដាំនារដូវវស្សា ពីព្រោះនៅរដូវប្រាំងមានពន្លឺថ្ងៃគ្រប់គ្រាន់ ធ្វើឲ្យបន្លែលូតលាស់បានល្អ ពុំសូវមានជំងឺ និងពុំសូវរងការបំផ្លាញពីសត្វល្អិតចង្រៃ។ ឯរដូវវស្សាវិញ ពន្លឺថ្ងៃមិនសូវគ្រប់គ្រាន់ បន្លែរងការបំផ្លាញខ្លាំងពីសត្វល្អិតចង្រៃនិងជំងឺ ហើយភ្លៀងធ្លាក់ច្រើនជ្រុលក៏ប៉ះពាល់ដល់ការលូតលាស់របស់បន្លែផងដែរ។

### ២.២.៣. ប្រភពទឹកស្រោចស្រព

ទឹក ជាប្រភពមួយដ៏សំខាន់បំផុតសម្រាប់ប្រជាកសិករដែលប្រកបរបរកសិកម្ម ក្នុងការស្រោចស្រពដំណាំរបស់ខ្លួន។ រុក្ខជាតិ ឬដំណាំមិនអាចខ្វះទឹកបានឡើយ ប្រសិនបើខ្វះទឹក នោះការដុះលូតលាស់របស់ដំណាំនឹងមានផលប៉ះពាល់ជាមិនខានឡើយ។ យ៉ាងណាមិញ យោងទៅតាមការចុះសិក្សាស្រាវជ្រាវនៅមូលដ្ឋានបានបង្ហាញថា ប្រជាកសិករនៅឃុំស្វាយប្រទាលទាំងមូល ទោះបីជារស់នៅតាមបណ្តោយដងទន្លេបាសាក់ក៏ដោយ ក៏ដំណាំបន្លែរបស់ពួកគាត់មិនបានប្រើប្រាស់ប្រភពទឹកទន្លេទេ គឺកសិករប្រើប្រាស់ទឹកអណ្តូងជីកផ្ទាល់ខ្លួន ដើម្បីស្រោចស្រពដំណាំបន្លែរបស់ពួកគាត់ ។ ដោយសារការប្រើប្រាស់អណ្តូងមានភាពងាយស្រួល អាចជីកនៅក្បែរផ្ទះ នៅជិតចម្ការបន្លែ និងអាចផ្គត់ផ្គង់គ្រប់គ្រាន់ គ្រប់រដូវ រួមទាំងអាចទាញមកប្រើប្រាស់ផ្សេងៗក្រៅពីការដាំដុះបន្លែផងដែរ។

### ២.២.៤. ការប្រមូលផល

ការប្រមូលផលធ្វើឡើងក្នុងអំឡុងពេលដែល បន្លែតាមប្រភេទនីមួយៗដល់អាយុប្រមូលផលអាច ២៥ថ្ងៃ ២៨ថ្ងៃ ៣៥ថ្ងៃក្រោយករដាំដុះ និងអាចឈានដល់៤៥ថ្ងៃសម្រាប់ស្ពៃក្រញ៉ាញ់ គឺនៅពេលដែលកសិករឃើញថា បន្លែរបស់ខ្លួនដល់អាចប្រមូលផលបាន និងមានការត្រូវថ្លៃជាមួយឈ្មួញ។ កសិករប្រើពេល ១ថ្ងៃ ទៅ២ថ្ងៃ ឬក៏៣ថ្ងៃ ទៅតាមទំហំដីដែលបានដាំ និងតម្រូវការឈ្មួញ ដើម្បីប្រមូលផលបន្លែឲ្យអស់ពីចម្ការ។

ចំពោះមធ្យោបាយដែលប្រើប្រាស់សម្រាប់ប្រមូលផល គឺប្រើកូនកាំបិតតូចៗមកកាត់ដើមបន្លែពីដីតាមរងនីមួយៗ ដោយយកចេញនូវដើម ឬស្លឹកណាដែលខូច បន្ទាប់មកមានអ្នកចាំប្រមូលច្រកថង់ដើម្បីកុំឲ្យស្វិត និងដើម្បីងាយស្រួលថ្លឹងគីឡូ។ រីឯកាដឹកជញ្ជូនមិនពិបាកឡើយ ពីព្រោះចម្ការភាគច្រើននៅជិតផ្ទះកសិករ ហើយភាពងាយស្រួលជាងនេះ គឺពេលខ្លះកសិករមិនចាំបាច់ដឹកទៅផ្ទះនោះទេ ប្រសិនបើពួកគាត់សម្រេចចិត្តលក់ទៅឲ្យឈ្មួញដោយគ្រាន់តែយល់ព្រមលក់ (មៅដល់ចម្ការ) ក្នុងតម្លៃណាមួយដែលបានព្រមព្រៀងគ្នា។ បន្ទាប់មកបន្លែត្រូវបានកាត់ពីចម្ការ និងដឹកជញ្ជូនដោយឈ្មួញកណ្តាលដោយខ្លួនឯងតែម្តង ហើយរាល់ការចំណាយក្នុងការកាត់បន្លែគឺជាបន្ទុករបស់ឈ្មួញ។

### ២.២.៥. ប្រភពដើមទុន

ដើមទុន មានសារៈសំខាន់ណាស់ក្នុងផលិតកម្មបន្លែ ព្រោះថាទុនជាប្រភពដែលបង្កើតឲ្យមាននូវដំណើរការនៃការផលិត សម្រាប់ធានាឲ្យមានស្ថេរភាព ក៏ដូចជាការរីកចម្រើនរបស់កសិដ្ឋាន។

ប្រសិនបើដើមទុនមិនគ្រប់គ្រាន់ ឬខ្វះខាតទុន នោះនឹងមានផលប៉ះពាល់ខ្លាំងដល់ដំណើរការផលិតកម្មជាក់ជាមិនខាន ព្រោះបើមិនមានទុនគ្រប់គ្រាន់ក្នុងការទិញពូជ ការផ្គត់ផ្គង់ជី ថ្នាំ និងជាពិសេសការថែទាំមិនដិតដល់ នាំឲ្យដំណាំបន្លែមិនទទួលបានទិន្នផលខ្ពស់នោះទេ។ តាមរយៈការសម្ភាសន៍ផ្ទាល់នៅតំបន់សិក្សាស្រាវជ្រាវឃើញថា ដើមទុនសម្រាប់ការវិនិយោគលើការដាំដុះបន្លែកសិករភាគច្រើនប្រើប្រាស់ទុនផ្ទាល់ខ្លួន និងមួយចំនួនតូចប្រើទុនខ្លួនឯងខ្លះ រួមនឹងការទិញជី ថ្នាំ ពីអ្នកលក់ដោយជំពាក់សិន ហើយនឹងសងត្រឡប់ទៅវិញនៅពេលប្រមូលផលរួច ។

## ២.២.៦. ស្ថានភាពទីផ្សារបន្លែ

### ២.២.៦.១.ទីផ្សារបន្លែ

ទីផ្សារ ជាកន្លែងបញ្ចាក់ពីប្រភេទទំនិញ និងជាកន្លែងដោះដូរផលិតផល រវាងអ្នកទិញ និងអ្នកលក់ក្នុងតំបន់ភូមិសាស្ត្រណាមួយ និងនៅក្នុងរយៈពេលកំណត់ណាមួយ ដែលជាសេចក្តីត្រូវការរបស់អ្នកទិញ និងកំណត់តម្លៃមួយសមរម្យរវាងអ្នកលក់និងអ្នកទិញ។ យោងតាមការចុះសិក្សាស្រាវជ្រាវនៅឃុំស្វាយប្រទាលនេះបានបង្ហាញថា បន្លែអំបូរស្ពៃដែលកសិករដាំបាន ភាគច្រើនលក់នៅចម្ការផ្ទាល់ ដោយមានឈ្មួញកណ្តាលមកទិញដល់កន្លែង។ ការលក់បន្លែនៅចម្ការតម្លៃអាចទាបជាងការដែលកសិករយកទៅលក់នៅទីផ្សារដោយខ្លួនឯង ប៉ុន្តែកសិករសម្រេចចិត្តលក់ ព្រោះបើគិតទៅលើថ្លៃឈ្នួលដឹកជញ្ជូន និងពេលវាលាទៅមក ក៏មិនខុសគ្នាប៉ុន្មានដែរ។ ពីព្រោះថា បើគាត់លក់ឲ្យឈ្មួញដែលមកទិញដល់កន្លែង ក៏គាត់អាចចំណេញពេលវាលាសម្រាប់រៀបចំដី ដើម្បីដាំបន្លែឡើងវិញដែរ។ ទន្ទឹមនឹងនេះផងដែរ ក៏មានគ្រួសារមួយចំនួនតូច បានដឹកយកបន្លែស្ពៃទៅលក់នៅទីផ្សារដោយខ្លួនឯងផងដែរ ព្រោះថាគាត់មានដីចម្ការតូចល្មម ក្នុងការដាំដុះសារឡើងវិញ និងមានសមាជិកគ្រួសារច្រើនជួយមើលការខុសត្រូវ ឬយកលក់ទៅទីផ្សារដោយសោហ៊ុយដឹកជញ្ជូនចំណាយតិច។ ម្យ៉ាងទៀត កសិករមិនចង់ខាតបង់នូវប្រាក់ចំណេញពីការបោះដុំឲ្យឈ្មួញនៅចម្ការ ហេតុនេះហើយ ទើបពួកគាត់យកបន្លែរបស់ខ្លួនទៅលក់នៅទីផ្សារដោយខ្លួនឯង។

តាមការសម្ភាសន៍កសិករផ្ទាល់ អំពីរដូវកាលដែលបន្លែអំបូរស្ពៃនេះមានតម្លៃថ្លៃខ្ពស់បំផុតឬទាបបំផុតនោះគឺពួកគាត់បានមានប្រសាសន៍ថា រយៈពេលពីរឆ្នាំចុងក្រោយនេះគាត់មិនអាចកំណត់បានពីខែណាមួយជាក់លាក់នោះទេ ព្រោះតែតម្លៃប្រែប្រួលតាមការផ្គត់ផ្គង់បន្លែលើទីផ្សារ។ ប៉ុន្តែកាលពីមុនបន្លែអំបូរស្ពៃមានតម្លៃថ្លៃ ភាគច្រើននៅចុងរដូវប្រាំង ក្នុងអំឡុងខែមីនា និងខែមេសា ពីព្រោះរយៈពេលនេះ តំបន់ដាំដុះបន្លែមួយចំនួននៅក្នុងប្រទេស ចាប់ផ្តើមខ្វះខាតទឹកសម្រាប់ស្រោចស្រព ជាហេតុនាំឲ្យការផ្គត់ផ្គង់បន្លែនៅលើទីផ្សារថយចុះនិងថ្លៃកើនឡើង។ រីឯក្នុងរដូវវស្សាវិញ បន្លែអាចលក់បានថ្លៃភាគច្រើននៅក្នុងអំឡុងខែឧសភា និងខែមិថុនា ព្រោះរដូវប្រាំងទើបតែ

បញ្ចប់ ហើយពុំទាន់មានភ្លៀងធ្លាក់ច្រើននៅឡើយ ធ្វើឲ្យតំបន់ខ្លះនៅតែខ្វះខាតទឹកសម្រាប់ស្រោចស្រព បណ្តាលឲ្យខ្វះការផ្គត់ផ្គង់ ពេលនោះឈ្មួញកណ្តាលចាប់ផ្តើមតម្លើងថ្លៃបន្លែ ដែលអាចឈានទៅដល់ ៥,០០០រៀល ក្នុងមួយគីឡូក្រាម។ កសិករបានបន្ថែមទៀតថា បើទោះបីជាថ្លៃបន្លែមានការប្រែប្រួលឡើងចុះខ្លាំងក៏ដោយ ក៏កសិករមិនកាត់បន្ថយការដាំបន្លែនោះដែរ ពីព្រោះវាជាមុខរបររបស់ពួកគាត់។

**២.២.៦.២. បណ្តាញបែងចែកផលិតផលដំណាំបន្លែ**

ផលិតផលបន្លែដែលកសិករនៅឃុំស្វាយប្រទាលដាំបាន គឺត្រូវបានចែកចាយ ផ្តើមពីម្ចាស់ចម្ការដែលធ្វើការលក់ផលិតផលរបស់ខ្លួនទៅឲ្យឈ្មួញកណ្តាលដែលមកទិញដល់ចម្ការ។ ក្នុងការទិញបន្លែរបស់ឈ្មួញមួយចំនួន បានធ្វើការប្រមូលទិញពីកសិករក្នុងបរិមាណតិចតួច ដើម្បីលក់បន្តទៅឲ្យឈ្មួញផ្សេងទៀតដែលទិញក្នុងបរិមាណច្រើន។ ចំណែកឯឈ្មួញខ្លះទៀត ទិញដោយមៅដល់ចម្ការតែម្តង ដើម្បីយកទៅផ្គត់ផ្គង់ទីផ្សារជាលក្ខណៈបោះដុំ។

ការបែងចែកផលដំណាំបន្លែនៅក្នុងឃុំស្វាយប្រទាល ជាផ្នែកតូចមួយនៃការជួយផ្គត់ផ្គង់តម្រូវការទីផ្សាររបស់ប្រទេសកម្ពុជា។ បន្លែរបស់កសិករក្នុងឃុំនេះ ត្រូវបានចែកចាយទៅតាមទីផ្សារក្នុងតំបន់មួយចំនួន ហើយបន្ទាប់មកនាំយកទៅទីផ្សាររួមមួយចំនួនដែរ ដើម្បីបំពេញតម្រូវការអ្នកប្រើប្រាស់ចុងក្រោយក្នុងប្រទេសកម្ពុជា។

គំនូសបំព្រួញទី១៖ ការបង្ហាញអំពីការបែងចែកបន្លែទៅទីផ្សាររបស់កសិករ



**២.២.៦.៣. បញ្ហាទីផ្សារបន្លែរបស់កសិករក្នុងឃុំស្វាយប្រទាល**

ការសិក្សាលើផ្នែកផលិតកម្មបន្លែ បានបង្ហាញថាទីផ្សារមានតួនាទីសំខាន់ក្នុងផលិតកម្មបន្លែ។ តំបន់ផលិតកម្មបន្លែខុសគ្នា តម្លៃរបស់បន្លែក៏មានលក្ខណៈខុសគ្នាផងដែរ និងមានការប្រែប្រួលតម្លៃពីរដូវមួយទៅរដូវមួយ។ ហើយការប្រែប្រួលកើនឡើង ឬធ្លាក់ចុះតម្លៃបន្លែនៅលើទីផ្សារ ដោយសារមានតម្រូវការ និងការផ្គត់ផ្គង់បន្លែនៅលើទីផ្សារ និងការខ្វះខាតព័ត៌មានទីផ្សារ។ ម្យ៉ាងទៀត តាមការសម្ភាសន៍អំពីថ្លៃបន្លែ កសិករភាគច្រើនលក់បានក្នុងតម្លៃថោកក្នុងរយៈពេលពីរឆ្នាំនេះចុងក្រោយនេះ ដោយសារមានការនាំចូលបន្លែពីប្រទេសជិតខាងច្រើនលើសលុប នាំឲ្យបន្លែមានតម្លៃធ្លាក់ចុះខ្លាំង។ ពេលខ្លះ ក្នុងមួយថ្ងៃថ្លៃបន្លែអាចធ្លាក់ចុះពីជាង ២,០០០ រៀល/គ.ក មកនៅត្រឹមថ្លៃ ក្រោម ១,០០០ រៀល/គ.ក ហើយថ្លៃក៏អាចកើនឡើងវិញរហូតដល់ជាង ២,០០០ រៀល/គ.ក និងពេលខ្លះឈានទៅដល់ជាង ៣,០០០ រៀល/គ.ក ថែមទៀតផង។

ការនាំចូលបន្លែពីប្រទេសជិតខាង ក្នុងបរិមាណកាន់តែច្រើន ធ្វើឲ្យប្រជាកសិករទទួលបានផលចំណេញកាន់តែតិច ឬស្ទើរតែមិនចំណេញ និងអាចឈានដល់ការខាតបង់ថែមទៀតផង។

**២.២.៦.៤. ដំណោះស្រាយបញ្ហាទីផ្សារ**

ថ្លៃបន្លែនៅលើទីផ្សារ ជាធម្មតាមានការប្រែប្រួលខ្លាំង និងឆាប់រហ័ស។ ជាការឆ្លើយតបទៅនឹងបញ្ហានេះ កសិករនៅឃុំស្វាយប្រទាល ធ្វើការដាំដុះនូវប្រភេទបន្លែលើសពីមួយប្រភេទ។ កសិករខ្លះ ធ្វើការដាំដុះបន្លែពីរប្រភេទក្នុងពេលដំណាលគ្នា និងខ្លះទៀតធ្វើការដាំដុះរហូតដល់ទៅបីប្រភេទ។ មូលហេតុដែលពួកគាត់ធ្វើការដាំដុះបែបនេះ ដោយសារតែឆ្លងតាមបទពិសោធន៍ជាច្រើនឆ្នាំកន្លងមក នៅពេលថ្លៃបន្លែមួយប្រភេទមានការធ្លាក់ចុះខ្លាំង ថ្លៃបន្លែប្រភេទផ្សេងទៀតអាចនៅមានតម្លៃថ្លៃគួរសមដែលអាចទទួលយកបាន។ ក្នុងករណីនេះ បើសិនបន្លែប្រភេទណាមួយដែលពួកគាត់ដាំ លក់បានក្នុងតម្លៃទាបខ្លាំង ធ្វើឲ្យប្រាក់ចំណេញទទួលបានតែបន្តិចបន្តួច នោះគាត់នៅអាចទទួលបានប្រាក់ចំណេញសមល្មម ពីការលក់បន្លែប្រភេទផ្សេងទៀត ដែលមានតម្លៃថ្លៃជាង។ ក្រៅពីនេះ កសិករពុំមានដំណោះស្រាយអ្វីផ្សេងទៀតឡើយ ក្រៅពីការរំពឹងរង់ចាំការជួយសម្របសម្រួលពីសំណាក់រាជរដ្ឋាភិបាល អង្គការនានា និងស្ថាប័នដែលពាក់ព័ន្ធ ដើម្បីឲ្យផលបន្លែដែលពួកគាត់អាចលក់បានក្នុងតម្លៃសមស្របមួយដែលអាចទទួលយកបាន។

# ជំពូកទី ៣
# ការវិភាគទិន្នន័យ
# និងលទ្ធផលស្រាវជ្រាវ

# ជំពូកទី ៣

# ការវិភាគទិន្នន័យ និងលទ្ធផលស្រាវជ្រាវ

តាមរយៈការបកស្រាយជំពូកទី១ និងជំពូកទី២ មក អាចធ្វើឲ្យយើងយល់កាន់តែច្បាស់នូវទ្រឹស្តី និងស្ថានភាពទូទៅនៃការដាំដំណាំបន្លែនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល។ តទៅនេះ នឹងមានការបកស្រាយពន្យល់អំពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែរបស់គ្រួសារកសិករនៅទីនោះថាតើ តើកសិករ ត្រូវការចំណាយជាមធ្យមប៉ុន្មាន នៅក្នុងមួយវដ្តផលិតកម្មដំណាំបន្លែ? តើកសិករអាចទទួលបានប្រាក់ចំណូលសរុបជាមធ្យមប៉ុន្មាន នៅក្នុងមួយវដ្តផលិតកម្មដំណាំបន្លែ? តើកសិករអាច ទទួលបានប្រាក់ចំណេញសរុបជាមធ្យមចំនួនប៉ុន្មាន នៅក្នុងមួយវដ្តផលិតកម្មដំណាំបន្លែ?

ដើម្បីទទួលបានព័ត៌មាន និងទិន្នន័យសម្រាប់យកមកបកស្រាយពន្យល់ កម្រងសំណួរមួយចំនួនត្រូវបានប្រើសម្រាប់សម្ភាសន៍កសិករ ដែលជាមេគ្រួសារនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ដោយបានជ្រើសរើសគ្រួសារទាំងអស់ចំនួន ២០ គ្រួសារ មកធ្វើការសម្ភាសន៍។

ខាងក្រោមនេះ ជាទិន្នន័យដែលទទួលបានក្រោយពីការសម្ភាសន៍។

## ៣.១. ទិន្នន័យប្រជាសាស្ត្រ

### ៣.១.១. ទិន្នន័យមេគ្រួសារ

#### ៣.១.១.១. ភេទ

តារាងទី៣.១៖ ការបង្ហាញពីភេទរបស់កសិករដែលជាមេគ្រួសារ

| ភេទ | ចំនួនគ្រួសារ | គិតជាភាគរយ |
|---|---|---|
| ប្រុស | ១១ | ៥៥% |
| ស្រី | ៩ | ៤៥% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេត ឆ្នាំ២០១៧

តារាងខាងលើបង្ហាញថា ក្នុងចំណោមគ្រួសារកសិករទាំង ២០ គ្រួសារ មានមេគ្រួសារជាស្ត្រីដល់ទៅ ៩ គ្រួសារ ដែលស្មើនឹង ៤៥% នៃការធ្វើសម្ភាសន៍ ខណៈដែលគ្រួសារភាគច្រើនមានមេគ្រួសារជាបុរស ដែលជាអ្នកទទួលខុសត្រូវចំពោះការរកចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ។

**៣.១.១.២. ក្រុមអាយុ**

អាយុត្រូវបានធ្វើការបែងចែកដើម្បីរកចំណុចរួមមួយនៃការវិវត្តនៃវ័យ ដែលក្នុងនោះអាចបង្ហាញឲ្យឃើញអំពីស្ថានភាពជាក់ស្តែងនៃកម្លាំងកាយ និងកម្លាំងប្រាជ្ញាដែលបានវិវត្តទៅមុខឥតឈប់ឈរ។ អាយុ គឺជាកត្តាសំខាន់ណាស់សម្រាប់កសិករដែលបម្រើឲ្យផលិតកម្មកសិកម្ម ព្រោះកាលណាអាយុកាន់តែចាស់កម្លាំងក៏កាន់តែខ្សោយ ដែលអាចធ្វើឲ្យផលិតភាពមានការថយចុះ។ នៅក្នុងការប្រកបរបរកសិកម្ម គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើកម្លាំងកាយ ដែលអាចនិយាយបានថាកម្លាំងកាយមានឥទ្ធិពលខ្លាំងទៅលើទិន្នផលបន្លែ។ រីឯបទពិសោធន៍ និងប្រាជ្ញាវិញ ជាកត្តាជម្រុញបន្ថែមទៅលើកម្លាំងកាយដើម្បីបង្កើនផលិតភាព។ ជាងនេះទៅទៀត តាមរយៈបទពិសោធន៍និងប្រាជ្ញា កសិករអាចរិះរកវិធីងាយជាងមុននៅក្នុងការដាំដុះបន្លែ ការថែទាំដ៏មានប្រសិទ្ធភាព ការបង្កើនទាំងបរិមាណ និងគុណភាពបន្លែ រួមទាំងវិធីសាស្ត្រដែលអាចធ្វើឲ្យបន្លែអាចលក់បានក្នុងតម្លៃមួយសមរម្យទៀតផង។

តារាងខាងក្រោមនេះ សិក្សាអំពីអាយុនៃមេគ្រួសារ ដែលប្រកបរបរដាំបន្លែដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារទាំងមូលតាមរយៈការងារពីកម្លាំងកាយ។

តារាងទី៣.២ ៖ ការបង្ហាញពីក្រុមអាយុរបស់កសិករដែលជាមេគ្រួសារ

| ក្រុមអាយុនៃមេគ្រួសារ | ចំនួនគ្រួសារ | គិតជាភាគរយ |
|---|---|---|
| ២០ - ៣០ ឆ្នាំ | ១ | ៥% |
| ៣០ - ៤០ ឆ្នាំ | ៥ | ២៥% |
| ៤០ - ៥០ ឆ្នាំ | ៣ | ១៥% |
| ៥០ - ៦០ ឆ្នាំ | ៨ | ៤០% |
| ៦០ ឆ្នាំ ឡើងទៅ | ៣ | ១៥% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេត ឆ្នាំ២០១៧

តារាងខាងលើ បង្ហាញអំពីក្រុមអាយុនៃមេគ្រួសារ ដែលចង់សំដៅទៅលើអាយុនៃកសិករដែលអាចធ្វើការពេញលេញ និងអាយុដែលមិនសូវសកម្មក្នុងការដាំដុះបន្លែ។ ក្រុមអាយុ ត្រូវបានបែងចែកជា ៥ ក្រុមផ្សេងៗគ្នា ដែលក្នុងនោះ កសិករជាមេគ្រួសារដែលមានអាយុចន្លោះពី ២០ឆ្នាំ ទៅ ៣០ឆ្នាំ មានចំនួន ១គ្រួសារ ស្មើនឹង ៥% អាយុចន្លោះពី ៣០ឆ្នាំ ទៅ ៤០ឆ្នាំ មានចំនួន ៥គ្រួសារ ស្មើនឹង ២៥% អាយុចន្លោះពី ៤០ឆ្នាំ ទៅ ៥០ឆ្នាំ មានចំនួន ៣គ្រួសារ ស្មើនឹង ១៥% អាយុចន្លោះពី

៥០ឆ្នាំ ទៅ ៦០ឆ្នាំ មានចំនួន ៨គ្រួសារ ស្មើនឹង ៤០% និងអាយុចាប់ពី ៦០ឆ្នាំឡើងទៅ មានចំនួន ៣ គ្រួសារ ស្មើនឹង ១៥% នៃគ្រួសារសរុបដែលធ្វើការសម្ភាសន៍។ តាមតួលេខនេះ បញ្ជាក់ថា មេគ្រួសារ ដែលមានអាយុចន្លោះពី ៥០ឆ្នាំ ទៅ ៦០ឆ្នាំ មានចំនួនច្រើនជាងគេ ហើយកសិករដែលមានអាយុ ស្ថិតនៅក្នុងចន្លោះនេះ គឺសុទ្ធសឹងជាកសិករដែលពោរពេញទៅដោយបទពិសោធន៍ និងជំនាញក្នុង ការធ្វើកសិកម្ម ក៏ប៉ុន្តែកម្លាំងរាងកាយរបស់ពួកគាត់មានការថមថយហើយ។

### ៣.១.២. ចំនួនសមាជិកគ្រួសារ

ជឿថាចំនួនសមាជិកគ្រួសារ បានបង្ហាញពីការចូលរួមជួយសម្រាលបន្ទុកក្នុងការងារ កសិកម្មរបស់កសិករដែលត្រូវការកម្លាំងពលកម្មច្រើនក៏ពិតមែន ប៉ុន្តែការជួយសម្រាលបន្ទុកអាចធ្វើ ឡើងបាននៅពេលដែលកូនៗរបស់ពួកគាត់ពេញវ័យប៉ុណ្ណោះ។

គុណសម្បត្តិនៃចំនួនសមាជិកគ្រួសារច្រើន សម្រាប់គ្រួសារដែលប្រកបរបរដាំដុះដំណាំបន្លែ គឺមានកម្លាំងពលកម្មច្រើនដើម្បីចូលរួមក្នុងផលិតកម្មបន្លែ និងមានអ្នកជួយរកចំណូលបន្ថែមចូល ក្នុងគ្រួសារ នៅពេលដែលពួកគាត់មានសមត្ថភាពស្វែងរកប្រាក់ចំណូល។ ជាក់ស្តែងគ្រួសារដែល មានសមាជិកច្រើន ហើយគ្រប់គ្នាសុទ្ធសឹងតែពេញកម្លាំងពលកម្ម ពោលគឺគ្រួសារដែលមានកម្លាំង ពលកម្មច្រើន ពួកគាត់អាចដាំនិងថែទាំបន្លែបានយ៉ាងល្អ និងកាត់បន្ថយការចំណាយទៅលើការ ជួលកម្លាំងពលកម្មបន្ថែមនៅក្នុងដំណាក់កាលចាំបាច់មួយចំនួន ជាពិសេសគឺនៅពេលធ្វើការជម្រះ ស្មៅនិងពេលប្រមូលផល។ មិនតែប៉ុណ្ណោះ ពេលទំនេរពីការងារដាំដុះនិងថែទាំបន្លែ ពួកគាត់អាច ស៊ីឈ្នួលជម្រះស្មៅ កាត់បន្លែ បាញ់ថ្នាំ រាយចំបើង និងលើករងបន្លែផងដែរ។ លើសពីនេះទៅទៀត ពួកគាត់នៅអាចប្រកបរបរបន្ទាប់បន្សំដូចជាចិញ្ចឹមសត្វ និងនេសាទថែមទៀតផង។

ទោះបីជាការមានសមាជិកគ្រួសារច្រើន មានគុណសម្បត្តិជាច្រើនដូចបានរៀបរាប់ខាងលើ ក្តី ទន្ទឹមនឹងនេះ វាក៏បានលេចចេញនូវគុណវិបត្តិព្រមគ្នាផងដែរ។ ការមានសមាជិកគ្រួសារច្រើន ក៏ មានផលប៉ះពាល់ដល់ការប្រកបរបរដាំដុះបន្លែដែរ ពីព្រោះតែសមាជិកគ្រួសារច្រើនអាចជាមនុស្ស ចាស់ជរា និងក្មេងតូចៗ ដែលតម្រូវឲ្យមានការចំណាយពេលវេលា និងថវិកាក្នុងការមើលថែពួកគាត់ ធ្វើឲ្យគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការដាំដុះនិងថែទាំបន្លែ ហើយក៏ជាសញ្ញាមួយបញ្ជាក់ឲ្យឃើញថា ចំណាយអាចច្រើនជាងចំណូល។ ហេតុនេះហើយមេគ្រួសារត្រូវត្រៀមខ្លួន ត្រៀមថវិកាដើម្បីផ្គត់ផ្គង់ លើការចំណាយរបស់សមាជិកគ្រួសារ ទៅតាមស្ថានភាពជាក់ស្តែងនៃទំហំគ្រួសារ។

"គ្រួសារតូចចំណាយតិច គ្រួសារកាន់តែធំចំណាយកាន់តែច្រើន"។

ដោយសារតែទំហំនៃគ្រួសារមានទាំងគុណសម្បត្តិ និងគុណវិបត្តិ ដូច្នេះទើបធ្វើឲ្យស្ថានភាព

ជីវភាពគ្រួសារនីមួយៗមានលក្ខណៈមិនដូចគ្នា។ ប៉ុន្តែគ្រួសារខ្លះ មានជីវភាពធូរធារដោយសារការមានសមាជិកច្រើន រីឯគ្រួសារខ្លះទៀតមានជីវភាពមិនធូរធារទៅវិញដោយសារតែមានសមាជិកគ្រួសារតិច ពេលខ្លះក៏អាចមកពីកេរតំណពីដូនតាមិនសូវសំបូរបែបពោលគឺដីសម្រាប់ដាំដុះពុំសូវមានជីជាតិ ឬក៏មានទំហំតូច។

ខាងក្រោមនេះ គឺជាតារាងដែលបង្ហាញអំពីសមាជិកគ្រួសារកសិករដាំដុះបន្លែនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល។

តារាងទី៣.៣ ៖ ការបង្ហាញអំពីសមាជិកគ្រួសារកសិករ

| ប្រភេទសមាជិកគ្រួសារ | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ២-៣ នាក់ | ៤ | ២០% |
| ៤-៥ នាក់ | ៨ | ៤០% |
| ៦-៧ នាក់ | ៦ | ៣០% |
| ៨-៩ នាក់ | ២ | ១០% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេត ឆ្នាំ២០១៧

តារាងខាងលើបង្ហាញថា ក្នុងចំណោមគ្រួសារសរុបដែលធ្វើការសម្ភាសន៍ គ្រួសារដែលមានសមាជិកតិចជាងគេ គឺចន្លោះពី ២នាក់ ទៅ៣នាក់ មានចំនួន ៤គ្រួសារ ស្មើនឹង ២០% មានសមាជិកគ្រួសារចន្លោះពី ៤នាក់ ទៅ៥នាក់ មានចំនួន ៨គ្រួសារ ស្មើនឹង ៤០% មានសមាជិកគ្រួសារចន្លោះពី ៦នាក់ ទៅ៧នាក់ មានចំនួន ៦គ្រួសារ ស្មើនឹង ៣០% និងគ្រួសារដែលមានសមាជិកចន្លោះពី ៨នាក់ ទៅ៩នាក់ មានចំនួន ២គ្រួសារ ស្មើនឹង ១០%។ លទ្ធផលនេះ បញ្ជាក់ថា កសិករនៅឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ភាគច្រើនមានសមាជិកគ្រួសារមធ្យម មិនច្រើនពេកហើយក៏មិនតិចពេក។ ដូចនេះ ពួកគាត់អាចមានកម្លាំងពលកម្មសមល្មមសម្រាប់ការដាំដុះដំណាំបន្លែ ប៉ុន្តែក៏ត្រូវមានការចំណាយប្រចាំថ្ងៃច្រើនគួរសមដែរ។

### ៣.១.៣. កម្លាំងពលកម្មក្នុងគ្រួសារ

កម្លាំងពលកម្មក្នុងគ្រួសារ សំដៅលើចំនួនសមាជិកនៅក្នុងគ្រួសារដែលស្ថិតក្នុងវ័យអាចមានលទ្ធភាពចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលក្នុងគ្រួសារ តាមរយៈសកម្មភាពការងារផ្សេងៗ ដូចជាការចូលរួមក្នុងសកម្មភាពដាំដុះបន្លែនេះផងដែរ។

តារាងទី៣.៤. ការបង្ហាញអំពីកម្លាំងពលកម្មក្នុងគ្រួសាររបស់កសិករ

| ប្រភេទកម្លាំងពលកម្ម | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ១-២ នាក់ | ៨ | ៤០% |
| ៣-៤ នាក់ | ១១ | ៥៥% |
| ៥-៦ នាក់ | ១ | ៥% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេត ឆ្នាំ២០១៧

តារាងខាងលើ បង្ហាញអំពីទំហំកម្លាំងពលកម្មក្នុងគ្រួសាររបស់កសិករដែលប្រកបរបរដាំដុះបន្លែនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល ដែលក្នុងនោះគ្រួសារដែលមានកម្លាំងពលកម្មចន្លោះពី ១ ទៅ ២នាក់ មានចំនួន ៨គ្រួសារ ស្មើនឹង ៤០% គ្រួសារដែលមានកម្លាំងពលកម្មចន្លោះពី ៣ ទៅ ៤នាក់ មានចំនួនច្រើនជាងគេគឺមានចំនួន ១១គ្រួសារ ស្មើនឹង ៥៥% និងគ្រួសារដែលមានកម្លាំងពលកម្មចន្លោះពី ៥ ទៅ ៦នាក់ មានចំនួន ១គ្រួសារ ស្មើនឹង ៥%។

## ៣.២. ផ្ទៃដីសម្រាប់ដាំដុះដំណាំបន្លែ

ផ្ទៃដី ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការដាំដុះបន្លែ ហើយវាជាប្រភពទុនមួយយ៉ាងសំខាន់នៅក្នុងរបរដាំដុះបន្លែ។

តារាងទី៣.៥. ទំហំផ្ទៃដីដាំបន្លែជាមធ្យម

| | ផ្ទៃដីជាមធ្យម (Mean) | កំហុសនៃការវាយតម្លៃលើផ្ទៃដី (Std. Error of Mean) | គំលាតគំរូ (Std. Deviation) |
|---|---|---|---|
| ទំហំផ្ទៃដីដាំដុះបន្លែ (ម$^2$) | ២,៦៧៦ | ៣៤២.២៦ | ១,៥៣០.៦០ |

ប្រភព៖ ទិន្នន័យអង្កេត ឆ្នាំ២០១៧

តាមតារាងខាងលើ ដែលទទួលបានទិន្នន័យពីការអង្កេត បង្ហាញថាផ្ទៃដីជាមធ្យមរបស់កសិករសម្រាប់ការដាំដុះបន្លែគឺមានទំហំ ២,៦៧៦ ម$^2$ ហើយគំលាតគំរូ ឬគំលាតជាមធ្យមនៃផ្ទៃដីរបស់គ្រួសារនីមួយៗគឺ ១,៥៣០.៦០ ម$^2$ និងកំហុសនៃការវាយតម្លៃលើមធ្យមនៃទំហំផ្ទៃដីរបស់គ្រួសារនីមួយៗគឺ ៣៤២.២៦ ម$^2$ ។

## ៣.៣. ប្រភេទបន្លែ

ដំណាំបន្លែដែលកសិករនិយមដាំក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល មានដូចជា

ស្ពៃតឿ ស្ពៃចង្កឹះ ស្ពៃខ្មៅ និងស្ពៃក្រញាញ់។ ក្នុងចំណោមកសិករដែលបានធ្វើការសម្ភាសន៍ឃើញថា ស្ពៃតឿត្រូវបានកសិករដាំដុះច្រើនជាងគេគឺ ៤៥% បន្ទាប់មកគឺស្ពៃចង្កឹះ ដែលមាន ៣០% ស្ពៃខ្មៅ មាន ២០% និងស្ពៃក្រញាញ់មាន ៥%។

ក្រាបទី ៣.១ ការបង្ហាញអំពីប្រភេទដំណាំបន្លែរបស់កសិករ




ប្រភព ៖ ទិន្នន័យអង្កេត ឆ្នាំ២០១៧

## ៣.៤. ការវិភាគប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែ

### ៣.៤.១. ចំណាយសរុបជាមធ្យមទៅលើការដាំដុះដំណាំបន្លែ

តារាងខាងក្រោមនេះ បង្ហាញអំពីការចំណាយសរុបជាមធ្យមរបស់កសិករទៅលើការដាំដុះបន្លែក្នុង១វដ្តផលិតកម្ម ដោយនៅក្នុងនោះគឺមានទាំងការចំណាយទៅលើចលនទុន និងអចលនទុន។

តារាងទី៣.៦. ការចំណាយសរុបជាមធ្យមរបស់កសិករទៅលើការដាំដុះបន្លែ

| | ចំណាយជាធ្យម (Mean) | កំហុសនៃការវាយតម្លៃលើចំណាយមធ្យម (Std. Error of Mean) | គម្លាតគំរូ (Std. Deviation) |
|---|---|---|---|
| ចំណាយសរុបក្នុងមួយ ១វដ្តផលិតកម្ម (រៀល) | ១,៩៨០,៩០០ | ២១២,១៣៨.៥៨ | ៩៤៨,៧១២.៥៨ |

ប្រភព៖ ទិន្នន័យអង្កេត ឆ្នាំ២០១៧

តាមទិន្នន័យខាងលើ បញ្ជាក់ថាការចំណាយសរុបរបស់កសិករទៅលើការដាំដុះបន្លែ ជាមធ្យមគឺ ១,៩៨០,៩០០ រៀល ក្នុង១វដ្តផលិតកម្ម ដែលក្នុងនោះគំលាតគំរូគឺ ៩៥៨,៧១២.៥៨ រៀល និងកំហុសនៃការវាយតម្លៃលើចំណាយមធ្យមគឺ ២១២,១៣៨.៥៨ រៀល។

### ៣.៤.២. ចំណូលជាមធ្យមទៅលើការដាំដុះដំណាំបន្លែ

ចំណូល គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់គ្រួសារប្រជាកសិករក្នុងការទ្រទង់ជីវភាពប្រចាំថ្ងៃ។ សម្រាប់គ្រួសារប្រជាកសិករដាំដុះបន្លែក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ចំណូលសរុបជាមធ្យមដែលទទួលបានពីការដាំដុះបន្លែក្នុងមួយវដ្តផលិតកម្ម បានមកពីផលគុណរវាងបន្លែសរុបដែលទទួលបានក្នុង ១វដ្តផលិតកម្ម ជាមួយនឹងថ្លៃបន្លែក្នុង ១ឯកតា។ តាមការចុះអង្កេតស្រាវជ្រាវនៅមូលដ្ឋានផ្ទាល់ ឃើញថាកម្រិតប្រាក់ចំណូលរបស់គ្រួសារកសិករនីមួយៗមានភាពខុសគ្នា អាស្រ័យទៅតាមទំហំផ្ទៃដីរបស់ប្រជាកសិករ បរិមាណទិន្នផលបន្លែ គុណភាពបន្លែ និងថ្លៃនៅលើទីផ្សារ នៅពេលដែលគាត់ប្រមូលផល[28]។

តារាងទី៣.៧.ចំណូលសរុបជាមធ្យមរបស់ប្រជាកសិករដែលទទួលបានពីការដាំដុះបន្លែក្នុងមួយវដ្តផលិតកម្ម

| បរិមាណបន្លែដែលទទួលបានជាមធ្យមក្នុង ១វដ្តផលិតកម្ម | ថ្លៃបន្លែជាមធ្យមក្នុងមួយគីឡូក្រាម | ចំណូលសរុបជាមធ្យមរបស់ប្រជាកសិករ |
|---|---|---|
| ២,៧៩២ គីឡូក្រាម | ១,៤៨៥ រៀល | ៣,៨៧១,៧០០ រៀល |

ប្រភព៖ ទិន្ន័យអង្កេត ឆ្នាំ២០១៧

យោងតាមទិន្នន័យទទួលបានខាងលើ បង្ហាញថាបរិមាណបន្លែដែលប្រជាកសិករនៅក្នុង ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ទទួលបានជាមធ្យមក្នុង ១វដ្តផលិតកម្មគឺ ២,៧៩២ គីឡូក្រាម និងថ្លៃបន្លែជាមធ្យមក្នុងមួយគីឡូក្រាមគឺ ១,៤៨៥ រៀល។ ដូចនេះ ប្រជាកសិករអាចទទួលបានចំណូលសរុបជាមធ្យមពីការដាំដុះបន្លែក្នុង ១វដ្តផលិតកម្មគឺ ៣,៨៧១,៧០០ រៀល។

### ៣.៤.៣. ប្រាក់ចំណេញ ឬខាតជាមធ្យមពីការដាំដុះដំណាំបន្លែ

ប្រាក់ចំណេញ ឬខាតជាមធ្យមពីការដាំដុះដំណាំបន្លែក្នុង ១វដ្តផលិតកម្ម គឺជាផលដករវាងចំណូលសរុបជាមធ្យមក្នុង ១វដ្តផលិតកម្ម ជាមួយនឹងចំណាយសរុបជាមធ្យមក្នុង ១វដ្តផលិតកម្ម។ យោងតាមលទ្ធផលនៃការបកស្រាយខាងលើបង្ហាញថា ចំណូលជាមធ្យមក្នុងមួយវដ្តផលិតកម្មបន្លែ

[28] ការសម្ភាសន៍ប្រជាកសិករ ក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល

គឺ ៣,៨៧១,៧០០ រៀល និងចំណាយសរុបជាមធ្យមក្នុង ១វដ្តផលិតកម្មគឺ ១,៩៨០,៩០០ រៀល។

នោះ ប្រាក់ចំណេញ ឬខាតជាមធ្យមពីការដាំដុះដំណាំបន្លែក្នុង ១វដ្តផលិតកម្មគឺ៖

ប្រាក់ចំណេញ ឬខាតជាមធ្យម = ៣,៨៧១,៧០០ រៀល - ១,៩៨០,៩០០ រៀល

= ១,៨៩០,៨០០ រៀល

ម្យ៉ាងទៀត ក្នុង ១ឆ្នាំ កសិករអាចធ្វើការដាំដុះបន្លែបានជាមធ្យម ៧ ដង (ព័ត៌មានសម្ភាសន៍)

នោះ ប្រាក់ចំណេញ ឬខាតជាមធ្យមពីការដាំដុះដំណាំបន្លែក្នុង ១ឆ្នាំគឺ៖

ប្រាក់ចំណេញ ឬខាតជាមធ្យម = ១,៨៩០,៨០០ x ៧

= ១៣,២៣៥,៦០០ រៀល

ដូចនេះ ប្រជាកសិករក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល អាចទទួលបានប្រាក់ចំណេញជាមធ្យមពីការដាដុះបន្លែស្មើនឹង ១,៨៩០,៨០០ រៀល ក្នុង ១វដ្តផលិតកម្ម ឬស្មើនឹង ១៣,២៣៥,៦០០ រៀល ក្នុងមួយឆ្នាំ សម្រាប់ចំណាយក្នុងជីវភាពគ្រួសារប្រចាំថ្ងៃ។

### ៣.៤.៤.ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការដាំដុះដំណាំបន្លែ

#### ៣.៤.៤.១. ប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម

ប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម អាចបញ្ជាក់ថា នៅពេលដែលកសិករចំណាយដើមទុន ១ រៀល ទៅ តើកសិករអាចនឹងទទួលបានមកវិញប៉ុន្មានរៀលក្នុងចំណូលរបស់ពួកគាត់ ហើយចំណេញបានប៉ុន្មានដែរ?

$$\text{ប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម (E)} = \frac{\text{ចំណូលសរុបប្រចាំឆ្នាំ ឬ ក្នុងមួយវដ្តផលិតកម្ម}}{\text{ចំណាយសរុបប្រចាំឆ្នាំ ឬ ក្នុងមួយវដ្តផលិតកម្ម}}$$

ដោយ ចំណូលសរុបជាមធ្យមពីការដាំដុះបន្លែក្នុង ១វដ្តផលិតកម្មគឺ ៣,៨៧១,៧០០ រៀល

និងចំណាយសរុបជាមធ្យមក្នុង ១វដ្តផលិតកម្មគឺ ១,៩៨០,៩០០ រៀល

$$\text{(E)} = \frac{\text{៣,៨៧១,៧០០ រៀល}}{\text{១,៩៨០,៩០០ រៀល}} = \text{១.៩៥ រៀល}$$

លទ្ធផលដែលទទួលបានខាងលើ យើងអាចសន្និដ្ឋានបានថា នៅពេលដែលកសិករចំណាយដើមទុន ១ រៀល ទៅ គាត់នឹងទទួលបានចំណូលមកវិញចំនួន ១.៩៥ រៀល។ ចំណែកឯចំណេញស្មើនឹង ១.៩៥ រៀល ដកនឹង ១ រៀល គឺ ០.៩៥ រៀល។ ដូចនេះ យើងសង្កេតឃើញថា ការដាំដុះដំណាំបន្លែមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ពីព្រោះការដាំដុះដំណាំបន្លែដែលប្រើរយៈពេលខ្លីតែប្រមាណជា ១ខែប៉ុណ្ណោះ អាចទទួលបានប្រាក់ចំណេញ សឹងតែស្មើនឹងដើមទុនផលិតកម្ម។

### ៣.៤.៤.២. ប្រសិទ្ធិភាពកម្លាំងពលកម្ម

យោងតាមការចុះអង្កេតស្រាវជ្រាវទៅលើការដាំដុះដំណាំបន្លែរបស់កសិករ នៅឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល បានបង្ហាញអំពីប្រសិទ្ធភាពកម្លាំងពលកម្ម ដែលអាចឲ្យយើងឃើញថា តើក្នុងកម្លាំងពលកម្មម្នាក់ អាចទទួលបានប្រាក់ចំណូលប៉ុន្មាន?

$$\text{ប្រសិទ្ធភាពកម្លាំងពលកម្ម} = \frac{\text{ថ្លៃកសិផលក្នុង ១ឯកតា x បរិមាណកសិផលសរុប}}{\text{កម្លាំងពលកម្មសរុប}}$$

ដោយ ថ្លៃបន្លែក្នុង ១ឯកតា x បរិមាណបន្លែសរុប ស្មើនឹងចំណូលសរុបជាមធ្យមគឺ ៣,៨៧១,៧០០ រៀល

និងកម្លាំងពលកម្មសរុបជាមធ្យមគឺ ៣ នាក់

$$\text{ប្រសិទ្ធភាពកម្លាំងពលកម្ម} = \frac{\text{៣,៨៧១,៧០០ រៀល}}{\text{៣ នាក់}} = \text{១,២៩០,៥៦៧ រៀល}$$

ដូចនេះ កម្លាំងពលកម្ម ១នាក់របស់គ្រួសារ ដែលបានចូលរួមនៅក្នុងផលិតកម្មបន្លែ អាចទទួលបានប្រាក់ចំណូលចំនួន ១,២៩០,៥៦៧ រៀល ក្នុង ១វដ្តផលិតកម្មដំណាំបន្លែ។

- **អង្កត់ជឿជាក់នៃប្រសិទ្ធភាពកម្លាំងពលកម្ម**

អង្កត់ជឿជាក់នៃប្រសិទ្ធភាពកម្លាំងពលកម្ម ជាអង្កត់ប្រាប់ពីតម្លៃដែលប្រសិទ្ធភាពកម្លាំងពលកម្មស្ថិតនៅចន្លោះវា។

រូបមន្តសម្រាប់គណនា អង្កត់ជឿជាក់នៃប្រសិទ្ធភាពកម្លាំងពលកម្ម[29] គឺ៖

$$\text{អង្កត់ជឿជាក់} = [\, \bar{X} - t^{\frac{\alpha\%}{2}} \frac{s}{\sqrt{n}} \,;\, \bar{X} + t^{\frac{\alpha\%}{2}} \frac{s}{\sqrt{n}} \,]$$

ដែល $\bar{X}$ ជាប្រសិទ្ធភាពកម្លាំងពលកម្មក្នុង១នាក់ ស្មើនឹង ១,២៩០,៥៦៧ រៀល

$t^{\frac{\alpha\%}{2}} = t^{\frac{\text{៥}\%}{2}}$ ជាពិន្ទុ student ត្រង់កម្រិតហានិភ័យ ៥% ស្មើនឹង ២.០៩៣ (តារាងពិន្ទុ student)

$s$ ជាគំលាតគំរូ ស្មើនឹង ១,០៩២,៧៧៧.២៤

$n$ ជាចំនួនអង្កេត ស្មើនឹង ២០

$$\text{អង្កត់ជឿជាក់} = [\text{១,២៩០,៥៦៧} - \text{២.០៩៣} \times \frac{\text{១,០៩២,៧៧៧.២៤}}{\sqrt{\text{២០}}} \,;\, \text{១,២៩០,៥៦៧} + \text{២.០៩៣} \times \frac{\text{១,០៩២,៧៧៧.២៤}}{\sqrt{\text{២០}}}]$$

= [៧៧៩,១៣៧.៣៩ ; ១,៨០១,៩៩៦.៦១] រៀល

[29] Frederick J Gravetter and Larry B. Wallnau, Statistic for the Behavioral Sciences, 6th Edition, New York, Thomson Wadsworth, Page 302

ម្យ៉ាងទៀត ក្នុង ១ឆ្នាំ កសិករអាចធ្វើការដាំដុះបន្លែបានជាមធ្យម ៧ ដង (ព័ត៌មានសម្ភាសន៍)

យើងបាន អង្កត់ជឿជាក់ = [៧៧៩,១៣៧.៣៩ x ៧ ; ១,៨០១,៩៩៦.៦១ x ៧]

= [៥,៤៥៣,៩៦១.៧៣ ; ១២,៦១៣,៩៧៦.២៧] រៀល

ដូចនេះ ក្នុងកម្រិតហានិភ័យ ៥% កម្លាំងពលកម្ម ១នាក់របស់គ្រួសារ អាចរកប្រាក់ចំណូលបានចន្លោះពី ៦៨៦,៥៧០ រៀល ទៅ ១,៨៩៩,៥៦៤រៀល ក្នុង១វដ្តផលិតកម្ម ឬចន្លោះពី ៥,៤៥៣,៩៦១.៧៣ រៀល ទៅ ១២,៦១៣,៩៧៦.២៧ រៀល ក្នុងមួយឆ្នាំ។

#### ៣.៤.៤.៣. ប្រសិទ្ធភាពដីធ្លី

យោងតាមការចុះអង្កេតស្រាវជ្រាវទៅលើការដាំដុះដំណាំបន្លែរបស់កសិករ នៅឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល ប្រសិទ្ធភាពដីធ្លីរបស់កសិករនឹងត្រូវបានបង្ហាញដូចខាងក្រោម។

$$\text{ប្រសិទ្ធភាពដីធ្លី} = \frac{\text{ចំណូលសរុបជាមធ្យមប្រចាំឆ្នាំ ឬ ១វដ្តផលិតកម្ម}}{\text{ផ្ទៃដីសរុបជាមធ្យម}}$$

ដោយ ចំណូលសរុបជាមធ្យមពីការដាំដុះបន្លែក្នុង ១វដ្តផលិតកម្មគឺ ៣,៨៧១,៧០០ រៀល

និងផ្ទៃដីសរុបជាមធ្យមរបស់ប្រជាកសិករគឺ ២,៦៧៦ ម៉ែត្រការេ

$$\text{ប្រសិទ្ធភាពដីធ្លី} = \frac{\text{៣,៨៧១,៧០០ រៀល}}{\text{២,៦៧៦ ម៉ែត្រការេ}} = \text{១,៤៤៦.៨២ រៀល}$$

ដូចនេះ ក្នុងការដាំដុះដំណាំបន្លែក្នុង ១ម៉ែត្រការេ អាចរកចំណូលបាន ១,៤៤៦.៨២ រៀល។

### ៣.៤.៥. ការវិភាគចំណុចស្រង់ដើម

ចំណុចស្រង់ដើម គឺជាចំណុចមួយដែលបង្ហាញអំពីចំណូល ស្មើនឹងចំណាយ។ ការវិភាគលើចំណុចស្រង់ដើម អាចធ្វើឲ្យយើងដឹងពីកម្រិតថ្លៃ និងបរិមាណដែលធ្វើឲ្យកសិករចំណេញ ឬខាត។ នៅពេលដែលដឹងអំពីចំណុចស្រង់ដើមហើយ អាចធ្វើឲ្យកសិករបង្កើនសមត្ថភាពក្នុងការផលិតដើម្បីស្វែងរកប្រាក់ចំណេញអតិបរមា។

$$\text{ចំណុចស្រង់ដើម} = \frac{\text{ចំណាយសរុបជាមធ្យមក្នុង ១វដ្តផលិតកម្ម}}{\text{បរិមាណកសិផលជាមធ្យម(Q)}}$$

ដោយ ចំណាយសរុបជាមធ្យមក្នុង ១វដ្តផលិតកម្មបន្លែគឺ ១,៩៨០,៩០០ រៀល

និងបរិមាណបន្លែដែលទទួលបានជាមធ្យមក្នុង ១វដ្តផលិតកម្មគឺ ២,៧៩២ គ.ក

$$\text{ចំណុចស្រង់ដើម} = \frac{\text{១,៩៨០,៩០០ រៀល}}{\text{២,៧៩២ គីឡូក្រាម}} = \text{៧០៩.៥០ រៀល / គ.ក}$$

ដូចនេះ ចំណុចស្រង់ដើមនៃផលិតកម្មបន្លែរបស់កសិករ គឺស្ថិតនៅកម្រិតថ្លៃ ៧០៩.៥០ រៀល/គ.ក និងនៅបរិមាណបន្លែ ២,៧៩២ គ.ក។ មានន័យថា ប្រសិនបើកសិករលក់បន្លែក្រោមតម្លៃ

៧០៩.៥០ រៀល/គ.ក នៅក្នុងបរិមាណកសិផល ២,៧៩២ គ.ក នោះកសិករនឹងទទួលរងនូវការខាតបង់ និងប្រសិនបើកសិករលក់បន្លែត្រង់តម្លៃ ៧០៩.៥០ រៀល/គ.ក ពួកគាត់ត្រូវផលិតឲ្យបានបរិមាណកសិផលលើសពី ២,៧៩២ គ.ក ទើបបានចំណេញ។ ប៉ុន្តែ បើថ្លៃដែលលក់ចេញលើសពី ៧០៩.៥០ រៀល/គ.ក ទោះជាបរិមាណកសិផលនៅដដែលក៏កសិករអាចទទួលបានប្រាក់ចំណេញបានដែរ។

យោងតាមការចុះអង្កេតស្រាវជ្រាវទៅលើការដាំដុះដំណាំបន្លែ និងតាមរយៈការសម្ភាសន៍ផ្ទាល់ជាមួយកសិករឃើញថា ថ្លៃជាមធ្យមដែលកសិករលក់បន្លែទៅឲ្យឈ្មួញគឺ ១,៨៨៥ រៀល/គ.ក ដូចនេះយើងអាចសន្និដ្ឋានបានថា កសិករពិតជាអាចទទួលបានប្រាក់ចំណេញដ៏សមរម្យពីការដាំដុះដំណាំបន្លែជាមិនខាន។

## ៣.៥. ការវិភាគ SWOT នៃដំណាំបន្លែ

ការវិភាគ SWOT គឺជាវិធីសាស្ត្រដ៏មានសារៈប្រយោជន៍សម្រាប់ការសិក្សាស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយ ព្រមទាំងសម្រាប់ការកំណត់ឱកាស និងការគំរាមកំហែង។ ការប្រកបរបរកសិកម្មដាំដុះដំណាំបន្លែដែលនៅក្នុងឃុំស្វាយប្រទាលនឹងត្រូវលើកយកមកវិភាគ SWOT ។ បើយោងទៅតាមការចុះអង្កេត សម្ភាសន៍ និងការវិភាគទៅលើដំណើរការផលិតកម្មដំណាំបន្លែរួចមកបានស្តែងចេញនូវ ចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែងដូចខាងក្រោម៖

❖ ចំណុចខ្លាំង

- តំបន់ដីរបស់កសិករមានជីជាតិ ជាកត្តាអំណោយផលដល់ការដាំដុះដំណាំបន្លែ
- កសិករមានដីគ្រប់គ្រាន់សម្រាប់ដាំដុះបន្លែដោយមិនជួលគេ ធ្វើឲ្យចំណាយថ្លៃដើមទាប
- ប្រើប្រាស់ឧបករណ៍កសិកម្មតាមបែបទំនើប និងមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់
- កសិករភាគច្រើនមានលទ្ធភាព ប្រើប្រាស់ទុនខ្លួនឯងក្នុងការវិនិយោគទៅលើការដាំដុះដំណាំបន្លែ ដោយមិនចាំបាច់ខ្ចីឥណទានពីស្ថាប័នហិរញ្ញវត្ថុ ឬអ្នកចងការប្រាក់ឡើយ
- អាចកាត់បន្ថយចំណាយទៅលើការទិញបន្លែពីទីផ្សារ ដោយការប្រើប្រាស់បន្លែ ដែលគាត់បានដាំ
- ការដាំបន្លែអាចជួយលើកស្ទួយជីវភាពក្នុងគ្រួសារឲ្យបានល្អប្រសើរជាងមុន។

❖ ចំណុចខ្សោយ

- មិនសូវមានអង្គការ ឬភ្នាក់ងារកសិកម្ម ឬអ្នកជំនាញខាងកសិកម្មចុះទៅផ្សព្វផ្សាយ
- កសិករ ប្រើប្រាស់បច្ចេកទេសតាមបែបបុរាណដែលធ្វើឲ្យទិន្នផលទាប បើធៀបនឹងការប្រើ

ប្រាស់បច្ចេកទេសទំនើប

- កសិករភាគច្រើន ពុំសូវយល់ដឹងពីការ ប្រើប្រាស់ពូជ ជី និងថ្នាំសម្លាប់សត្វល្អិត
- កសិករកង្វះខាតព័ត៌មានទីផ្សារ
- ចំពោះការលក់ផលិលផលបន្លែវិញ គឺកសិករលក់ឲ្យឈ្មួញកណ្តាលច្រើនជាងយកលក់ទៅទីផ្សារដោយខ្លួន
- កសិករ គ្មានលទ្ធភាពរក្សារទុកផលិតផលបន្លែរបស់ខ្លួននៅពេលថ្លៃបន្លែនៅលើទីផ្សារធ្លាក់ចុះទាប។

❖ **ឱកាស ឬកាលានុវត្តភាព**

- កសិករអាចដាំដំណាំបន្លែបានគ្រប់រដូវ ព្រោះផលិតផលបន្លែអំបូរស្ពៃមានរយៈពេលខ្លី និងងាយប្រមូលផល
- ចំពោះទីផ្សារ គឺមានទីផ្សារសម្រាប់លក់ផលិតផលបន្លែមានភាពងាយស្រួល ព្រោះមានឈ្មួញមកទិញដល់ចម្ការ
- ចំពោះផលិតផលបន្លែ គឺមានផ្លូវគមនាគមន៍ល្អ សម្រាប់ដឹកបន្លែយកទៅលក់លើទីផ្សារបានទាន់ពេលវាលា
- គោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានចេញប្រកាសនាឆ្នាំ២០១៧នេះ យកខេត្តចំនួនប្រាំជាខេត្តចម្បងក្នុងការផ្គត់ផ្គង់បន្លែក្នុងស្រុក និងសម្រាប់នាំចេញ ក្នុងនោះមានខេត្តកណ្តាលផងដែរ។

❖ **ការគំរាមកំហែង**

- នៅរដូវភ្លៀង ផ្លូវលំមួយចំនួននៅក្នុងភូមិមានការលំបាកធ្វើដំណើរ ពិបាកដឹកជញ្ជូនផលិតផលបន្លែបន្តិច ព្រោះផ្លូវមានភាពស្អិត និងមានភក់
- មិនអាចទប់ស្កាត់នូការបំផ្លាញពីធម្មជាតិដូចជា អាកាធាតុក្តៅពេកនៅរដូវប្រាំង និងភ្លៀងធ្លាក់ច្រើនពេកនៅរដូវវស្សាធ្វើឲ្យបន្លែមិនទទួលបានទិន្នផលល្អ
- ការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ចដែលធ្វើឲ្យតម្លៃប្រេង និងជីគីមី ព្រមទាំងថ្នាំការពារសត្វល្អិតកើនឡើង នាំឲ្យការចំណាយទៅលើផលិតកម្មរបស់កសិករមានការកើនឡើង ដែលជះឥទ្ធិពលដល់ចំណូលរបស់កសិករ
- ការនាំចូលផលិតផលបន្លែពីប្រទេសជិតខាង បានធ្វើឲ្យថ្លៃបន្លែរបស់កសិករ ក៏ដូចជាផលិតផលកសិកម្មក្នុងឃុំស្វាយប្រទាលមានការធ្លាក់ចុះ។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវ អង្កេត និងវិភាគលទ្ធផល ដែលទទួលបានពីការដាំដុះបន្លែ នៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល យើងអាចសន្និដ្ឋានបានថាការដាំដុះដំណាំបន្លែ ពិតជាអាចជួយរកប្រាក់ចំណូលយ៉ាងច្រើន ជូនកសិករសម្រាប់ការលើកស្ទួយជីវភាពគ្រួសារបាន យ៉ាងពិតប្រាកដមែន។ កត្តានេះដោយសារបន្លែ ជាប្រភេទដំណាំកសិកម្មដែលផ្តល់ទិន្នផលខ្ពស់ និងមានរយៈពេលខ្លី ថែមទាំងតំបន់នោះជាតំបន់មាត់ទន្លេដែលមានលក្ខណៈអំណោយផលខ្លាំង សម្រាប់ការដាំដុះបន្លែ ដែលធ្វើឲ្យបន្លែលូតលាស់បានល្អ មិនសូវមានទទួលរងនូវការបំផ្លិចបំផ្លាញ ធ្ងន់ធ្ងរពីកត្តាចង្រៃ និងទទួលបានទិន្នផលខ្ពស់ ហើយថែមទាំងការចំណាយដើមទុនក្នុងការដាំដុះ មិនសូវជាមានការចំណាយច្រើនទៀតផង។

ដំណាំបន្លែ ត្រូវបានកសិករធ្វើការដាំដុះគ្រប់រដូវទាំងអស់។ ប្រភពស្រោចស្រពដ៏ងាយស្រួល និងគ្រប់គ្រាន់ទោះបីស្ថិតក្នុងរដូវប្រាំងដែលមានអាកាសធាតុក្តៅហួតហែងក្តី គឺជាអណ្តូងទឹក ដែលត្រូវបានជីកនៅនឹងចម្ការផ្ទាល់តែម្តង។ ចំពោះដើមទុនសម្រាប់ការវិនិយោគលើការដាំដុះបន្លែ កសិករភាគច្រើនប្រើប្រាស់ទុនផ្ទាល់ខ្លួនទាំងស្រុង ដោយពុំបានខ្ចីឥណទានពីធនាគារ ឬមីក្រូហិរញ្ញវត្ថុ ឬអ្នកចងការប្រាក់ឡើយ។ រីឯបន្លែដែលកសិករដាំបាន ភាគច្រើនលក់នៅចម្ការផ្ទាល់ ដោយមានឈ្មួញកណ្តាលមកទិញដល់កន្លែង។ ចំណែកឯ បច្ចេកទេសដែលកសិករប្រើក្នុងការដាំដុះវិញ គឺជាបច្ចេកទេសបែបបុរាណដែលកសិករចេះតៗគ្នា។ បន្ថែមពីលើនេះ កម្លាំងពលកម្មជាមធ្យមក្នុងគ្រួសារ ដែលប្រើសម្រាប់ការដាំដុះដំណាំបន្លែគឺមានចំនួន ៣នាក់។

ដោយយោងទៅតាម លទ្ធផលនៃការវិភាគប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែឃើញថា ការចំណាយសរុបរបស់កសិករ ទៅលើការដាំដុះបន្លែជាមធ្យមគឺ ១,៩៨០,៩០០រៀល ក្នុង ១វដ្តផលិតកម្ម ។ ចំណែក ប្រាក់ចំណូលសរុបជាមធ្យមដែលកសិករអាចទទួលបានពីការដាំដុះបន្លែក្នុង ១វដ្តផលិតកម្មគឺ ៣,៨៧១,៧០០ រៀល ។ បន្ថែមពីលើនេះ កសិករអាចទទួលបានប្រាក់ចំណេញជាមធ្យមពីការដាដុះបន្លែក្នុង ១វដ្តផលិតកម្មស្មើនឹង ១,៨៩០,៨០០ រៀល សម្រាប់លើកស្ទួយជីវភាពគ្រួសារ។ នៅពេលដែលកសិករចំណាយដើមទុន ១ រៀល ទៅ គាត់នឹងទទួលបានចំណូលមកវិញចំនួន ១.៩៥ រៀល។ ចំណែកឯចំណេញស្មើនឹង ១.៩៥ រៀល ដកនឹង ១រៀល គឺ ០.៩៥ រៀល។ ចំពោះកម្លាំងពលកម្ម ១នាក់របស់គ្រួសារ ដែលបានចូលរួមនៅក្នុងផលិតកម្មបន្លែ អាចទទួលបានប្រាក់ចំណូលចំនួន ១,២៩០,៥៦៧ រៀល ក្នុង ១វដ្តផលិតកម្មដំណាំបន្លែ ហើយក្នុងកម្រិតហានិភ័យ ៥% កម្លាំងពលកម្ម ១នាក់របស់គ្រួសារ អាចរកប្រាក់ចំណូលបានចន្លោះពី ៧៧៩,១៣៧.៣៩ រៀល ទៅ ១,៨០១,៩៩៦.៦១ រៀល ក្នុង១វដ្តផលិតកម្ម ឬចន្លោះពី ៥,៤៥៣,៩៦១.៧៣ រៀល ទៅ ១២,៦១៣,៩៧៦.២៧ រៀល ក្នុងមួយឆ្នាំ។ ឯការដាំដុះដំណាំបន្លែក្នុង ១ម៉ែត្រការេ អាចរកចំណូល

បាន ១,៩៤៦.៨២ រៀល។ បើគិតអំពីចំណុចស្រង់ដើមនៃផលិតកម្មបន្លែរបស់កសិករវិញគឺ ស្ថិតនៅកម្រិតថ្លៃ ៧០៩.៥០ រៀល/គ.ក និងនៅបរិមាណបន្លែ ២,៧៩២ គ.ក។ មានន័យថា ប្រសិនបើកសិករលក់បន្លែក្រោមតម្លៃ ៧០៩.៥០ រៀល/គ.ក នៅក្នុងបរិមាណកសិផល ២,៧៩២ គ.ក នោះកសិករនឹងទទួលរងនូវការខាតបង់ និងប្រសិនបើកសិករលក់បន្លែត្រង់តម្លៃ ៧០៩.៥០ រៀល/គ.ក ពួកគាត់ត្រូវផលិតឲ្យបានបរិមាណកសិផលលើសពី ២,៧៩២ គ.ក ទើបបានចំណេញ។ ប៉ុន្តែ បើថ្លៃដែលលក់ចេញលើសពី ៧០៩.៥០ រៀល/គ.ក ទោះជាបរិមាណកសិផលនៅដដែលក៏កសិករអាចទទួលបានប្រាក់ចំណេញបានដែរ។ ដោយ ថ្លៃបន្លែជាមធ្យមដែលបានពីការសម្ភាសន៍ ដែលកសិករលក់បន្លែទៅឲ្យឈ្មួញគឺ ១,៤៨៥ រៀល/គ.ក ដូចនេះ កសិករពិតជាអាចទទួលបានប្រាក់ចំណេញដ៏សមរម្យពីការដាំដុះដំណាំបន្លែជាមិនខាន។

## ២. អនុសាសន៍

យោងតាមលទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវ និងការវិភាគបកស្រាយខាងលើ យើងខ្ញុំសូមផ្តល់មតិយោបល់ និងសំណូមពរមួយចំនួនដូចខាងក្រោមៈ

- កសិករគួរតែបង្កើនការដាំដុះបន្លែ ហើយគួរសិក្សាពីបច្ចេកទេសដាំដុះបន្លែថ្មីៗដើម្បីឲ្យការដាំដុះបន្លែទទួលបានទិន្នផលកាន់តែខ្ពស់។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីកសិកម្មខេត្ត រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល រួមជាមួយអង្គការនានា និងស្ថាប័នពាក់ព័ន្ធ គួរចុះផ្សព្វផ្សាយបច្ចេកទេសថ្មីៗដល់ប្រជាកសិករ ចំពោះការដាំដុះបន្លែ ដើម្បីជំរុញដល់ការដាំដុះរបស់ពួកគាត់ឈានទៅរកការទទួលបានទិន្នផលកសិផលខ្ពស់បំផុត និងជួយជំរុញឲ្យមានការផ្សព្វផ្សាយ និងផ្តល់ព័ត៌មានទីផ្សារបន្លែឲ្យបានកាន់តែទូលំទូលាយដល់កសិករ។ បន្ថែមពីលើនេះ ក៏គួរបង្កើតសហាគមន៍មូលដ្ឋានក្នុងឃុំ ដើម្បីសម្របសម្រួលដល់ការលក់ផលិតផលបន្លែរបស់កសិករ។
- ក្រសួងពាណិជ្ជកម្ម គួរតែស្វែងរកទីផ្សារបន្លែឲ្យកសិករសម្រាប់លក់បន្លែ ក៏ដូចជាមានយន្តការសម្របសម្រួលថ្លៃបន្លែនៅលើទីផ្សារ ដើម្បីកុំឲ្យថ្លៃបន្លែមានការឡើងចុះខ្លាំង និងឆាប់រហ័សពេក។
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក៏ដូចជាមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តកណ្តាល រួមជាមួយនឹងស្ថាប័នពាក់ព័ន្ធ គួរមានវិធានការជួសជុលផ្លូវលំមួយចំនួននៅក្នុងភូមិ ដើម្បីជួយសម្រួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនកសិផលនៅរដូវភ្លៀង។
- រដ្ឋាភិបាល គួរមានយុទ្ធសាស្ត្រក្នុងការជម្រុញការប្រើប្រាស់ផលិតផលបន្លែក្នុងស្រុកជាជាងការនាំចូលពីប្រទេសជិតខាង និងត្រូវមានវិធានការទប់ស្កាត់ការនាំចូលផលិតផលបន្លែពីប្រទេសជិតខាង ដើម្បីធ្វើឲ្យផលិតផលបន្លែរបស់កសិករអាចលក់បានក្នុងកម្រិតតម្លៃថ្លៃមួយ ដែលកសិករអាចទទួលយកបាន។

- ភោជនីយដ្ឋាន និងសណ្ឋាគារនានា គួរតែផ្សារភ្ជាប់ទំនាក់ទំនងជាមួយកសិករដើម្បីទិញយកផលិតផលបន្លែដែលកសិករផលិតបានក្នុងតម្លៃមួយសមស្រប។
- ហើយប្រជាជនកម្ពុជាទាំងអស់ គួរនាំគ្នាងាកមកគាំទ្រផលិតផលបន្លែក្នុងស្រុក ទើបធ្វើឲ្យកសិករដាំដុះបន្លែកាន់តែច្រើន បង្កើនការងារកាន់តែច្រើនសម្រាប់ប្រជាពលរដ្ឋខ្មែរ កាត់បន្ថយការធ្វើចំណាកស្រុក និងជួយលើកកម្ពស់ជីវភាពគ្រួសារកសិករ ដែលជាកត្តាមួយរុញច្រានកំណើនសេដ្ឋកិច្ចជាតិ។

# ឯកសារយោង

# ឯកសារយោង


១. បណ្ឌិត ប្រិន រ៉ូវែល និង តាត់ អេងឡាយ, ១៩៩២, ដំណាំបន្លែនៅកម្ពុជា, បោះពុម្ពលើកទី១, នាយកដ្ឋានក្សេត្រសាស្រ្តនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២. សៀវភៅទិន្នន័យឃុំ ឆ្នាំ ២០១៧, ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល, ២០១៧

៤. របាយការណ៍ស្ថិតិប្រជាពលរដ្ឋក្នុងស្រុកស្អាងឆ្នាំ២០០៨, សាលាស្រុកស្អាង

៥. បណ្ឌិត ហង់ ជួន ណារ៉ុន, ២០១៥, សេដ្ឋកិច្ចកម្ពុជា

៦. ម៉ម ចរិយារុធ និង ងួន ហេង, ២០១២, សេដ្ឋកិច្ចនយោបាយ, បោះពុម្ពលើកទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

៧. Frederick J Gravetter and Larry B. Wallnau, Statistic for the Behavioral Sciences, 6th Edition, New York, Thomson Wadsworth

៨. Baden Cameron and Peter Twyford-Jones, 1995, Development of the Market for Vegetable in Cambodia

៩. Yamane1967 (Yamane Taro, An Introductory Statistic, 2nd Edition, New York: Harper and Row)

១១. Hal R. Varian, 2010, Intermediate Microeconomics, 8th Edition, New York, W.W. Norton & Company

១២. Timothy J. Coelli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer

១៣. David Besanko Ronald R. Braetigan, 2010, Microeconomic, 4th Edition, New York, John Wiley & Sons,

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១

## កម្រងសំណួរសម្រាប់សម្ភាសន៍កសិករ

ឈ្មោះភូមិ.......................................ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល

១. ឈ្មោះមេគ្រួសារ.......................................ភេទ.............អាយុ...................ឆ្នាំ

២. ចំនួនសមាជិកគ្រួសារ................................នាក់ ប្រុស.................នាក់

៣. ចំនួនកម្លាំងកម្មក្នុងគ្រួសារ.........................នាក់ ប្រុស.................នាក់

៤. តើដំណាំបន្លែប្រភេទណាដែលអ្នកដាំ?

១.☐ ស្ពៃតឿ ២. ☐ ស្ពៃចង្កឹះ ៣. ☐ ស្ពៃក្រញាញ់

៤. ☐ ស្ពៃខ្មៅ ៥. ☐ ផ្សេងៗ

៥. ហេតុអ្វីបានជាអ្នកជ្រើសរើសយកការដាំបន្លែប្រភេទនេះ?

.......................................................................................................................................

.......................................................................................................................................

៦. តើអ្នកមានទំហំដីសម្រាប់ដាំបន្លែប៉ុន្មានម៉ែត្រការេ?....................................ម៉ែត្រការេ តើទំហំផ្ទៃដីនេះគ្រប់គ្រាន់សម្រាប់ការដាំដុះឬទេ?

១. ☐ គ្រប់គ្រាន់ ២. ☐ មិនគ្រប់គ្រាន់គ្រប់គ្រាន់

៧. តើផ្ទៃដីដាំដុះរបស់អ្នកបានមកពីណា?

១. ☐ ដីផ្ទាល់ខ្លួន ២. ☐ ដីជួលគេ ៣. ☐ ជួលគេខ្លះ ដីផ្ទាល់ខ្លួនខ្លះ

៨. ប្រសិនបើជួល តើជួលក្នុងតម្លៃប៉ុន្មានជាប្រចាំឆ្នាំ?.......................................រៀល

ចំនួនប៉ុន្មានម៉ែត្រការេ?............................ម៉ែត្រការេ

៩. តើលោកអ្នកបានពូជមកពីណា?

១. ☐ ទិញគេ ២. ☐ ខ្លួនឯង ៣. ☐ ភ្នាក់ងារកសិកម្ម ៤.☐ ផ្សេងៗ

១០. តើក្នុងការដាំន្លែនេះអ្នកប្រើកម្លាំងពលកម្មប៉ុន្មាននាក់? ..........................នាក់

១១. តើអ្នកជួលកម្លាំងពលកម្មបន្ថែមចំនួនប៉ុន្មាននាក់?.................នាក់

តើចំណាយប៉ុន្មាន?....................................រៀល

១២. តើប្រភពទឹកដែលអ្នកស្រោចស្រពបានមកពីណា?

១. ☐ ស្រះ ២. ☐ ទន្លេ ៣. ☐ អណ្តូង ៤. ☐ ទឹកភ្លៀង

១៣. តើប្រភពទឹកដែលទទួលបានគ្រប់គ្រាន់ដែរឬទេ?

១. ☐ គ្រប់គ្រាន់ ២. ☐ មិនគ្រប់គ្រាន់

១៤. តើធ្លាប់មានអ្នកបច្ចេកទេសកសិកម្មមកបណ្តុះបណ្តាលបច្ចេកទេសដល់អ្នកឬទេ?

១. ☐ ធ្លាប់ ២. ☐ មិនធ្លាប់ទេ

១៥. តើអ្នកមានបច្ចេកទេសដាំបន្លែនេះមកពីណា?

១. ☐ តាមទម្លាប់ ២. ☐ អ្នកជិតខាង ៣. ☐ ខ្លួនឯង

៤. ☐ ភ្នាក់ងារកសិកម្ម ៥. ☐ អង្គការជំនាញខាងកសិកម្ម ៦. ☐ ផ្សេងៗ

១៦. បើអ្នកអនុវត្តតាមលក្ខណៈបច្ចេកទេស តើទិន្នផលដំណាំទទួលបានផលកើនឡើង ឬទេ?

១. ☐ កើន ២. ☐ ថេរ ៣. ☐ ធ្លាក់ចុះ

១៧. តើប្រភពទុនវិនិយោគរបស់អ្នកបានមកពីណា?

១. ☐ ខ្លួនឯង ២. ☐ ខ្ចីបងប្អូន ៣. ☐ ខ្ចីអ្នកជិតខាង

៤. ☐ ខ្ចីឥណទាន ៤. ☐ ជំនួយពីភ្នាក់ងារកសិកម្ម ៥. ☐ ផ្សេងៗពីនេះ

១៨. បើខ្ចី តើគិតក្នុងអត្រាការប្រាក់ប៉ុន្មានក្នុងមួយខែ?......................................

១៩. តើមានកត្តាអ្វីខ្លះដែលធ្វើឲ្យទិន្នផលកើនឡើង?

១. ☐ កត្តាទឹក ២. ☐ កត្តាជី ៣. ☐ ថ្នាំការពារ ៤. ☐ កត្តាពូជ

៥. ☐ កត្តាអាសធាតុ ៦. ☐ កត្តាបច្ចេកទេស ៧. ☐ កត្តាផ្សេងៗ

២០. មានកត្តាអ្វីខ្លះក្នុងការធ្វើឲ្យទិន្នផលថយចុះ?

១. ☐ កត្តាទឹក ២. ☐ កត្តាដី ៣. ☐ កត្តាសត្វល្អិត និងជំងឺ ៤. ☐ កត្តាពូជ

៥. ☐ កត្តាអាសធាតុ ៦. ☐ កត្តាបច្ចេកទេស ៧. ☐ កត្តាផ្សេងៗ

២១. តើករណីណាដែលចាំបាច់ប្រើប្រាស់ជី និង ប្រើថ្នាំពុលសម្លាប់សត្វល្អិតលើដំណាំ?

១. ☐ ប្រើប្រាស់ទូទៅ ២. ☐ មានសត្វល្អិត និងជំងឺ ៣. ☐ នៅពេលជិតប្រមូលផ

២២. បើប្រើតើចំណាយអស់ប៉ុន្មានក្នុងមួយវដ្តផលិតកម្ម? ....................................រៀល

២៣. ក្នុងរយៈពេលដាំ តើប្រើពេលប៉ុន្មានទើបទទួលបានផល?....................................

២៤. នៅពេលដែលប្រមូលផលរួច តើអ្នកលក់ផលិតផលបន្លែដោយរបៀបណា?

១.☐ មានឈ្មួញមកទិញដល់ផ្ទះ ក្នុងតម្លៃ........................./មួយគីឡូក្រាម

២.☐ ដឹកយកទៅលក់ខ្លួនឯង ក្នុងតម្លៃ........................./មួយគីឡូក្រាម

៣.☐ មានឈ្មួញមកម៉ៅការដល់ចម្ការ ក្នុងតម្លៃ........................./មួយគីឡូក្រាម

៤.☐ ផ្សេងៗ ក្នុងតម្លៃ........................./មួយគីឡូក្រា

២៥. បើរកទីផ្សារដោយខ្លួនឯង តើអ្នកយកបន្លែទៅលក់នៅទីផ្សារណាច្រើនជាងគេ?

១.☐ នៅផ្ទះ ☐ ២.☐ ផ្សារក្នុងភូមិ ៣.☐ ផ្សារក្នុងស្រុក

៤.☐ ផ្សារក្នុងខេត្ត ៥.☐ ផ្សារនៅរាជធានីភ្នំពេញ ៦.☐ ផ្សេងៗពីនេះ

២៦. តើក្នុងខែណាដែលបន្លែលក់បានថ្លៃខ្ពស់ជាងគេ?......................ក្នុងតម្លៃ................/គីឡូក្រាម
មូលហេតុ:

..............................................................................................................................

..............................................................................................................................

២៧. តើក្នុងខែណាដែលបន្លែមានតម្លៃទាបជាងគេ? ......................ក្នុងតម្លៃ................/គីឡូក្រាម
មូលហេតុ:

..........................................................................................................................................

..........................................................................................................................................

២៨. នៅពេលបន្លែក្នុងផ្សារមានតម្លៃថោក តើអ្នកធ្វើដូចម្តេចនៅពេលដាំលើកក្រោយ?

១.☐ កាត់បន្ថយការដាំ ២. ☐ រក្សារការដាំ ៣.☐ បង្កើនការដាំ

២៩. នៅពេលបន្លែក្នុងផ្សារមានតម្លៃខ្ពស់ តើអ្នកធ្វើដូចម្តេចនៅពេលដាំលើកក្រោយ?

១.☐ កាត់បន្ថយការដាំ ២. ☐ រក្សារការដាំ ៣.☐ បង្កើនការដាំ

៣០. តើអ្នកជួបបញ្ហាប្រឈមអ្វីខ្លះក្នុងការដាំបន្លែ?

..........................................................................................................................................

..........................................................................................................................................

៣១. តើអ្នកមានដំណោះស្រាយបែបណាចំពោះបញ្ហាប្រឈមទាំងនេះ?

..........................................................................................................................................

..........................................................................................................................................

៣២. តើក្នុងមួយវដ្តផលិតកម្ម តើអ្នកទទួលបានផលបន្លែបានប៉ុន្មានគីឡូក្រាម?..............គីឡូក្រាម

៣៣.តើក្នុងមួយវគ្គផលិតកម្ម អ្នកចំណាយដើមទុនសរុបអស់ប៉ុន្មាន?.....................................រៀល

# ឧបសម្ព័ន្ធទី២
# លទ្ធផលនៃការវិភាគ

កម្រិតអាយុ និងភេទនៃមេគ្រួសារ

| | | ភេទ | | សរុប |
|---|---|---|---|---|
| | | ស្ត្រី | បុរស | |
| អាយុ | 29 | 0 | 1 | 1 |
| | 32 | 1 | 1 | 2 |
| | 34 | 1 | 0 | 1 |
| | 36 | 1 | 0 | 1 |
| | 38 | 1 | 0 | 1 |
| | 45 | 0 | 2 | 2 |
| | 46 | 0 | 1 | 1 |
| | 50 | 1 | 0 | 1 |
| | 51 | 0 | 1 | 1 |
| | 53 | 1 | 0 | 1 |
| | 54 | 1 | 1 | 2 |
| | 55 | 0 | 1 | 1 |
| | 57 | 0 | 1 | 1 |
| | 58 | 1 | 0 | 1 |
| | 60 | 0 | 1 | 1 |
| | 61 | 0 | 1 | 1 |
| | 65 | 1 | 0 | 1 |
| សរុប | | 9 | 11 | 20 |

### ចំនួនសមាជិកគ្រួសារ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 2 | 1 | 5.0 | 5.0 | 5.0 |
| | 3 | 3 | 15.0 | 15.0 | 20.0 |
| | 4 | 5 | 25.0 | 25.0 | 45.0 |
| | 5 | 3 | 15.0 | 15.0 | 60.0 |
| | 6 | 4 | 20.0 | 20.0 | 80.0 |
| | 7 | 2 | 10.0 | 10.0 | 90.0 |
| | 8 | 2 | 10.0 | 10.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

### ចំនួនសមាជិកគ្រួសារ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 5.00 |
| Minimum | | 2 |
| Maximum | | 8 |

### ចំនួនសមាជិកគ្រួសារជាបុរស

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1 | 3 | 15.0 | 15.0 | 15.0 |
| | 2 | 11 | 55.0 | 55.0 | 70.0 |
| | 3 | 3 | 15.0 | 15.0 | 85.0 |
| | 4 | 3 | 15.0 | 15.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

## ចំនួនសមាជិកគ្រួសារ និងចំនួនសមាជិកគ្រួសារជាបុរស

| | | ចំនួនសមាជិកគ្រួសារជាបុរស | | | | សរុប |
|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | |
| ចំនួនសមាជិកគ្រួសារ | 2 | 0 | 1 | 0 | 0 | 1 |
| | 3 | 1 | 2 | 0 | 0 | 3 |
| | 4 | 2 | 3 | 0 | 0 | 5 |
| | 5 | 0 | 2 | 1 | 0 | 3 |
| | 6 | 0 | 3 | 1 | 0 | 4 |
| | 7 | 0 | 0 | 0 | 2 | 2 |
| | 8 | 0 | 0 | 1 | 1 | 2 |
| សរុប | | 3 | 11 | 3 | 3 | 20 |

## ចំនួនកម្លាំងពលកម្មក្នុងគ្រួសារ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1 | 1 | 5.0 | 5.0 | 5.0 |
| | 2 | 7 | 35.0 | 35.0 | 40.0 |
| | 3 | 4 | 20.0 | 20.0 | 60.0 |
| | 4 | 7 | 35.0 | 35.0 | 95.0 |
| | 6 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

## ចំនួនកម្លាំងពលកម្មក្នុងគ្រួសារ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 3.05 |
| Minimum | | 1 |
| Maximum | | 6 |

ចំនួនកម្លាំងពលកម្មក្នុងគ្រួសារជាបុរស

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 0 | 1 | 5.0 | 5.0 | 5.0 |
| | 1 | 8 | 40.0 | 40.0 | 45.0 |
| | 2 | 7 | 35.0 | 35.0 | 80.0 |
| | 3 | 3 | 15.0 | 15.0 | 95.0 |
| | 4 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ចំនួនកម្លាំងពលកម្មក្នុងគ្រួសារ និងចំនួនកម្លាំងពលកម្មក្នុងគ្រួសារជាបុរស

| | | ចំនួនកម្លាំងពលកម្មក្នុងគ្រួសារជាបុរស | | | | | |
|---|---|---|---|---|---|---|---|
| | | 0 | 1 | 2 | 3 | 4 | |
| ចំនួនកម្លាំងពលកម្មសរុបក្នុងគ្រួសារ | 1 | 1 | 0 | 0 | 0 | 0 | 1 |
| | 2 | 0 | 7 | 0 | 0 | 0 | 7 |
| | 3 | 0 | 0 | 4 | 0 | 0 | 4 |
| | 4 | 0 | 1 | 3 | 3 | 0 | 7 |
| | 6 | 0 | 0 | 0 | 0 | 1 | 1 |
| សរុប | | 1 | 8 | 7 | 3 | 1 | 20 |

ប្រភេទបន្លែ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ស្ពៃតឿ | 9 | 45.0 | 45.0 | 45.0 |
| | ស្ពៃចង្កឹះ | 6 | 30.0 | 30.0 | 75.0 |
| | ស្ពៃខ្មៅ | 4 | 20.0 | 20.0 | 95.0 |
| | ស្ពៃក្រញ៉ាញ់ | 1 | 5.0 | 5.0 | 100.0 |
| | សរុប | 20 | 100.0 | 100.0 | |

ផ្ទៃដីដាំដុះបន្លែ (គិតជាម៉ែត្រការេ)

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 840 | 1 | 5.0 | 5.0 | 5.0 |
| | 900 | 1 | 5.0 | 5.0 | 10.0 |
| | 1200 | 1 | 5.0 | 5.0 | 15.0 |
| | 1400 | 1 | 5.0 | 5.0 | 20.0 |
| | 1620 | 1 | 5.0 | 5.0 | 25.0 |
| | 1700 | 1 | 5.0 | 5.0 | 30.0 |
| | 1950 | 1 | 5.0 | 5.0 | 35.0 |
| | 2100 | 1 | 5.0 | 5.0 | 40.0 |
| | 2300 | 1 | 5.0 | 5.0 | 45.0 |
| | 2390 | 1 | 5.0 | 5.0 | 50.0 |
| | 2400 | 4 | 20.0 | 20.0 | 70.0 |
| | 3000 | 1 | 5.0 | 5.0 | 75.0 |
| | 3520 | 1 | 5.0 | 5.0 | 80.0 |
| | 3900 | 1 | 5.0 | 5.0 | 85.0 |
| | 5200 | 1 | 5.0 | 5.0 | 90.0 |
| | 5400 | 1 | 5.0 | 5.0 | 95.0 |
| | 6500 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ផ្ទៃដីដាំដុះបន្លែ (គិតជាម៉ែត្រការេ)

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2676.00 |
| Minimum | | 840 |
| Maximum | | 6500 |

បរិមាណបន្លែ (គិតជាគីឡូក្រាម)

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1200 | 1 | 5.0 | 5.0 | 5.0 |
| | 1300 | 1 | 5.0 | 5.0 | 10.0 |
| | 1320 | 1 | 5.0 | 5.0 | 15.0 |
| | 1470 | 1 | 5.0 | 5.0 | 20.0 |
| | 1500 | 1 | 5.0 | 5.0 | 25.0 |
| | 1700 | 1 | 5.0 | 5.0 | 30.0 |
| | 1800 | 1 | 5.0 | 5.0 | 35.0 |
| | 1850 | 1 | 5.0 | 5.0 | 40.0 |
| | 2070 | 1 | 5.0 | 5.0 | 45.0 |
| | 2200 | 1 | 5.0 | 5.0 | 50.0 |
| | 2500 | 1 | 5.0 | 5.0 | 55.0 |
| | 2670 | 1 | 5.0 | 5.0 | 60.0 |
| | 3200 | 1 | 5.0 | 5.0 | 65.0 |
| | 3500 | 1 | 5.0 | 5.0 | 70.0 |
| | 3560 | 1 | 5.0 | 5.0 | 75.0 |
| | 4000 | 2 | 10.0 | 10.0 | 85.0 |
| | 4500 | 1 | 5.0 | 5.0 | 90.0 |
| | 5500 | 1 | 5.0 | 5.0 | 95.0 |
| | 6000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

បរិមាណបន្លែ (គិតជាគីឡូក្រាម)

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2792.00 |
| Minimum | | 1200 |
| Maximum | | 6000 |

ថ្លៃបន្លែ (គិតជារៀល)

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 400 | 1 | 5.0 | 5.0 | 5.0 |
| | 700 | 3 | 15.0 | 15.0 | 20.0 |
| | 800 | 3 | 15.0 | 15.0 | 35.0 |
| | 1000 | 2 | 10.0 | 10.0 | 45.0 |
| | 1500 | 2 | 10.0 | 10.0 | 55.0 |
| | 1600 | 1 | 5.0 | 5.0 | 60.0 |
| | 1800 | 1 | 5.0 | 5.0 | 65.0 |
| | 2000 | 2 | 10.0 | 10.0 | 75.0 |
| | 2200 | 2 | 10.0 | 10.0 | 85.0 |
| | 2500 | 2 | 10.0 | 10.0 | 95.0 |
| | 3000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ថ្លៃបន្លែ (គិតជារៀល)

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1485.00 |
| Minimum | | 400 |
| Maximum | | 3000 |

ចំណូលពីការដាំបន្លែ (គិតជារៀល)

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| | 1040000 | 1 | 5.0 | 5.0 | 5.0 |
| | 1280000 | 1 | 5.0 | 5.0 | 10.0 |
| | 1449000 | 1 | 5.0 | 5.0 | 15.0 |
| | 1750000 | 1 | 5.0 | 5.0 | 20.0 |
| | 1800000 | 1 | 5.0 | 5.0 | 25.0 |
| | 2250000 | 1 | 5.0 | 5.0 | 30.0 |
| | 2376000 | 1 | 5.0 | 5.0 | 35.0 |
| | 2720000 | 1 | 5.0 | 5.0 | 40.0 |
| | 2800000 | 1 | 5.0 | 5.0 | 45.0 |
| | 3234000 | 1 | 5.0 | 5.0 | 50.0 |
| Valid | 3560000 | 1 | 5.0 | 5.0 | 55.0 |
| | 3600000 | 1 | 5.0 | 5.0 | 60.0 |
| | 3700000 | 1 | 5.0 | 5.0 | 65.0 |
| | 4000000 | 1 | 5.0 | 5.0 | 70.0 |
| | 4200000 | 1 | 5.0 | 5.0 | 75.0 |
| | 5400000 | 1 | 5.0 | 5.0 | 80.0 |
| | 5500000 | 1 | 5.0 | 5.0 | 85.0 |
| | 6675000 | 1 | 5.0 | 5.0 | 90.0 |
| | 8000000 | 1 | 5.0 | 5.0 | 95.0 |
| | 12100000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ចំណូលពីការដាំបន្លែ (គិតជារៀល)

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 3,871,700.00 |
| Sum | | 77,434,000 |

ចំណាយលើការដាំដុះបន្លែ (គិតជារៀល)

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 465000 | 1 | 5.0 | 5.0 | 5.0 |
| | 880000 | 1 | 5.0 | 5.0 | 10.0 |
| | 967000 | 1 | 5.0 | 5.0 | 15.0 |
| | 990000 | 1 | 5.0 | 5.0 | 20.0 |
| | 1000000 | 1 | 5.0 | 5.0 | 25.0 |
| | 1090000 | 1 | 5.0 | 5.0 | 30.0 |
| | 1459000 | 1 | 5.0 | 5.0 | 35.0 |
| | 1600000 | 1 | 5.0 | 5.0 | 40.0 |
| | 1700000 | 1 | 5.0 | 5.0 | 45.0 |
| | 1980000 | 1 | 5.0 | 5.0 | 50.0 |
| | 2100000 | 1 | 5.0 | 5.0 | 55.0 |
| | 2400000 | 2 | 10.0 | 10.0 | 65.0 |
| | 2446000 | 1 | 5.0 | 5.0 | 70.0 |
| | 2500000 | 1 | 5.0 | 5.0 | 75.0 |
| | 2650000 | 1 | 5.0 | 5.0 | 80.0 |
| | 2720000 | 1 | 5.0 | 5.0 | 85.0 |
| | 2850000 | 1 | 5.0 | 5.0 | 90.0 |
| | 3100000 | 1 | 5.0 | 5.0 | 95.0 |
| | 4321000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ចំណាយលើការដាំដុះបន្លែ (គិតជារៀល)

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1,980,900.00 |
| Sum | | 39,618,000 |

ប្រាក់ចំណេញ ឬខាត

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | -420000 | 1 | 5.0 | 5.0 | 5.0 |
| | 359000 | 1 | 5.0 | 5.0 | 10.0 |
| | 460000 | 1 | 5.0 | 5.0 | 15.0 |
| | 575000 | 1 | 5.0 | 5.0 | 20.0 |
| | 776000 | 1 | 5.0 | 5.0 | 25.0 |
| | 791000 | 1 | 5.0 | 5.0 | 30.0 |
| | 800000 | 1 | 5.0 | 5.0 | 35.0 |
| | 820000 | 1 | 5.0 | 5.0 | 40.0 |
| | 870000 | 1 | 5.0 | 5.0 | 45.0 |
| | 950000 | 1 | 5.0 | 5.0 | 50.0 |
| | 980000 | 1 | 5.0 | 5.0 | 55.0 |
| | 1150000 | 1 | 5.0 | 5.0 | 60.0 |
| | 1753000 | 1 | 5.0 | 5.0 | 65.0 |
| | 1800000 | 1 | 5.0 | 5.0 | 70.0 |
| | 2244000 | 1 | 5.0 | 5.0 | 75.0 |
| | 2954000 | 1 | 5.0 | 5.0 | 80.0 |
| | 3400000 | 1 | 5.0 | 5.0 | 85.0 |
| | 4175000 | 1 | 5.0 | 5.0 | 90.0 |
| | 5600000 | 1 | 5.0 | 5.0 | 95.0 |
| | 7779000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ប្រាក់ចំណេញ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1,890,800.00 |
| Sum | | 37,816,000 |

# ឧបសម្ព័ន្ធទី៣

ផែនទីស្រុកស្អាង




ប្រភពៈសាលាស្រុកស្អាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរកសិកម្ម ខេត្តកណ្តាល
ការិយល័យផែនការ គណនេយ្យ

## ផ្ទៃដីដំណាំប្រចាំឆ្នាំ ២០១៥-២០១៦

| លរ | បរិយាយ | រដូវវស្សា | | | រដូវប្រាំង | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ត) | បរិមាណផល (ត) | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ត) | បរិមាណផល (ត) | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ត) | បរិមាណផល (ត) |
| **ក** | **ដំណាំប្រចាំឆ្នាំ** | **52678** | **52210** | **198392** | **69446** | **69446** | **300716** | **122124** | **121656** | **499108** |
| ក្នុងនោះមាន | | | | | | | | | | |
| ក1 | **ដំណាំស្រូវ** | 35280 | 35280 | 108949 | 55581 | 55581 | 234334 | 90861 | 90861 | 343283 |
| ក2 | **ដំណាំអនុផល** | 17398 | 16930 | 89443 | 13865 | 13865 | 66382 | 31263 | 30795 | 155825 |
| ក្នុងនោះ :- ដំណាំរួមផ្សំ | | *15822* | *15354* | *76673* | *11476* | *11476* | *48407* | *27298* | *26830* | *125080* |
| ក.2.1 | ពោត | 12314 | 11852 | 54465 | 4050 | 4050 | 16387 | 16364 | 15902 | 70852 |
| ក.2.2 | ដំឡូងឈើ | 5 | 5 | 53 | 49 | 49 | 392 | 54 | 54 | 445 |
| ក.2.3 | ដំឡូងជ្វា | 39 | 39 | 234 | 86 | 86 | 516 | 125 | 125 | 750 |
| ក.2.4 | បន្លែគ្រប់មុខ | 3443 | 3437 | 21897 | 3772 | 3772 | 25950 | 7215 | 7209 | 47847 |
| ក.2.5 | សណ្តែកសរុប | 21 | 21 | 24 | 3519 | 3519 | 5162 | 3540 | 3540 | 5186 |
| ក.2.6 | ត្រាវ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | ដំណាំឧស្សាហកម្ម | *1576* | *1576* | *12770* | *2389* | *2389* | *17975* | *3965* | *3965* | *30745* |
| ក.2.7 | សណ្តែកដី | 0 | 0 | 0 | 8 | 8 | 12 | 8 | 8 | 12 |
| ក.2.8 | សណ្តែកសៀង | 0 | 0 | 0 | 25 | 25 | 42 | 25 | 25 | 42 |
| ក.2.9 | ល្ង | 221 | 221 | 69 | 18 | 18 | 8 | 239 | 239 | 77 |
| ក.2.10 | អំពៅ | 453 | 453 | 11799 | 633 | 633 | 15825 | 1086 | 1086 | 27624 |
| ក.2.11 | ក្រចៅ | 0 | 0 | 0 | 11 | 11 | 11 | 11 | 11 | 11 |
| ក.2.12 | កក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ក.2.13 | ម្ទេស | 0 | 0 | 0 | 196 | 196 | 392 | 196 | 196 | 392 |
| ក.2.14 | ថ្នាំជក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ក.2.15 | ឈូក | 902 | 902 | 902 | 563 | 563 | 563 | 1465 | 1465 | 1465 |
| ក.2.16 | ជីគ្រាប់ | 0 | 0 | 0 | 935 | 935 | 1122 | 935 | 935 | 1122 |

បានឃើញ និងឯកភាព
ប្រធានមន្ទីរកសិកម្ម ខេត្តកណ្តាល

ប៊ុនធួន-ស៊ីមូណា

តាខ្មៅ,ថ្ងៃទី ខែ ឆ្នាំ ២០១៥
ការិយាល័យផែនការ គណនេយ្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្រុក ស្អាង
ឃុំ ស្វាយប្រទាល

## ស្ថិតិប្រជាពលរដ្ឋប្រចាំ ឆមាសទី ១ ឆ្នាំ ២០១៧

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | | | ចំនួនប្រជាពលរដ្ឋ | | | | | | ចំនួនប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | អចិន្ត្រៃយ៍ | បណ្តោះអាសន្ន | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្តោះអាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្តោះអាសន្ន | |
| | | | | | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 |
| 1 | ព្រៃ កតាតិន | 360 | 360 | | 1539 | 839 | 1539 | 839 | - | - | 936 | 436 | 936 | 436 | - | - |
| 2 | ឫស្សីជ្រោយ | 409 | 409 | - | 1981 | 1134 | 1981 | 1134 | - | - | 1299 | 735 | 1299 | 735 | - | - |
| 3 | ព្រៃកតាជ័រ | 553 | 553 | - | 2608 | 1342 | 2608 | 1342 | - | - | 1390 | 690 | 1390 | 690 | - | - |
| 4 | ព្រៃកតាសៅ | 366 | 366 | | 1570 | 816 | 1570 | 816 | - | - | 1080 | 577 | 1080 | 577 | - | - |
| 5 | ចុងកោះគរ | 182 | 182 | | 789 | 408 | 789 | 408 | - | - | 542 | 300 | 542 | 300 | - | - |
| 6 | បារ៉ែនលើ | 225 | 225 | | 982 | 531 | 982 | 531 | - | - | 515 | 345 | 515 | 345 | - | - |
| 7 | អូរចេក | 234 | 234 | | 1035 | 532 | 1035 | 532 | - | - | 474 | 251 | 474 | 251 | - | - |
| 8 | បារ៉ែនក្រោម | 685 | 685 | | 3050 | 1617 | 3050 | 1617 | - | - | 2046 | 1103 | 2046 | 1103 | - | - |
| 9 | ពោធិតាប៉ាង | 535 | 535 | | 2456 | 1269 | 2456 | 1269 | - | - | 1270 | 665 | 1270 | 665 | - | - |
| សរុប | | 3549 | 3549 | | 16010 | 8488 | 16010 | 8488 | - | - | 9552 | 5102 | 9552 | 5102 | - | - |

បញ្ជាក់: ចំពោះភូមិដែលមិនមានប្រកាសទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ប្រជាពលរដ្ឋនៅក្នុងភូមិនោះ ត្រូវស្រង់បូកបញ្ចូលទៅក្នុងភូមិដែលមានប្រកាសទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ។

បានឃើញ និង ឯកភាព
ថ្ងៃទី១២ ខែ មិថុនា ឆ្នាំ២០១៧
ឃុំ ស្វាយប្រទាល
ឡុង សៀង

ធ្វើនៅស្វាយប្រទាល ថ្ងៃទី១២ ខែ មិថុនា ឆ្នាំ ២០១៧
ស្មៀន

# ឧបសម្ព័ន្ធទី៤

កសិករស្រោចទឹកលើរងបន្លែដែលពង្រោះគ្រាប់រួច



កសិករស្រោចស្រពបន្លែ



ការស្រោចស្រពរងបន្លែដោយប្រើបំពង់បាញ់ទឹកស្វ័យប្រវត្តិ



ការជម្រះស្មៅ



ការជម្រះស្មៅ



បន្លែដែលកសិករដាំលើដីទំនេរក្បែរផ្ទះ



បន្លែជិតប្រមូលផល



ការសម្ភាសន៍កសិករពេលកំពុងប្រមូលផល






ឈ្មួញកណ្តាលវេចខ្ចប់បន្លែសម្រាប់យកទៅលក់បន្តនៅទីផ្សារ

